# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៧ លេខ ១២ ខែ ធ្នូ

ព. ស. ២៥០៧ គ. ស. ១៩៦៥

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* ទំព័រ

១- ម្ដាយឪពុកខ្វះទុកចិត្តកូននាំឲ្យខកខ្លួន ព្រះសាសនមុនី កិម-ទូរ រៀបរៀង . . ១២៣២

*ផ្នែកអក្សរសាស្ត្រ*

២– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ១២៥២
៣ – រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ - កន ប្រែរៀបរៀង(ត) . . . ១២៥៤
៤– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. តាម ស្រាវជ្រាវ (ត) . . . . . ១២៥៨
៥– ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ១២៧៦
៦– លទ្ធផលនៃការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៥ . . ១៣២៤
៧– ពិធីប្រគល់មុខងារបាងហ្វាងសាសនាអ៊ិស្លាម . . . . . . ១៣២៧
៨– សេចក្ដីកត់ហេតុ ទី ៧ . . . . . . . . . ១៣៣៨
៩– សេចក្ដីកត់ហេតុ ទី ៨ . . . . . . . . . . ១៣៤០
១០– ចុតហ្មាយអ្នកឧកញ៉ាពិភក្តិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ . . . . ១៣៤៦

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុសខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។
រ.ព.

# ម្តាយឪពុកខ្លះទុកចិត្តកូននាំឲ្យខកខាន

ព្រះសាសនមុនី កិម-ទូវ រៀបរៀង

រឿងនេះ មិនមែនមានទូទៅគ្រប់តែម្តាយឪពុក ឬគ្រប់តែកូនទាំងអស់ទេ យើងបានឮខ្លះ បានសង្កេតទៅឃើញខ្លះ នៅនាបច្ចុប្បន្នកាលនេះ ចំពោះម្តាយឪពុកខ្លះដែលទុកចិត្តទៅលើកូន ហើយនាំឲ្យមានវិប្បដិសារៈ (សេចក្តីក្តៅក្រហាយចិត្ត) ជាខាងក្រោយ ពីព្រោះតែកូននោះជាមនុស្សអកតញ្ញូ ដែលនាំឲ្យម្តាយឪពុកទុកចិត្តខុស ឬស្មានខុស ដូចសេចក្តីដែលលើកយកមកពណ៌នាដោយសង្ខេបតទៅនេះ :-

មានម្តាយឪពុកខ្លះ តាំងពីកូនកើតមក ដែលវាកំពុងតែនៅក្នុងវ័យជាទារក មិនទាន់ល្មមឲ្យចូលក្នុងសាលារៀននៅឡើយ មិនដែលអប់រំកូនឲ្យស្គាល់លោកសង្ឃ មិនដែលអប់រំកូនឲ្យចេះសំពះ ឬថ្វាយបង្គំលោកសង្ឃសោះទេ មិនដែលនាំកូនទៅវត្តឲ្យវាឃើញគេធ្វើបុណ្យទានអ្វីសោះទេ ម្ល៉ោះហើយកូននោះឯង ក៏គ្មាននិស្ស័យចិត្តគំនិតផ្ចិតផ្ចាប់

មកខាងពុទ្ធសាសនាបន្តិចបន្តួចសោះឡើយ ។ លុះកូននោះមានវ័យចម្រើនឡើងល្មមដល់ការសិក្សាហើយ ម្តាយឪពុកក៏ដឹកនាំកូនឲ្យចូលទៅសិក្សាឯសាលារៀន ។ ក្នុងសាលារៀននោះ កូនខំសិក្សាចំពោះតែវិជ្ជាទាំងឡាយខាងផ្លូវលោក មានវិជ្ជាខាងអក្សរសាស្ត្រជាដើមប៉ុណ្ណោះ ម្ល៉ោះហើយកូននោះ ក៏មានចំណេះចេះដឹងយល់តែខាងផ្លូវលោកម្យ៉ាង ឯលទ្ធិខាងពុទ្ធសាសនា ដែលប្រដៅមនុស្សឲ្យជឿ កម្ម-ផល, បុណ្យ-បាប, គុណ-ទោស, សុចរិត-ទុច្ចរិត ។ល។ យ៉ាងណា, កូននោះឯងក៏ទៅជាមនុស្សឥតដឹង ឥតយល់រសជាតិ នៃពុទ្ធសាសនានោះថា ដូចម្តេចសោះឡើយ, កូននោះ មិនត្រឹមតែមិនដឹងពុទ្ធសាសនាប៉ុណ្ណោះទេ ថែមទាំងមិនដឹងមិនយល់ថា ម្តាយឪពុករបស់ខ្លួនមានគុណឧបការៈលើខ្លួនដូចម្តេចផងទៀត, ព្រោះហេតុនោះ បានជាយុវជនខ្លះ និយាយថា ម្តាយឪពុកគ្មានគុណបំណាច់អ្វីនឹងកូនប៉ុន្មានទេ ព្រោះយើងដែលកើតមកដោយសារសេចក្តីសប្បាយរបស់គាត់ទេតើ មួយយ៉ាងទៀត ម្តាយឪពុកដែលបង្កើតកូនមក ជាភារៈត្រូវតែចិញ្ចឹមកូន, ត្រូវតែទំនុកបម្រុងកូនតាមនាទីនៃខ្លួនជាម្តាយឪពុក យ៉ាងនេះក៏មាន ។ កូនខ្លះទៀត ដែលមិនដឹងថា ម្តាយឪពុកមានគុណដូចម្តេច ហើយចេះតែព្រងើយកន្តើយមិនសូវរវល់អើពើនឹងម្តាយឪពុក ទោះបីម្តាយឪពុកចាស់ជរា ឬមានទុក្ខធុរៈដូចម្តេចក៏ដោយ, ដូនកាលកូននោះឯង ហ៊ានប្រមាថមើល

ងាយ ហ៊ានជេរឈ្លោះតបតទៅរកម្តាយឪពុករបស់ខ្លួនវិញ យ៉ាងនេះក៏សឹងមាន ។ល។

មានម្តាយឪពុកខ្លះ ទំនុកបម្រុងកូនឲ្យរៀនសូត្រ ដោយមានគោលបំណងចង់ឲ្យកូនខ្លួនមានចំណេះវិជ្ជា ក្រែងលោភ័ព្វមាន នឹងបានធ្វើការជានេះ ឬជានោះនឹងគេ, គ្រាន់នឹងបានជួយដោះស្រាយបញ្ហាជីវិតក្នុងគ្រួសាររបស់ខ្លួន, ម្ល៉ោះហើយក៏ខំប្រឹងប្រែងធ្វើការរកស៊ី សន្សំប្រាក់កាសដោយសេចក្តីនឿយហត់លំបាកក្រៃលែង ដើម្បីយកទៅផ្តល់ជួយឧបត្ថម្ភកូនឲ្យមានកម្លាំងរៀនសូត្រ ។ ប៉ុន្តែផ្ទុយស្រឡះពីគោលបំណងរបស់ម្តាយឪពុកទៅវិញសោះ ព្រោះកូននោះ រៀនសូត្របានចម្រើនហូរហែតាមលំដាប់ រហូតដល់មានការចេះដឹងជាក់ខ្ពស់ហើយ ក៏ទៅទាក់ទងនឹងអ្នកដទៃ ដោយឃើញកូនក្រមុំរបស់គេ ឬអ្នកដទៃមានកូនក្រមុំគេមកទាក់ទងប្រស្រ័យនឹងខ្លួន ដោយគេសំឡឹងឃើញថា ខ្លួនមានវិជ្ជាជាក់ខ្ពស់ ប្រាកដជានឹងបានការហើយ គេក៏តាំងធ្វើជាអ្នកទំនុកបម្រុងចុងក្រោយ បញ្ចុកបន្សី ដឹកនាំដើម្បីឲ្យងាកចិត្ត ទៅតាមគោលបំណងរបស់គេ, កាលបើគេដឹងថាខ្លួនបាក់ចិត្តទន់ទោរទៅរកគេហើយ គេក៏ស៊ូចាយប្រាក់កាសចេញជំនួសខ្លួន ទុកដូចជាទិញខ្លួនឲ្យរៀបមង្គលការជាមួយនឹងកូនស្រីគេ, ខ្លួនក៏បានទៅជាកូនប្រសារបស់គេទៅ ។ ឯខាងត្រកូលស្រី គេលើកតម្កើងឲ្យ កិត្តិយសឲ្យសុខស្រួលទទួលស្គាល់

ចំពោះតែខ្លួនមួយប៉ុណ្ណោះ, ត្រង់ម្ដាយឪពុកបងប្អូនសាច់ញាតិខាងខ្លួន គេមិនសូវទទួលស្គាល់ មិនសូវរាប់អាន គេវ៉ៃឫកក្រអឺតក្រអោង ធ្វើងៃធ្ងោ ដោយគេនឹកខ្លាចក្រែងម្ដាយឪពុកបងប្អូនសាច់ញាតិឯង ទៅពឹងពាក់គេ ឬរកទ្រព្យសម្បត្តិគេ ពុំនោះសោត កូនឯងជាមនុស្សអកតញ្ញូស្រាប់ផង ក៏វ៉ៃឫកក្រអឺតក្រអោងធ្វើងៃធ្ងោផងដែរ ឃើញម្ដាយឪពុកឃើញបងប្អូនសាច់ញាតិណាមួយមានភាពជាអ្នកស្រែចំការមករកខ្លួន ក៏សម្ដែងអាការសោះអង្គើយ ធ្វើហាក់ដូចជាមិនស្គាល់ មិនសូវរាក់ទាក់ មិនសូវរាប់រក ដោយមានសេចក្ដីអៀនខ្មាស ខ្លាចថោកទាបខូចកិត្តិយសរាប់មុខខ្លួន, ម៉្លោះហើយម្ដាយឪពុកបងប្អូនសាច់ញាតិ បានដឹងអាការចិត្តគំនិតរបស់កូនឬបងប្អូនឯងដូច្នោះហើយ ក៏កើតវិប្បដិសារៈ គឺសេចក្ដីក្ដៅក្រហាយ អាក់អន់ក្នុងចិត្តយ៉ាងខ្លាំង លែងទៅជួប លែងទៅរកប្រស្រ័យទៀសវាងមួយជីវិត, ទៅជាមោឃៈ ឥតបានទទួលលទ្ធផលអ្វីតបអពីកូននោះសោះឡើយ យ៉ាងនេះក៏មាន ។

មានម្ដាយឪពុកខ្លះ មានទ្រព្យសម្បត្តិគួរសមដែរ មានកូនក៏ច្រើននាក់, លុះដល់កូនទាំងនោះមានវ័យចម្រើនធំឡើងហើយ ក៏រៀបចំកូននោះឲ្យមានគូស្រករៀងៗខ្លួន, កាលបើបានរៀបចំទុកដាក់កូនឲ្យមានផ្ទះសម្បែងអស់ហើយ ក៏មានគំនិតគិតថា ឥឡូវអាត្មាអញបានរៀបចំទុកដាក់កូនឲ្យមានគូស្រកររួចស្រេចហើយ, ខ្លួនក៏ចូលមកក្នុងបច្ឆិមវ័យហើយ, ឯទ្រព្យសម្បត្តិ

ក៏នៅមានខ្លះដែរ ណ្ហើយចុះអត្មាអញ គួរតែចែកទ្រព្យសម្បត្តិដែលមាននេះប្រគល់ឲ្យទៅកូនទាំងអស់ទៅចុះ, ហើយទៅនៅប្រស្រ័យចិញ្ចឹមជីវិតរស់នៅនឹងកូននេះខ្លះ កូននោះខ្លះទៅបានហើយ, លុះទុកចិត្តគិតឃើញយ៉ាងនេះហើយ ក៏បែងចែកទ្រព្យសម្បត្តិទាំងនោះឲ្យដល់កូនអស់រលីងទៅ ៗ បើកូនទាំងនោះ ជាមនុស្សកតញ្ញូ ម្ដាយឪពុកក៏មានភ័ព្វសមប្រកបដូចបំណងរបស់ខ្លួន, តែបើកូនទាំងនោះ ជាមនុស្សអកតញ្ញូវិញទេ, ម្ដាយឪពុកប្រាកដជាទទួលអភ័ព្វបង់គំនិតពុំខាន, ដឹងធ្លាក់ខ្លួនទៅជាមនុស្សគ្មានទីពឹងពំនាក់ រងសេចក្ដីទុក្ខលំបាកព្រួយចិត្តអស់មួយជីវិតក៏មាន, កូនខ្លះឃើញម្ដាយឪពុកនៅមានទ្រព្យ ក្ដើអាករជាច្រើនទៀតមិនទាន់ចែកអស់ ក៏ដើរខ្វាយធ្វើជាទៅបម្រើផ្គាប់ផ្គុនម្ដាយឪពុក ដើម្បីឲ្យម្ដាយឪពុកចែកមកឲ្យខ្លួនទៀត កាលបើម្ដាយឪពុកបានចែកឲ្យមកខ្លួនអស់ហើយ ក៏ប្រែគំនិតធ្វើព្រងើយកន្តើយលែងផ្គាប់ផ្គុនបម្រើ លែងទទួលដឹងសុខ-ទុក្ខរបស់ម្ដាយឪពុកទៅវិញ យ៉ាងនេះក៏មាន ។ល។

សូមលើកយករឿងព្រាហ្មណ៍ម្នាក់ ដែលមានក្នុងគម្ពីរធម្មបទដ្ឋកថា ខុទ្ទកនិកាយ ត្រង់នាគវគ្គ មកសម្ដែងជាឧទាហរណ៍ថា :

មានព្រាហ្មណ៍ចាស់ម្នាក់ អាស្រ័យនៅក្នុងក្រុងសាវត្ថី, មានប្រាក់ចំនួន ៨ សែនកហាបណ: មានទាំងកូនប្រុស ៤ នាក់ផង ៗ លុះដល់កូនទាំង ៤ នាក់នោះ មានវ័យចម្រើនធំឡើងហើយ, ព្រាហ្មណ៍ និង

ព្រាហ្មណ៍ជាឪពុកម្ដាយ ក៏រកគូស្រករៀបចំអាពាហ៍ពិពាហ៍ឲ្យកូនប្រុសទាំង ៤ នាក់មានភរិយាគ្រប់គ្នាហើយ, បានទាំងចែកទ្រព្យឲ្យម្នាក់មួយសែនកហាបណៈ ម្នាក់មួយសែនកហាបណៈ គ្រប់កូនទាំង ៤ នាក់ផង ទុកនៅសល់តែ ៤ សែនកហាបណៈប៉ុណ្ណោះ ៗ លុះចំណេរកាលជាខាងក្រោយមក, ព្រាហ្មណីជាម្ដាយទទួលអនិច្ចកម្មទៅ, កូនទាំងនោះក៏ប្រឹក្សាគ្នាថា បើឪពុកយើងយកប្រពន្ធដទៃទៀត ត្រកូលនិងទ្រព្យសម្បត្តិទាំងប៉ុន្មាន ដែលមាននៅក្នុងបន្ទុករបស់គាត់ មុខតែនឹងបែកខ្ចាត់ខ្ចាយដោយអំណាចកូនក្រោយពុំខាន, បើដូច្នេះ យើងត្រូវសង្គ្រោះទំនុកបម្រុងគាត់កុំឲ្យគាត់លំបាក ៗ ចាប់ដើមពីថ្ងៃនោះទៅ, កូនទាំង ៤ នាក់ ក៏ដើរទៅផ្លាស់វេនគ្នាបម្រើផ្គាប់ផ្គុនឪពុក ដោយជូនរបស់ប្រើប្រាស់មានសំពត់សម្រាប់ស្លៀកពាក់និងចំណីអាហារជាដើមផង គក់ច្របាច់ថៃទាំបម្រើដោយជូនទឹកក្ដៅទឹកត្រជាក់ជាដើមផង ៗ ក្នុងពេលដែលកូនទាំងនោះទៅបម្រើម្ដង ១ និយាយពណ៌នាតែពីទោសឃរាវាស គឺការនៅគ្រប់គ្រងផ្ទះមានប្រពន្ធកូនតែងបានទទួលនូវសេចក្ដីទុក្ខព្រួយលំបាកដូច្នេះខ្លះ ដូច្នោះខ្លះ ឲ្យឪពុកខ្លួនស្ដាប់ ដើម្បីទប់ពាំងកុំឲ្យឪពុកនឹកនាចង់បានប្រពន្ធទៀតៗ មិនតែប៉ុណ្ណោះ នាំគ្នានិយាយល្បួងលោមឪពុកថា សូមលោកឪពុកកុំយកប្រពន្ធទៀត យើងជាកូនទាំងអស់គ្នា នឹងមកបម្រើឪពុកតាមរបៀបនេះ អស់មួយជីវិតរៀង ១ ខ្លួន ដើម្បីកុំឲ្យឪពុកព្រួយលំបាកនឹងអ្វីឡើយ

ប៉ុន្តែទ្រព្យសម្បត្តិទាំងប៉ុន្មានដែលនៅសល់ ឪពុកចាស់ហើយទុកធ្វើអ្វីទៀត, សូមឪពុកចែកប្រគល់ឲ្យយើងជាកូនទាំងអស់គ្នាមក ។

ព្រាហ្មណ៍ជាឪពុក លុះបានឮសំដីកូនទាំងអស់ និយាយទទួលព៉ប់វេសព្វយ៉ាងដូច្នោះហើយ ក៏ធ្វើតាម ទាំងគិតឃើញថា ឯងចាស់ហើយទុកសម្បត្តិធ្វើអ្វីទៀត គួរតែចែកឲ្យវាទាំងអស់ទៅ ហើយសុំទៅនៅជ្រកអាស្រ័យនឹងកូននេះម្តង កូននោះម្តង ទំរាំតែដល់ពេលខ្លួនស្លាប់ទៅចុះ ។ ព្រាហ្មណ៍នោះ លុះគិតឃើញយ៉ាងនេះហើយ ក៏យកប្រាក់ដែលនៅសល់ ៤ សែនកហាបណៈនោះ មកចែកឲ្យកូនទាំង ៤ ត្រូវបានមួយសែនកហាបណៈ ១ នាក់ ១ ទៀត ទាំងគ្រឿងឧបភោគ-បរិភោគសម្រាប់ប្រើប្រាស់ខាងក្នុងផ្ទះ និងខាងក្រៅផ្ទះទាំងប៉ុន្មាន ក៏បែងចែកឲ្យកូនអស់រលីង នៅសល់ទុកត្រឹមតែសំពត់សម្រាប់ស្លៀកដណ្តប់ពោះខ្លួនមួយប៉ុណ្ណោះ ។ ចំណែកខាងកូនទាំងអស់ កាលបើឃើញឪពុកចែកទ្រព្យសម្បត្តិឲ្យអស់រលីងពីខ្លួនហើយ ក៏សម្តែងអាការព្រងើយកន្តើយ សោះអង្គើយ លែងយកចិត្តទុកដាក់បម្រើតទៅទៀត ។ ថ្ងៃក្រោយមក, មុនដំបូង តាព្រាហ្មណ៍ ទៅនៅអាស្រ័យនឹងផ្ទះកូនបងតាមគំនិតដែលខ្លួនបានគិតទុកពីមុនមក, នៅមិនទាន់បានយូរថ្ងៃប៉ុន្មាន កូនបងមត់គ្មានសមគំនិតនឹងប្រពន្ធខ្លួន ក៏និយាយញុះញង់ឲ្យប្រពន្ធស្តីបន្ទោសឪពុកខ្លួន, មេប្រពន្ធនោះក៏តាំងនិយាយថា "នែឪឯង, កាលដែលចែកទ្រព្យ

សម្បត្តិឲ្យកូនទាំងអស់នោះ គឺឪពុកឯងចែកឲ្យស្មើ ៗ គ្នា គ្មានលើសគ្មានខ្វះជាងគ្នាទេ, បើឪពុកឯង ចែកឲ្យកូនបងលើសគេចំនួនជាមួយរយ ឬមួយពាន់កហាបណៈទៅចុះ ខ្ញុំក៏មិនថាអីដែរ, នេះមិនដូច្នោះ កូនទាំងអស់បានទទួលចំណែកស្មើៗ គ្នាទេតើ! ហេតុដូចម្តេច បានជាឪពុកឯងមិនស្គាល់ផ្លូវទៅផ្ទះកូនឯទៀតផង, ស្គាល់តែត្រង់ផ្ទះកូនបងមួយ» ? តាព្រាហ្មណ៍ឪពុក លុះបានឮសំដីមេកូនប្រសាស្តីបន្ទោស ថាឲ្យ ដោយពាក្យត្រគោះពុំសមគួរដូច្នោះហើយ ក៏ខឹងប្រឡោតគោតគូង ដេរប្រទេចផ្តាសា ទាំងកូនបង្កើត ទាំងកូនប្រសា ហើយចុះចេញពីផ្ទះកូនបងនោះ ទៅនៅនឹងផ្ទះកូនបន្ទាប់ទៀត, នៅទើបតែនឹងបានពីរបីថ្ងៃប៉ុណ្ណោះ មេកូនប្រសាសមគំនិតគ្នានឹងប្តី ក៏តាំងនិយាយស្តីឲ្យតាព្រាហ្មណ៍ឪពុកនោះទៀតថា «ឪពុកឯង កាលដែលចែកទ្រព្យសម្បត្តិ ឲ្យដល់កូនទាំងអស់នោះ ចំណែកខាងប្រាក់បាទពីរសែនម្នាក់ ៗ ទាំងគ្រឿងឧបភោគ-បរិភោគឯទៀត ឪពុកឯងក៏ចែកឲ្យស្មើ ៗ គ្នាដែរ គ្មានលើសគ្មានខ្វះជាងគ្នាទេ, ម៉េចក៏ឪពុកឯងស្គាល់តែផ្ទះខ្ញុំ ត្រង់ផ្ទះកូនឯទៀត ម៉េចក៏មិនស្គាល់ផង» ? តាព្រាហ្មណ៍ឪពុក និម្មិតតែបានឮសំដីមេកូនប្រសាស្តីបន្ទោសថាឲ្យខ្លួនដូច្នោះ ក៏ខឹងដេរប្រទេចហើយចុះចេញពីផ្ទះកូននោះ ទៅនៅទីផ្ទះកូនទី ៣ និងកូនទី ៤ ដទៃទៀត, ក៏ត្រូវបានកូនទាំងនោះស្តីបន្ទោសថាឲ្យដូចគ្នាទៀត ។ តាព្រាហ្មណ៍ លែងបានចូលទៅរក

ផ្ទះកូនណាទាំងអស់, ឃើញថាអស់សង្ឃឹម អស់ទីពឹងនៅលើកូនបានហើយ, ក៏ស្លៀកពាក់សធ្វើជាតាជី ដៃកាន់ឈើច្រត់ដើរសូមទានគេចិញ្ចឹមជីវិត ៗ ការចិញ្ចឹមជីវិតដោយភាពជាសូមនៃតាព្រាហ្មណ៍នោះប្រព្រឹត្តទៅអស់កាលដ៏យូរ, ព្រោះតែភោជនដែលបរិភោគមិនល្អ និងដំណេកដេកមិនល្អ រាងកាយនៃតាព្រាហ្មណ៍នោះ ក៏កាន់តែជរាទ្រុឌទ្រោមស្វិតស្រពោនស្គមចុះទៅជាលំដាប់ ៗ ថ្ងៃមួយ តាព្រាហ្មណ៍ដើរសូមទានគេបានមក បរិភោគរួចហើយ ក៏ដេកសម្រាកកាយលក់ក្នុងវេលាថ្ងៃ លុះភ្ញាក់ដើបក្រោកឡើងអង្គុយសម្លឹងអត្តភាពខ្លួន មិនឃើញមានការទីពឹងរបស់ខ្លួនទៅលើកូនសោះ ក៏គិតថា ឱ ! អាត្មាអញ ជាមនុស្សអភ័ព្វហើយតើ, កាលពីដើម ខ្លួនមានទ្រព្យសម្បត្តិគួរសមដែរ, មកពីខ្លួនទុកចិត្តកូន បានជាចែកសម្បត្តិដែលមានទាំងប៉ុន្មានឲ្យដល់កូនអស់ គិតថានឹងបានទៅនៅទីពឹងកូនក្នុងពេលដែលខ្លួនចាស់; គំនិតនេះខុសស្រឡះ ព្រោះកូនទាំងនោះសុទ្ធតែជាកូនអកតញ្ញូ ៗ ឥឡូវនេះ ឮថា ព្រះសមណគោតមព្រះអង្គមានព្រះភក្ត្រមិនចេះក្រញូវ មានព្រះភក្ត្រស្រស់ស្រាយជាធម្មតា ទាំងព្រះវាចារបស់ព្រះអង្គទៀតសោត ក៏ពីរោះព្រះអង្គប៉ុនប្រសប់ចេះធ្វើបដិសណ្ឋារៈចំពោះអ្នកដទៃណាស់, ដូច្នេះគួរតែអាត្មាអញចូលទៅរកព្រះសមណគោតមវិញ ក្រែងបានសេចក្តីសង្គ្រោះអំពីព្រះអង្គខ្លះ ៗ គ្រានោះ តាព្រាហ្មណ៍ លុះគិតឃើញ

យ៉ាងនេះហើយ ក៏កាន់ឈើច្រត់ដើរទៅកាន់សំណាក់ព្រះពុទ្ធ, ព្រះអង្គទ្រង់ទតឃើញព្រាហ្មណ៍នោះចូលមកដល់, ទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងព្រាហ្មណ៍នោះ រួចហើយទើបទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍, អ្នកម៉េចក៏មានខ្លួនសៅហ្មងស្គាំងស្គមម៉្លេះ, ទាំងសំពត់ស្លៀកពាក់ក៏សៅហ្មងដែរដូច្នេះ? តាព្រាហ្មណ៍ក្រាបទូលថា ឱ! ព្រះអង្គអើយ, ខ្ញុំព្រះអង្គមានកូនប្រុស ៤ នាក់, បានរៀបចំទុកដាក់ឲ្យមានប្រពន្ធគ្រប់គ្នា ហើយបានទាំងចែកទ្រព្យសម្បត្តិឲ្យគេអស់រលីងពីខ្លួន ដោយគិតថា នឹងបានទីពឹងគេក្នុងពេលដែលខ្លួនចាស់ តែកូនទាំងនោះ គេសមគំនិតជាមួយនឹងប្រពន្ធគេបណ្ដេញខ្ញុំព្រះអង្គឲ្យចេញអំពីផ្ទះ, បានជាខ្ញុំព្រះអង្គមានសេចក្ដីទុក្ខលំបាកយ៉ាងនេះ ៗ ព្រះបរមសាស្ដាចារ្យ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍, បើដូច្នេះ តថាគតជួយសង្គ្រោះអ្នក ប៉ុន្ដែអ្នកត្រូវរៀនគាថាទាំងឡាយដែលតថាគតប្រាប់ឲ្យចាំ ហើយដល់ពេលណាដែលពួកមហាជនប្រជុំគ្នាក្នុងសភា ទាំងកូនរបស់អ្នកក៏មុខតែមកអង្គុយក្នុងទីប្រជុំនោះដែរ ចូរអ្នកសុំឱកាសគេហើយសូត្រគាថាទាំងនេះចុះ ៗ តាព្រាហ្មណ៍ បានរៀនគាថាទាំងឡាយនោះ ក្នុងសំណាក់នៃព្រះមានព្រះភាគចាំស្ទាត់ហើយ, ដូនជាដល់ថ្ងៃត្រូវពួកព្រាហ្មណ៍ប្រជុំគ្នាក្នុងសភា ទាំងកូននៃព្រាហ្មណ៍ ក៏ចូលទៅអង្គុយប្រជុំជាមួយគេក្នុងសភានោះដែរ ៗ តាព្រាហ្មណ៍គិតថា ពេលនេះជាឱកាសល្អដល់អាត្មាអញហើយ ក៏ចូលទៅឈរក្នុងកណ្ដាលសភា

លើកដៃឡើងថា នែអស់លោកទាំងឡាយ! ខ្ញុំចង់ពោលគាថាទាំងឡាយ ដើម្បីឲ្យអស់លោកទាំងឡាយស្តាប់ តើអស់លោកពល់គ្នានឹងស្តាប់ឬទេ? ព្រាហ្មណ៍ទាំងឡាយក្នុងទីប្រជុំនោះ បានឆ្លើយឡើងថា នែលោកតា! លោកតាចូរពោលគាថាទាំងនោះមកចុះ យើងទាំងអស់គ្នានឹងស្តាប់ ។ តាព្រាហ្មណ៍ បានពោលគាថាទាំងឡាយ ដែលខ្លួនបានរៀនអំពីសំណាក់ព្រះសម្ពុទ្ធបរមគ្រូថា :

យេហិ ជាតេហិ នន្ទិស្សំ យេសញ្ច ភវមិច្ឆិសំ
តេ មំ ទារេហិ សំបុច្ឆា សាវ វារេន្តិ សូករំ ។

។ ល ។

អក្ខការេ បុរេ ហោតិ គម្ភីរេ គាធមេជតិ
ធណ្ហស្ស អាតុការេន ខលិត្វា បដិតិដ្ឋតិ ។

ខ្ញុំត្រេកអរកែកពយជាមួយនឹងកូនទាំងឡាយណាដែលកើតមកហើយផង ទាំងប្រាថ្នានូវសេចក្តីចម្រើនដល់កូនទាំងឡាយណាផង កូនទាំងឡាយនោះ ៗ ក៏សមគំនិតជាមួយនឹងប្រពន្ធក៏ ហើយបណ្តេញខ្ញុំឲ្យចុះចេញអំពីផ្ទះ ដូចជាឆ្កែដេញទាំជ្រូក ៗ កូនទាំងឡាយណា ជាអសប្បុរសលាមក ដូចជាអារក្សទឹកកើតមកគ្រាន់តែមានរូបដូចជាកូន ក៏នាំគ្នាហៅខ្ញុំថាឪ ៗ តែកូនទាំងឡាយនោះ ក៏បោះបង់ចោលខ្ញុំដែលចាស់ជក មានវ័យកន្លងទៅហើយ ៗ កូនពាលទាំងឡាយ ក៏លែងចោលឪពុក

ដែលមានវ័យចាស់ជរា ឲ្យដើរសូមទានគេ ទៀបសំយាបផ្ទះនៃជនដទៃ ដូចជាសេះចាស់ដែលគេប្រើប្រាស់មិនកើត ហើយគេដេញចេញពីចំណី លែងចោល ។ ឈើច្រត់របស់ខ្ញុំឯណោះទេ ដែលប្រសើរជាង ព្រោះ ឈើច្រត់អាចការពារគោកាចក៏បាន, ការពារឆ្កែកាចក៏បាន, ច្រត់ស្ទាប ស្ទង់ខាងមុខកន្លែងងងឹតក៏បាន, ច្រត់ស្ទាបស្ទង់កន្លែងដែលមានថ្លុកជង្ហុក ជ្រៅក៏បាន, (ម្យ៉ាងទៀត) អានុភាពនៃឈើច្រត់នេះ កាលបើភ្លាត់កេ កល់ចង់ដួល អាចច្រត់ទប់ខ្លួនឲ្យនៅនឹងវិញបាន, ឯកូនអសប្បុរស មិន ស្ដាប់បង្គាប់ ពុំប្រសើរដូចជាឈើច្រត់នេះឡើយ ។

ក៏កន្លងសម័យនោះ គេមានតាំងច្បាប់បញ្ញត្តិ សម្រាប់មនុស្សទាំង-ឡាយថា បើកូនណាបានទទួលទ្រព្យសម្បត្តិជារបស់ម្ដាយឪពុកមកបរិ-ភោគប្រើប្រាស់ហើយ មិនទំនុកបម្រុងចិញ្ចឹមម្ដាយឪពុកវិញទេ កូននោះ ត្រូវសម្លាប់ចោល ព្រោះហេតុនោះបានជាកូនទាំងឡាយនៃព្រាហ្មណ៍នោះ នាំគ្នាមកក្រាបទៀបជើងនៃតាព្រាហ្មណ៍ជាឪពុក និយាយអង្វរថា សូម លោកឪពុកឲ្យដីតដល់កូនទាំងឡាយផង កូននឹងទំនុកបម្រុងចិញ្ចឹមរក្សា លោកឪពុកដូចពីដើមឡើងវិញ ។ តាព្រាហ្មណ៍ជាឪពុក ឮសំដីកូន អង្វរដូច្នោះ ក៏មានហឫទ័យទន់ទោរទៅរកកូន ហើយនិយាយសុំទោស ទីប្រជុំថា ឱអស់លោកទាំងឡាយអើយ, សូមកុំធ្វើកូនខ្ញុំឲ្យវិនាស; ឥឡូវ កូនខ្ញុំវាព្រមទំនុកបម្រុងចិញ្ចឹមខ្ញុំវិញហើយ ។ គ្រានោះ ពួកមនុស្សក្នុង ទីប្រជុំបាននិយាយដាក់កម្រិត ចំពោះកូនទាំងនោះថា ចាប់ពីថ្ងៃនេះទៅ

បើអ្នកទាំងឡាយជាកូនហើយ មិនចាំទុកបម្រុងចិញ្ចឹមឪពុកទេ យើងនឹងសម្លាប់អ្នកទាំងឡាយចោល ។ កូនទាំងឡាយនោះ មានសេចក្ដីភ័យខ្លាចគេសម្លាប់ ក៏នាំគ្នាលើកឪពុកដាក់លើគ្រែ ហើយសែងនាំយកទៅផ្ទះ, លុះដល់ហើយ ក៏នាំគ្នាដងទឹកមកដូត យកគ្រឿងលំអិតមកដុះក្អែលជម្រះកាយឪពុកស្អាតបាតហើយ ឲ្យផ្លាស់គ្រឿងស្លៀកបំពាក់ចាស់ចោល ហើយឲ្យស្លៀកពាក់សុទ្ធតែសំពត់ថ្មីៗ ទាំងអស់, នាំគ្នាតាក់តែងអាហារភោជនយ៉ាងប្រណីតមកជូនឪពុកបរិភោគ ហើយនិយាយដាក់កម្រិត ចំពោះប្រពន្ធទាំងឡាយរបស់ខ្លួនថា នែរ៉ុយ! ឯង ចាប់ពីថ្ងៃនេះទៅ កុំធ្វេសប្រហែសនឹងឪពុកអញណា! តែបើឯងធ្វេសប្រហែស, អញនឹងកេរៀងស្ដីបន្ទោសជាទម្ងន់ពុំខាន ។

តាព្រាហ្មណ៍ជាឪពុក បានអាស្រ័យភោជនល្អ និង ដំណេកល្អគង់នៅរាល់ពីរបីថ្ងៃប៉ុណ្ណោះ ក៏មានកម្លាំងកំហែង ឥន្ទ្រិយក៏ឡើងពេញលេញ, សម្លឹងមើលអត្តភាពរបស់ខ្លួន ក៏គិតថា សម្បត្តិដែលអាត្មាអញបាននេះ ព្រោះអាស្រ័យនឹងព្រះសមណគោតម, លុះគិតឃើញដូច្នេះហើយក៏យកសំពត់មួយគូដើម្បីជាជង្គ្រាយ នាំយកទៅថ្វាយព្រះសម្មាសម្ពុទ្ធហើយក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍បានស្វែងរកទ្រព្យសម្រាប់បូជាអាចារ្យ ដើម្បីអាចារ្យ, ព្រះគោតមដ៏ចម្រើន ជាគ្រូអាចារ្យនៃខ្ញុំព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោសទទួលនូវ

សំពត់មួយគូនេះ ទុកជាទ្រព្យសម្រាប់បូជាអាចារ្យ ។ ព្រះភគវ័ត ទ្រង់ទទួលសំពត់មួយគូនោះដោយសេចក្ដីអនុគ្រោះចំពោះព្រាហ្មណ៍ ហើយទ្រង់សម្ដែងធម៌ទូន្មាន, លុះដល់ទីអវសាននៃធម្មទេសនាហើយ ព្រាហ្មណ៍នោះក៏បានបិតនៅក្នុងត្រៃសរណគមន៍ ទើបក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន, កូនចៅទាំងឡាយរបស់ខ្ញុំព្រះអង្គបានជូនធុរភត្ត (ភត្តជាប់ជានិច្ច) ៤ សម្រាប់ដល់ខ្ញុំព្រះអង្គ, ឲ្យសូមថ្វាយធុរភត្តពីរចំណែកចំពោះព្រះអង្គជានិច្ចរាល់ថ្ងៃ ។ ព្រះភគវ័ត ទ្រង់ត្រាស់តបនឹងព្រាហ្មណ៍នោះថា ល្អហើយព្រាហ្មណ៍! ណ្ហើយចុះកុំអី, តថាគតនឹងត្រាច់ទៅកាន់ទីដទៃតាមគាប់អធ្យាស្រ័យនៃតថាគតបានហើយ ។ ព្រាហ្មណ៍ថ្វាយបង្គំលាព្រះសម្ពុទ្ធត្រឡប់មកផ្ទះវិញ ប្រាប់កូនចៅទាំងឡាយថា នែកូនចៅតឡាយ, ព្រះសមណគោតមជាសម្លាញ់នៃអញ, ឥឡូវអញបានថ្វាយធុរភត្តពីរសម្រាប់ចំពោះព្រះសមណគោតមនោះ, កាលណាបើព្រះសមណគោតមព្រះអង្គយាងមកដល់ផ្ទះយើង កូនឯងរាល់គ្នាកុំធ្វេសប្រហែសឡើយ; លុះដល់ថ្ងៃព្រឹកឡើង មុនដំបូង ព្រះអង្គទ្រង់យាងទៅកាន់ផ្ទះកូនបង, ថ្ងៃព្រឹកទី ២ ទ្រង់យាងទៅកាន់ផ្ទះកូនបន្ទាប់, ព្រឹកថ្ងៃទី ៣ និង ទី៤ ទ្រង់យាងទៅតាមលំដាប់ដកបគ្រប់កូនចៅអស់ ។ កូនព្រាហ្មណ៍ទាំងឡាយ បានធ្វើបដិសណ្ឋារៈចំពោះព្រះអង្គដែលយាងមកដល់, បានថ្វាយបណីតភោជនចំពោះព្រះអង្គ ។ ក៏ទ្រង់សោយក្នុងទីនោះ ។ ក្នុងវេលាដែលព្រះអង្គទ្រង់

សោយរួចហើយ កូនព្រាហ្មណ៍ទាំង ៤ នាក់ បានក្រាបបង្គំទូលព្រះសម្ពុទ្ធជាម្ចាស់ថា បពិត្រព្រះសមណគោតមដ៏ចម្រើន, យើងខ្ញុំទាំងឡាយបានទំនុកបម្រុងចិញ្ចឹមឪពុកដោយឥតធ្វេសប្រហែសឡើយ, សូមព្រះអង្គទ្រង់ទតនូវអត្តភាពនៃឪពុករបស់យើងខ្ញុំទាំងឡាយៈនេះចុះ ។ ព្រះបរម-សាស្តា ទ្រង់សម្តែងធម៌ទេសនាទូន្មានកូនទាំងឡាយនោះថា ករណីយកិច្ចដែលអ្នកទាំងឡាយបានធ្វើនេះល្អហើយ, ការចិញ្ចឹមទំនុកបម្រុងមាតាបិតាឈ្មោះថាជាកិច្ចវត្តរបស់បោរាណកបណ្ឌិតទាំងឡាយ, ទើបព្រះសម្ពុទ្ធទ្រង់លើកយកអតីតនិទានរបស់ព្រះអង្គមកសម្តែងទៀតថា «កាលណោះតថាគតកើតជាដំរីឈ្មោះ ធនបាលកៈ អាស្រ័យនៅក្នុងព្រៃជាមួយនឹងម្តាយ ជាអ្នកស្រឡាញ់គោរពថែទាំចិញ្ចឹមម្តាយជាប្រក្រតី ។ គ្រានោះព្រះរាជាក្នុងដែនកាសី បានបញ្ជូនហ្មទ្យទៅទាក់ចាប់ដំរីឈ្មោះធនបាលកៈនោះមកថ្វាយ, សូម្បីហ្មនោះទាក់ចាប់បាននាំយកមកឲ្យនៅក្នុងពេនដំស្អាតល្អប្រោះព្រំដោយគ្រឿងក្រអូបយ៉ាងណាក្តី ឲ្យចំណីដ៏ល្អមានតម្លៃប្រសើរយ៉ាងណាក្តី ដំរីនោះមិនព្រមនៅ មិនព្រមបរិភោគចំណីនោះឡើយព្រោះវានឹករលឹកការឡោះអាល័យជានិច្ចទៅរកម្តាយដែលធ្លាប់បម្រើ ធ្លាប់នៅជាមួយ, ព្រះអង្គទ្រង់សម្តែងបញ្ជាក់ថែមទៀតថា សូម្បីដំរីជាសត្វតិរច្ឆាន វាចេះដឹងគុណគោរពបម្រើម្តាយវា ចុះដូចអ្នកទាំងឡាយ សុទ្ធតែជាជាតិមនុស្សត្រឡាំង គួរតែដឹងគុណគោរពបម្រើមាតាបិតារបស់ខ្លួនជាការប្រសើរណាស់» ។

កាលដែលព្រះបរមសាស្តា កំពុងនាំយកបុព្វចរិយា (ការប្រព្រឹត្តពីកន្លងកាលមុន) របស់ព្រះអង្គមកសម្តែង, កូនប្រុសទាំង ៤ នាក់ និង កូនប្រុសស្រីទាំង ៤ នាក់របស់ព្រាហ្មណ៍នោះបានស្តាប់ហើយ ក៏កើតវិប្បដិសារៈ គឺសេចក្តីក្តៅក្រហាយចិត្ត ស្តាយចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តពុំគប្បីទៅលើឪពុកកាលពីពេលមុននោះ ក៏ត្រឡប់ជាមានហឫទ័យទន់ទោរទៅរកឪពុករបស់ខ្លួនវិញ ៗ លុះចប់ធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធហើយ ជនទាំងអស់នោះ ក៏បានសម្រេចមគ្គ-ផលរៀង ១ ខ្លួន ១

រឿងដែលលើកយកមកពណ៌នាខាងលើនេះ សូមជ្រាបថា កូនព្រាហ្មណ៍ទាំង ៤ នាក់ ដែលបានប្រព្រឹត្តល្មើសពុំគប្បីនឹងឪពុកៈរបស់ខ្លួនពីពេលមុននោះ អាស្រ័យហេតុមកតែអំពីការមិនបានសេពគប់យល់ពុទ្ធសាសនា, ដល់ខាងក្រោយមក ក៏ត្រឡប់ជាដឹងគុណគោរពប្រតិបត្តិឪពុកខ្លួនវិញ ក៏អាស្រ័យហេតុមកតែអំពីការបានសេពគប់យល់ពុទ្ធសាសនាហ្នឹងឯ ៗ ព្រោះហេតុនោះ ម្តាយឪពុកនីមួយ ១ ខ្លួនជាពុទ្ធសាសនិក ពុំគួរបណ្តែតបណ្តោយកូនឲ្យឃ្លាតពីពុទ្ធសាសនាសោះឡើយ, កាលបើកូនឃ្លាតពីពុទ្ធសាសនា មិនយល់ន័យនៃពុទ្ធសាសនាហើយ កូននោះនឹងក្លាយទៅជាសត្រូវនឹងខ្លួនជាម្តាយឪពុកវិញ ក៏សឹងតែមានដែរ ៗ

មានម្តាយឪពុកខ្លះ មានកិត្តិស័ព្ទកេរ្តិ៍ឈ្មោះល្បីខ្ចរទៅក្នុងប្រទេស ទាំងអ្នកដទៃក៏ទទួលស្គាល់ដោយច្រើនថា ជាអ្នកពុទ្ធសាសនិកមួយរូប, ជា

អ្នកមានសទ្ធា ជះថ្លាឧស្សាហ៍ធ្វើបុណ្យ ឲ្យទាន រក្សាសីល ចេញចូលវត្ត អាកមជាប្រក្រតីពុំសូវដែលលស់ខានក្នុងកាលសម័យដែលមានបុណ្យទាន អម្តងៗ ប៉ុន្តែចំណែកខាងកូនវិញ បែបសោះអង្គើយនឹងការកុសល មិនមាន សទ្ធាជឿបុណ្យ-បាបអ្វីសោះ, ម្តាយឪពុក ទោះបីដឹងថាកូនដូច្នោះក៏ដោយ នៅតែមិនរវល់អើពើប្រៀនប្រដៅដឹកនាំកូនឲ្យមានសទ្ធាដូចខ្លួន,ដល់វេលា ណាខ្លួនជាម្តាយឪពុកអស់ជីវិតស្លាប់ទៅ កូនទាំងអស់ក៏ក្លាយទៅជាមិច្ឆា-ទិដ្ឋិ ប្រឆាំងនឹងពុទ្ធសាសនា មិនជឿកម្ម ផលទៅវិញ យ៉ាងនេះក៏មាន ៗ

ម្តាយឪពុកនីមួយ ៗ ដែលជានាយកលើកូន គួរយកតម្រាប់តាម អនាថបិណ្ឌិកសេដ្ឋី ដែលជាឧបាសក-ទាយក មានកេរ្តិ៍ឈ្មោះល្បីល្បាញ ក្នុងពុទ្ធសាសនា ។ អនាថបិណ្ឌិកសេដ្ឋី មានកូនមួយឈ្មោះ កាលៈ, កូននោះគេគល់ទៅជាមិច្ឆាទិដ្ឋិ មិនចង់ទៅកាន់សំណាក់ព្រះពុទ្ធ មិនចង់ជួប នឹងភិក្ខុសង្ឃដែលមកកាន់ផ្ទះខ្លួន, មិនចង់ស្តាប់ធម៌,មិនចង់ធ្វើកិច្ចបម្រើភិក្ខុ-សង្ឃ ទោះបីឪពុកនិយាយប្រដៅថា កុំឲ្យធ្វើយ៉ាងនេះ ក៏នៅតែមិនស្តាប់ ៗ សេដ្ឋីឪពុកគិតថា កូននេះ បើនៅតែប្រកាន់ទិដ្ឋិវង់ទទឹងបែបនេះ មុខតែនឹង ធ្លាក់ទៅកាន់អបាយភូមិពុំខាន បើអាត្មាអញកំពុងមានជីវិតរស់នៅឡើយ ហើយបណ្តោយឲ្យកូនធ្លាក់ទៅនរក ពីព្រោះតែមិច្ឆាទិដ្ឋិរបស់វានោះ ជា ការពុំសមគួរដល់អាត្មាអញសោះ, ធម្មតាមនុស្សក្នុងលោកនេះ គ្មាន មនុស្សណាមួយ ដែលថាមិនត្រូវការចង់បានទ្រព្យនោះពុំមានសោះឡើយ

គឺសុទ្ធសឹងតែចង់បានដូចគ្នាទាំងអស់, បើដូច្នេះ អាត្មាអញនឹងយកទ្រព្យទៅល្បួងទាក់ទាឲ្យតែខានបាន ទើបនិយាយទៅកកាលៈថា នែកាលៈ! កូនឯង ទៅវត្តទទួលរក្សាឧបោសថសីលរួចហើយស្តាប់ធម៌ទៀត លុះស្តាប់ធម៌រួចហើយ សឹមមកផ្ទះវិញចុះ, អញនឹងឲ្យឯងមួយរយកហាបណៈ ។ កាលៈ សួរបញ្ជាក់អស់វារៈ ៣ ដងថា ឪពុកប្រាកដជាឲ្យខ្ញុំមែនឬ? បើមែន ទើបបានខ្ញុំទៅ ។ អើ! អញនឹងឲ្យឯងប្រាកដមែន ។ កាលៈ លុះទទួលពាក្យប្តេជ្ញាជាមួយនឹងឪពុកខ្លួនហើយ ទើបទៅវត្ត ទទួលឧបោ-សថសីលរួចហើយ មិនព្រមនៅស្តាប់ធម៌សោះ ក៏គេចទៅសម្ងំដេកត្រង់ទីណាមួយដែលគួរសប្បាយអស់មួយយប់ ។ លុះដល់ព្រលឹមឡើងក៏ត្រឡប់មកផ្ទះវិញ ។ សេដ្ឋីឪពុក ឃើញកូនត្រឡប់មកដល់ផ្ទះវិញ ក៏ស្រែកប្រាប់ទៅពួកស្រី បរិចារិកា ( ស្ត្រីអ្នកបម្រើ ) ថា នែវ៉ុយ! កូនអញទើបមកពីរក្សាឧបោសថ ស្តាប់ធម៌, ឯងរាល់គ្នាចូររៀបចំយកចំណីចំ-ណុកមានបបរជាដើមមកឲ្យកូនអញបរិភោគឆាប់ ៗ ។ កាលៈប្រកែកមិនព្រមទទួលអាហារ ដោយគំនិតថា បើមិនបានកហាបណៈមួយរយទេអញនឹងមិនបរិភោគ ។ សេដ្ឋី អត់ទ្រាំពុំបាន ក៏យកកហាបណៈមួយរយឲ្យទៅកាលៈ ។ បានកហាបណៈនោះហើយ ទើបព្រមបរិភោគអាហារ ។ ថ្ងៃក្រោយ សេដ្ឋីនិយាយនឹងកាលៈទៀតថា នែ កាលៈ, កូនឯងទៅវត្តទៀត, ម្តងនេះអញឲ្យកូនឯងមួយពាន់កហាបណៈ ប៉ុន្តែកូនឯងទៅដល់

អង្គុយចំពីខាងមុខព្រះ, ផ្ទៀងស្តាប់ធម៌ព្រះអង្គសំដែង, បើមិនបានច្រើនទេ, កំណត់ឲ្យចាំត្រឹមតែមួយបទក៏បាន, ដល់ត្រឡប់មកវិញ អញឲ្យកូនឯងមួយពាន់កហាបណៈភ្លាម ។ ដោយហេតុតែចង់បានកហាបណៈមួយពាន់ កាលៈ ក៏ព្រមទៅវត្ត, លុះដល់ហើយទៅអង្គុយពីខាងមុខព្រះ គិតថាអញស្តាប់កំណត់ឲ្យចាំធម៌តែមួយបទហើយរត់ទៅវិញ ។ ព្រះបរមសាស្តាទ្រង់សំដែងធម៌ធ្វើមិនឲ្យកាលៈនោះកំណត់ចាំបានសោះ, កាលៈនេះតែខំប្រឹងផ្ទៀងស្តាប់ នូវបទធម៌ខាងដើមក៏កំណត់ចាំមិនបាន បទកណ្តាលក៏នៅតែកំណត់មិនបាន នេះតែបញ្ចូនចិត្តដេញតាមក្រសែធម៌ខ្ពស់ទៅ ៗ អាស្រ័យដោយមានឧបនិស្ស័យពីអតីតជាតិផង ក៏បានសម្រេចសោតាបត្តិផល ។ លុះដល់វេលាព្រឹកឡើង កាលៈ ត្រឡប់មកផ្ទះវិញ, សេដ្ឋីក្រឡេកឃើញ កាលៈ មានអាការប្លែក នឹកគិតថា កូនអញប្រហែលជាបានលុះនូវគុណវិសេសណាមួយហើយ ក៏យកកហាបណៈមួយពាន់ឲ្យកាលៈ ៗ មិនទទួលយកព្រោះបានឃើញធម៌ជាក់ច្បាស់ហើយ ។

រឿងដូចបានពោលមកនេះ បើអនាថបិណ្ឌិកសេដ្ឋីជាឪពុក មិនរកឧបាយប្រៀនប្រដៅ ណែនាំកូនឲ្យទៅសេពគប់នឹងព្រះពុទ្ធសាសនាទេ កូនឈ្មោះកាលៈនោះ នឹងក្លាយទៅជាមិច្ឆាទិដ្ឋិពេញទី ហើយជាហេតុនាំឲ្យខូចជាតិកំណើតផង នាំឲ្យខូចកេរ្តិ៍ឈ្មោះវង្សត្រកូលផង នាំឲ្យខូចកិត្តិយសនៃខ្លួនជាម្តាយឪពុក ដែលមាននាមឈ្មោះថា ជាពុទ្ធសាសនិក

ហើយពុំគួរទឹងបណ្ដែតបណ្ដោយកូនឲ្យជាដូច្នោះផង ព្រោះហេតុនោះ ម្ដាយឪពុក ដែលបានសង្គ្រោះទំនុកបម្រុងកូន ខាងប្រយោជន៍បច្ចុប្បន្ន ហើយ គួរតែសង្គ្រោះទំនុកបម្រុងកូនឲ្យបានជឿគោរពពុទ្ធសាសនា ដាំង ឲ្យបានប្រយោជន៍ខាងបរលោកផង ទើបសមនឹងឋានៈនៃខ្លួនជាមាតាបិតា ហើយស្របនឹងពុទ្ធដីកាដែលថា មាតាបិតាត្រូវសង្គ្រោះកូនដោយឋាន ៥ យ៉ាងផងគឺ ១- បាបនិវារណៈ: ការហាមប្រាមមិនឲ្យធ្វើអំពើអាក្រក់ ឬអំពើដែលឥតប្រយោជន៍, ២. កល្យាណនិវេសនៈ: ការដឹកនាំកូនឲ្យតាំងនៅក្នុងអំពើល្អ ឬអំពើដែលមានប្រយោជន៍, ៣- សិប្ប-សិក្ខាបនៈ: ការដឹកនាំកូនឲ្យសិក្សាសិប្បសាស្ត្រ គឺវិជ្ជាខាងផ្លូវលោក និងខាងផ្លូវធម៌, ៤- បដិរូបទារសំយោជនៈ: ការរេះរៀបចំទុកដាក់កូនឲ្យមានគូស្រករ សមរម្យទៅតាមជាតិគោត្រកុល និងធនធានរបស់ខ្លួន, ៥- ទាយជ្ជទានៈ: ការរេះលៃលកចែកទ្រព្យសម្បត្តិឲ្យដល់កូន ក្នុងកាលសម័យដែលគួរចែកឲ្យ ។

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាន់ ខាត់ រៀបរៀង*

**អនុកាលម៑** ក្រ.វិ. ដោយគួរតាមកាល ។

**អនុកីណ៌** គុ. ដែលដេរដាសរឿយៗ ។

**អនុកីត៌ន** នបុំ. កិរិយាកំរើក, កិរិយាតែងតាំង ។

**អនុកីត៌្យ** គុ. ដែលគប្បីរៀបរាប់ ។

**អនុកូជ៑** ធាតុ. យាសយំ, រ៉ៗ ។

**អនុកូល** គុ. ដែលអនុកូ , ដែលធ្វើទៅតាមគួរ ។ -តា ស្ត្រី ភាវៈនៃ កិរិយាអនុកូល, សេចក្ដីព្រមព្រៀង ។ -ត្វ នបុំ. ភាវៈនៃ កិរិយាអនុកូល ។ -ការិន៑ គុ. ដែលធ្វើនូវអនុកូល ។ -ជ បុំ. ឈើដុះលើឆ្នេរ ។ -នាយក នាយក ឬ ប្ដីអនុកូល ។

-វាយុ បុំ ខ្យល់អនុកូល ឬ ខ្យល់បក់ស្រួល ។

អនុកូលោក្ត នបុំ ពហុ. សំដីនិយាយតាមឃើញ ។

អនុកូលិត គុ. ដែលទទួលរាក់ទាក់ ។

អនុកប្ប ធាតុ. ធ្វើតាម, ធ្វើគ្រាប់, ធ្វើរឿយ ៗ ។

អនុកប្បត៑ ធាតុ. បំផ្លាញរឿយ ៗ ។

អនុកប្បតិ ស្ត្រី. កិរិយាធ្វើតាម, កិរិយាធ្វើគ្រាប់ ។

អនុកប្បត្យ គុ. ដែលគប្បីធ្វើតាម, ដែលគប្បីធ្វើគ្រាប់ ។

អនុកប្បសិ៑ ធាតុ. បៀតបៀន, ញាំញី ។

អនុកប្បថ៑ ធាតុ. រួញ ។

អនុកប្បប៑ ធាតុ. តាមបែប, តាមវិធី ។

អនុកាល្ប បុំ. សេចក្តីអនុញ្ញាត ។

អនុកាល្បិត គុ ដែលធ្វើតាម ។

អនុកប្បិ ស្ត្រី. សេចក្តីយល់ព្រម ។

អនុក្ត គុ. ដែលមិនពោល, ដែលមិននិយាយ

អនុក្តិ ស្ត្រី. កិរិយាមិនពោល។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាតបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ
យូរ-អ៊ុន

ប៉ិស៊ុកឃាត់ទាស់ថា កាលដែលទឹងលើកទ័ពទៅធ្វើសង្គ្រាម ជាជ័យមង្គលធំណាស់ ដែលទឹងមកសម្លាប់មនុស្សនាយទាហានដូច្នេះ មិនត្រូវសោះ ទឹងអស់ឫក្សល្អទៅ គួនអ៊ុកស្លាប់តែថានៅមិនអស់កំហឹងនោះ ស្រែកគំហកឲ្យចៅស៊ូយិន ទឹង ប៉ិហាងថា បើយើងមិនឈ្នះយល់ដល់មុខប៉ិស៊ុទេ យើងក៏ត្រូវតែសម្លាប់កាត់ក្បាលខ្លួនទាំង ២ វេលានេះ ទើបបង្គាប់ទាហានឲ្យចាប់ខ្លួន ចៅស៊ូយិន ទឹងប៉ិហាងទៅវាយម្នាក់ ៤០ រំពាត់ ហើយដកហូតដំណែងចេញពីនាយទាហានទ័ពមុខ ឲ្យប៉ិហាងទៅឈរស្រុកឡាំកុន ឲ្យចៅស៊ូយិនទៅឈរនៅស្រុកកាំងអាន ហើយដាក់កំហិតថា វេលានេះ យើងលើកទោសទោលម្តង បើកាលណាយើងទៅធ្វើសង្គ្រាមមានជ័យជំនះឈ្នះត្រឡប់មកវិញ ហើយខ្លួននៅធ្វើខុសម្តងទៀត យើងនឹងត្រូវប្រហារជីវិតឥតត្រាប្រណីឡើយ ប៉ិហាងទឹងចៅស៊ូយិន ក៏បានសេចក្តីអាប់យសខ្មាសទាហានទាំងពួងពេកណាស់

ដោយសេចក្តីខ្លាច អំណាចហើយក៏ទៅតាមពាក្យគួនអ៊ីបង្គាប់ ។

គួនអ៊ីក៏តាំងឲ្យលៀវហ៊ួជាមេទ័ពមុខ ឲ្យគួនបេងជាមេទ័ពក្រោយ ឲ្យម៉ាលៀងនឹងអ៊ុំចៀជាទីប្រឹក្សា ឯគួនអ៊ីជាមេទ័ពធំរៀបប្រុងប្រៀបទាហានទុកព្រមហើយ លុះបានឫក្សល្អក៏លើកទ័ពទៅ ក្នុងខណៈនោះគួនអ៊ីក៏និយាយនឹងង៉ីប៉ាំនជាកូនង៉ីហួថា អ្នកឯងមានគុណ កាលយើងលើកទ័ពចេញពីបន្ទាយចូចូ វេលានោះ អ្នកបានជួយអាយុជីវិតយើងឲ្យរួចម្តង យើងក៏គិតនឹករឭកដល់គុណនោះ ឥឡូវនេះយើងនឹងលើកទ័ពទៅហើយ អ្នកចូលទៅនៅស្រុកសៃឈួនជាមួយនឹងប៊ីស៊ីប៊ុះ បើទៅដល់ហើយឲ្យសុំនៅធ្វើរាជការនឹងព្រះចៅហាន់ទុងតេទៅ ខណៈនោះង៉ីប៉ាំន ក៏ទៅជាមួយនឹងប៊ីស៊ី ដល់ទៅស្រុកសៃឈួនហើយ ក៏សុំចូលធ្វើរាជការនឹងព្រះចៅឡៀតី ។

លុះគួនអ៊ីរៀបពលីការបូជាទេវតាដែលរក្សាទង់ជ័យហើយ ក៏ចូលទៅដេក ក្នុងយប់នោះមានសុបិននិមិត្តឃើញថា មានជ្រូកខ្មៅធំទំហំប៉ុនគោ ចូលមកខាំជើងគួនអ៊ីយកទៅ គួនអ៊ីក៏ហូតក្រប៊ីកាប់ជ្រូកនោះ ជ្រូកក៏សូន្យបាត់ទៅ គួនអ៊ីតក់ស្លុតភិតភ័យភ្ញាក់ឡើង ហើយឲ្យគួនបេងជាកូនចិញ្ចឹមចូលមកពណ៌នានិមិត្តនោះស្តាប់ គួនបេងក៏ទំនាយថា ដែលមានជ្រូកមកខាំជើងលោកយកទៅនោះ មិនមែនអ្វីដទៃឆ្ងាយទេ គឺមករកលោក នឹងបានល្អជាទីខ្ពស់យសស័ក្តិប្រសើរលើសអស់មនុស្សទាំងពួង លុះព្រឹកឡើងគួនអ៊ី ក៏ឲ្យហៅនាយទាហានទាំងអស់ចូលមក

ព្រមគ្នា ហើយគួនអ៊ូពណ៌នាយល់សប្តិនោះឲ្យស្តាប់ នាយទាហានទាំងពួងនាំគ្នា ទំនាយថាអាក្រក់ខ្លះ ល្អខ្លះ គួនអ៊ូថា អាយុយើងដល់ហាសិបប្លាយឆ្នាំហើយ ទោះបីទីងជាប្រការម្តេចក៏តាមការចុះ ឯកើត មកជាប្រុសនេះ មិនត្រូវខ្លាចសេចក៏ស្លាប់នោះទេ ។

ខណៈនោះ ស្រាប់តែមានបម្រើកាន់សំបុត្រស្រុកសៃឈួន មកដល់គួនអ៊ូ ថែមលើសំបុត្រមុនទៀតសេចក្តីថា ព្រះចៅឡៅពីទ្រង់តាំងគួនអ៊ូជានាយទាហានឯកខាងមុខ កាន់អាជ្ញាសិទ្ធិជាធំលើខេត្តទាំង ៩ ដែលឡើងស្តាប់បង្គាប់ស្រុកកេងជីវ គួនអ៊ូ ក៏ទទួលតាមព្រះតម្រាស់ ទាហានទាំងពួងទើបព្រមគ្នាដំកបថា ដែលលោកយល់សប្តិនោះ គឺបានដល់ព្រះតម្រាសនេះឯងហើយ គួនអ៊ូ ក៏សោមនស្សណាស់ ទើបបង្គាប់ឲ្យលើកកងទ័ពចេញទៅតាមផ្លូវ តម្រង់ទៅស្រុកសុងយ៉ុង ។

ឯចោយិន ដែលទៅក្រស្រុកអួនសៀនោះ លុះដឹងថា គួនអ៊ូលើកទ័ពទៅវាយស្រុកសុងយ៉ុង ក៏ឲ្យទឹកស្ងប់ស្ងែងក្រែងខ្លាចណាស់ ទើបប្រមូលទាហានឲ្យប្រុងប្រយ័ត្នការក្សាបន្ទាយ ទីងស្រុកទុកជាមួនម៉ាំពុំធ្វេសប្រហែស ឯគេកង្ហួន ដែលជាទាហានរង ក៏ដំកបចោយិនថា ព្រះចៅរ៉ុ អងមានព្រះតម្រាស់ឲ្យលោក ទៅបបួលស៊ុនគួនឲ្យលើកទ័ពស្រុកកាំងតាំងមកព្រួតបញ្ចូលគ្នា ទៅវាយយកស្រុកកេងជីវឲ្យបាន ឥឡូវគួនអ៊ូ លើកទ័ពមកវាយយកស្រុកយើង បីដូចជាយកដីវិតមកឲ្យយើងហើយ យើងមិនត្រូវគោតញញើតសោះ គួរទីងលើកទ័ពចេញទៅតស៊ូទីងគួនអ៊ូចុះ ។

ប៊ួនថុន ជាទីប្រឹក្សា លុះបានឮគេគង្ហួននិយាយដូច្នោះ ក៏ឃាត់ហាម
ហោយិនថា ឯគួនអ៊ូនោះជាមនុស្សមានកម្លាំង នឹងសតិបញ្ញាចេះពិចារ-
ណាគិតជាច្រើនណាស់ ដែលលោកនឹងតស៊ូនឹងគេនោះ មុខជាពិបាក
ណាស់ យើងត្រូវតែរង់រក្សា ស្រុកទុកឲ្យមាំពីខាងក្នុងចុះ ហៃហ៊ួ ហៃហ៊ួ-
ផុនថា ប៊ុនថុននេះគ្រាន់តែជាមនុស្សចេះសំបុត្រម្យ៉ាង នឹងបានដឹងក្នុងកិច្ច
ការសង្គ្រាមគ្នានោះ អស់យើងសុទ្ធជាជាតិតាហានមិនគួរមកមានចិត្ត
គិតខ្លាចសេចក្តីស្លាប់នោះឡើយ ខាងលើកមកពីផ្លូវឆ្ងាយ តាហានទាំង-
ឡាយ ក៏កំពុងហត់នឿយមិនទាន់បាត់ ទោះនឹងខំគិតយ៉ាងណាក៏មិនឈ្នះ
យើងដែរ ហោយិនបានឮដូច្នោះ ក៏យល់ឃើញត្រូវ ទើបប្រើប៊ួនថុនឲ្យ
ចូងទៅរក្សាស្រុកអ៊ួនសៀ ឯហោយិនក៏លើកពលយោធាចេញទៅច្បាំង
នឹងគួនអ៊ូ ។

គួនអ៊ូនោះ លុះឃើញហោយិនលើកទ័ពមក ក៏បង្គាប់គួនបេងនឹង
លៀវហ៊ូថា អ្នកឯងត្រូវចេញទៅច្បាំងនឹងហោយិន ហើយត្រូវធ្វើជាចាក់ទ័ព
ត្រឡប់រត់ថយមកចុះ នោះគួនបេងនិងលៀវហ៊ួទទួលប្រសាសន៍ហើយ
លើកចេញទៅ ឯលៀវហ៊ួជិះសេះចេញទៅមុខ ហោយិនក៏ឲ្យគេគង្ហួនជិះ
សេះចេញច្បាំងគ្នា នឹងក្បួនទ័ពសេះមិនទាន់បាន ១ ក្លែង លៀវហ៊ួក៏ចំ
ផាយសេះរត់ទៅតាំងបន្ទាយពីឆ្ងាយប្រមាណ ២០០ សិន (៨គី-) លុះ
វេលាព្រឹក គួនបេង និង លៀវហ៊ួក៏លើកកងទ័ពចេញទៅ ហោយិន និង
ហៃហ៊ួផុន, គេគង្ហួន ក៏លើកតាហានចេញច្បាំង ។ (នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

(ត)

លោក ឌ. ពាម ស្រាវជ្រាវ និង រៀបរៀង

គ្រានោះ វិរូបក្ខទណ្ឌបានស្តាប់ហើយ ក៏សែនក្រេវក្រោធប្រទៀតខឹងប្រឹងខាំមាត់ក្រហឹមហើយឆ្លើយតបទៅវិញថា នែឯងកុំអាលមានពាក្យអាងអួតអំនួតបេះស្តាថា មានមហិទ្ធិឫទ្ធិខ្លាំងចង់ច្បាំងនឹងអញ ។ នេះមើលទៅខ្លួនឯងនេះពស្មើរ នឹងដៃអញណាស់ ។ កុំចង់មកប៉ះសង្គ្រាគេដដៃ អញមើលក្រែងក្ស័យស្លាប់អាសា ត្បិតប្រពន្ធឯងល្អណាស់សា ដូចទេពកញ្ញាសួគ៌ស្ថាន ក្រែងបានប្រពន្ធនោះមកអញពុំលែងឡើយ ថាតែម៉្មោះហើយ អសុរក៏សម្តែងឫទ្ធិគ្រវីដំបង ស្ទុះចូលទៅតកាំងច្បាំងលើកដរថា ។

កាលនោះ ព្រះបាទទសរថ្ឋនាថាធិបតីចក្រី ទ្រង់កាន់ធ្នូសិល្បជ័យ ។ ក្សូរន័យទ្រង់ពប់រងកាល់ការរក្សាអង្គ លុះទ្រង់តយុទ្ធយូរបន្តិចទៅ អង្គព្រះចមទៅ ក៏លើកព្រះបាទាឡើងជាន់ស្មាអសុរី អសុរក៏ឥតបីថយរុញករត់ដោះសោះឡើយ ហើយព្រះអង្គទ្រង់កាប់នឹងព្រះខ័នពេជ្រ ត្រូវកាយអសុរី ក៏ធ្លាក់ពីពដរថា ព្រះអង្គក៏ទៀនទេពជាពាជី ឲ្យខំផ្លោះហោះលឿនទៅឲ្យបានទាន់ ស្តេចក៏កាន់ព្រះខ័នពេជ្រគ្រវីគ្រវ៉ាសប៉ើងនឹងប្រហារជីវិត ។

កាលនោះ ប្រទូតទណ្ឌអសុរាបុទ្ធិខឹងពិរោធក្រេវក្រោធក្រៃ ក៏វាយបាច់ដំបងពេជ្រតោលទៅដោយនូវឫទ្ធី ក៏លាន់ឮគឹកកងកក្រើកអំពើកទាំងពីកពណាទិ រឹប្តីអំណាចដំបងពេជ្រនោះ ក៏បណ្តាលឆេះជាភ្លើងពិសអសុរ ។

កាលនោះ ព្រះបាទទធរដ្ឋបេស្តានោះ លុះឃើញភ្លើងឫទ្ធិដំបងពេជ្រអសុរ ឆេះពេលពលក្តៅដូចកំដៅព្រះសុរិយា ព្រះអង្គក៏ប្រវាចាប់ព្រះខ័នចោលទៅ ក៏លាន់ឮសន្ធឹកគ្រឹកគ្រេងដូចខ្យល់ព្យុះ ក៏បណ្តាលភ្លៀងធ្លាក់ចុះមកលត់ភ្លើងឫទ្ធិអំណាច ដំបងអសុរ ហើយព្រះខ័នពេជ្រថ្វា ក៏បំផ្លាញដំបងរបស់អសុរី វិនាសអន្តរាយខ្ទេចខ្ទី រីព្រះខ័នពេជ្រនោះ ក៏វិលមកព្រះអង្គវិញ ហាក់ដូចមានវិញ្ញាណហោង ។

កាលនោះ វិប្រទូតទណ្ឌឫទ្ធិច្បង លុះឃើញដំបងអាត្មាបាក់បែកខ្ទេចខ្ទីជាធូលីហើយ ពុំលង់ឡើយ ក៏ចាប់យកសរមកលើផ្ទង់ដៃមទៀតទៅសន្ធោសន្ធៅសែនសន្ធឹកសន្ធាប់ អត្ថអស់មេឃានភាល័យ រឹឫទ្ធិសរជ័យនោះ ក៏ទៅត្រូវភ្លៅព្រះពជរថដាច់ ហើយសរនោះចំពោះវិលវង់ជុំវិញខ្លួនព្រះអង្គ ។

គ្រានោះ រីធោមយង់កែកេសីនោះ លុះឃើញភ្លៅពជរថកែវសុរិយ-កាន្ត ត្រូវទីងសរជ័យដាច់ដូច្នោះ នាងចំពោះតាំងសច្ចាអធិដ្ឋានថា តេជះព្រះសម្ភារ ខ្ញុំស្លូតត្រង់នឹងព្រះស្វាមីខ្ញុំ សូមសុំខ្ញុំយកម្រាមចង្អុលដៃខ្ញុំសឹកធ្វើជាភ្លៅពជរថនេះឲ្យបានរឹង កុំឲ្យអន្តរាយដល់កាយជីវី ។ នារីនាងផ្សងស្រេចហើយ ក៏យកចង្អុលម្រាមដៃសឹកធ្វើតាងភ្លៅរទេះពជរថមួយរំពេចហោង ហេតុតែតេជះដែលនាងផ្សងសច្ចា ម្រាមហត្ថានាងនោះ ក៏រឹងដូចដែកជាម្គន ។

កាលនោះ ព្រះបាទទធរដ្ឋច្បាស់ច្បងនោះ លុះឃើញសរអសុរកវៃថ្ងៃ មកដូច្នោះ ព្រះអង្គនោះ ក៏មិនដឹងសោះឡើយ ជាត្រូវក្បោកដរថបាក់ដាច់ ក៏ទេ ទើបព្រះពន្សពុទ្ធ ក៏ចាប់យកព្រះខ័នពេជ្រចោលកំទេចសរសិល្ប ផ្ដិលផ្ដាច់រំលីតាំងជាវីអសុរីផង ។ លុះព្រះទ្រង់បុទ្ធីច្បងចោលព្រះខ័ន ពេជ្រទៅត្រូវសរសិទ្ធ របស់អសុរវិនាសអន្តរាយខ្ទេចខ្ទី ហើយព្រះខ័ន ពេជ្រមណីនោះ ក៏ស្ទុះទៅផ្ដិលផ្ដាច់កាប់ដាច់ក្បាលអសុរ ធ្លាក់ចុះដល់ ក្រឡាមហាប្រថពីជាវីក្ស័យហោង ។ លុះស្ដេចប្រហារជីវិតអសុរីយេង់យ្វង ហើយ ព្រះអង្គទ្រង់បែរមៀងមើលឆ្វេងស្ដាំទៅ ក៏ឃើញព្រះមហេសី សោភា នាងយកចង្អុលហត្ថាលូកសឹកធ្វើក្បោកដរថជ័យ ទើបភូវន័យស្ដេច ទ្រង់ត្រាស់សួរទៅថា នៃនាងឆោមឆ្នៃដូចម្ដេចហ៎ះ រាជរថនោះ តើមានហេតុ កេទអ្វី ទើបបានព្រះនាងធ្វើដូច្នេះ ។ ទើបនាងកែកេសីក្រាបទូលតប ស្នងព្រះរាជាថា កាលព្រះអង្គកំពុងច្បាំងនឹងអសុរី រវៃថ្ងៃសរជ័យមកត្រូវ ក្បោកដរថបាក់ដាច់ទៅ ខ្ញុំម្ចាស់ភ័យនឹងព្រះចមទៅចាញ់បុទ្ធីអសុរ ខ្ញុំ ម្ចាស់គិតថាប្ដូរជីវិតសូវស្លាប់ នឹងព្រះអង្គជាព្រះស្វាមី ទើបខ្ញុំម្ចាស់យកម្រាម ដៃលូកធ្វើជាក្បៅជំនួសក្បោកដរថ ទើបអង្គព្រះចមមកុដ ទ្រង់ប្រហារជីវិត អសុរីមានជ័យជំនះឈ្នះរហោង ។

កាលនោះ អង្គព្រះបាទទធរដ្ឋច្បាស់ច្បងធិបតី បានស្ដាប់សវណី មហេសីទូលដូច្នោះ ទើបស្ដេចបំពោះទ្រង់សរសើរថា អនុជអ្នកមានចិន្តា

ស្នេហាស្វាមីភក្តិនឹងបងមែនពិត គឺរួមជីវិតឲ្យនឹងជេដ្ឋា ក្នុងខណៈនេះណា នាងមានគុណនឹងបងណាស់ ថាបើព្រះនាងប្រាថ្នារបស់អ្វី ៗ ក្តី ឬប្រិម-ប្រិយចង់ប្រាថ្នាពេជសម្បត្តិបង ៗ ក៏ឲ្យនាង តាមក្តីប្រាថ្នារបស់នាង ។ ស្តេចត្រាស់ក្សាន្តហើយ ព្រះអង្គក៏ដឹកដៃនាងយាងចុះទៅប្រពាតសួនឧទ្យានកែវមណីរ័តន៍ ។

កាលនោះ រីអង្គព្រះសហស្សន័យន៍ចមត្រៃត្រឹង្ស នឹងអស់ហ្វូងទេពកញ្ញាទាំងសុភសុរិន្ទទេពនោះ លុះបានឃើញរូបព្រះចក្រវត្តិ ប្រហារជីវិតអសុរយក្សហើយ ពុំលង់ឡើយក៏នាំគ្នាថ្វាយសព្ទសាធុការកងរំពងឮលាន់ឥតកកងព្រម ៗ គ្នា ទេវាខ្លះក៏កាន់មាលីមាស យាងយាសបាកពិពិមានមាសមកហែតាម សម្តេចព្រះឥន្ទ្រាមកកាន់លតាវនឧទ្យាន ។ លុះបានមកដល់ហើយ ក៏បាចសាចមាលាមន្ទារបុស្សទេវពជនោះ ក៏ផ្ទុំស័ព្ទឮលាន់រំពង ហើយឲ្យទេវតាជងរេរាំរបាំថ្វាយលាយនឹងហ្វូងទេពកញ្ញាជាទូរ្យារិកអធឹកតាមសប្បាយ ។

កាលនោះ ស្រីទេពកញ្ញាទាំងឡាយគ្រប់វិមាន លុះបានស្តាប់ទេវបញ្ញាហើយ ក៏ត្រេកអរសោមនស្សា ទើបនាំគ្នាច្រៀងរាំរបាំថ្វាយកែក្រាយញ៉ែងញ៉ែងញ៉ាំញ៉ើដើរចាក់ក្បាច់ ក្រឡាប់ក្រឡះលេងលូកហត្ថបាច់បង់ទ្រង់ញញឹមញញែមថែមថៃរថើបដោយស្រើបស្រាល គ្រអាលអរសោមនស្សាសែនមហាសប្បាយ ថ្វាយព្រះបាទទេធរជ្ជ ហើយក៏ថ្វាយជ័យសិរីសួស្តិមង្គលព្រមគ្នាហោង ។

គ្រានោះ អង្គសក្ករិន្ទ្ររៀងឫទ្ធីច្បងជាធំនោះ លុះពាំថ្វាយស្រេច ហើយ ពុំលង់ឡើយទើបមានព្រះឱង្ការសរសើរបារមីសម្តេចព្រះចក្រាថា ព្រះអង្គជាវង្សព្រះនរាយណ៍ ចក្រពង្សមិនបង់ជាតិត្រកូលបណ្ដូលកំពូល គេសជាមគ្គុទេសកវិសេសវិសាល ដែលអង្គព្រះកូបាលស្តេចទ្រង់មកជួយ ប្រហារជីវិតជីវ័នក្នុងជាន់នេះ វិសេសរំលត់ទុក្ខទៅលោកបានជ្រកកោន ពឹងពោធិសម្ភារជាបរមសុខ ព្រះអង្គនឹងល្បីទៅមុខរន្ទឺខ្ទរខ្ចាយសាយសព្វ គ្រប់ទិសា សូមឲ្យអង្គព្រះចក្រាស្តេចទ្រង់ចម្រើនព្រះជន្មវស្សាទីឃាយុ យសសក្តិមង្គលាជយាតិរេក ជាឯកអគ្គមហាក្សត្រខត្តិយាវង្ស ឲ្យទ្រង់មាន បុញ្ញានុភាពបង្ក្រាបប្រាប់ពួកបច្ចាមិត្រ កុំឲ្យមកតឫទ្ធិនឹងព្រះអង្គបានឡើយ ។ ត្រាស់ហើយព្រះឥន្ទ្រប្រាប់ទៅព្រះមាតុលីទេវបុត្រថា ឲ្យបររាជរថជូនចុះ ទៅឯនគរព្រះអង្គវិញហោង ។ ហើយក៏ថ្វាយរាជរថនោះទុកបម្រុង សម្រាប់រាជធានី ។

គ្រានោះ រីមាតុលីទេវបុត្រ បានស្តាប់ទេវបញ្ជាត្រាស់បង្គាប់ប្រាប់ប្រើ អាត្មាដូច្នោះហើយ ក៏ក្រាបថ្វាយបង្គំលាថយមក ក៏តាំងសម្តែងឫទ្ធិនិម្មិត នៅរាជរថដាក់ដូចដើមស្រេចហើយ ក៏ត្រៀមចាំព្រះបាទទធរដ្ឋាធិបតី ។ ទើបព្រះបាទទធរដ្ឋស្តេចក៏មានព្រះឱង្ការស្តីនឹងព្រះឥន្ទ្រថា សូមទ្រង់គង់ នៅឲ្យក្សេមក្សាន្តសម្រាន្តឫទ្ធិ ខ្ញុំលាព្រះកោសិទ្ធិហើយ ត្រាស់ហើយ

ព្រះអង្គក៏លើកដៃអញ្ជលីនូវព្រះទេវីទូ ស្រេចហើយកុមិន្ទុក៏យាងមកគង់ព្រះពជររថកែវមណីរង្សី ។

កាលនោះ ព្រះមាតុលាទេវបុត្រនោះ ក៏ទ្រង់បរពជររថហោះត្រង់តម្រង់បុរីសិរីអយុធ្យាវិញហោង ។

ទឹងសម្ដែងពីមហាឥសីសៃយកាល័យគោដ្ឋ ជាកូនឥសីសិង្គមុនីអម្រឹតជាមាតា តែបិតានោះនៅមិនទាន់ក្ស័យ ក៏បានឈានលោកិយក្សា-ហានវិសេសប្រសើរ ធ្វើអាស្រមនៅអាស្រ័យព្រៃសាលវ័នអរញ្ញ ក្នុងដែនសីមាភាពពេជស្ដាន គាត់បានពរពីព្រះសម្មញាណកៃលាស ក៏តាំងតបៈកិច្ចការឈានជាខ្ជាប់ខ្ជួនមុនមាំសម្រួមកាយ ខ្វល់ខ្វាយចម្រើនមេត្តាជានិច្ចនិរន្តរតបន្តិចទៅ ក៏បណ្ដាលភ្លៀងនោះរាំង ៣ ឆ្នាំ ។

កាលនោះ វ៉ព្រះបាទពេជស្ដាន តាំងតែពីគ្មានភ្លៀងធ្លាក់មក ត្រូវផែនដីតែ១ដំណក់សោះឡើយ ហើយព្រះអង្គក៏ទ្រង់ព្រួយព្រះទ័យភ័យគិតគិតវិតក្កតុក្កលក្ដៅសៅហ្មងក្នុងវិញ្ញាណ សញ្ញារាំងពួកសេនាអាមាត្យមុខមន្ត្រីប្រជាជនបានសេចក្ដីអត់ឃ្លានតែគ្រប់ ៗ គ្នា បង្កើតជាទុរភិក្សអន្តរកប្បស្លាប់ខ្លះ រស់ខ្លះ សែនវេទនាណាស់ទឹងអត់ឃ្លានគ្មានវត្ថុទឹងស៊ីចុកចម្អែតកាយអាត្មា ទើបស្ដេចមានឧង្ការទៅទឹងមហាអាមាត្យជាធំថា ឥឡូវនេះតើអញទឹងគិតការបួងសួងទេព្រ័ក្ស អារ័ក្ខ អ្នកតា ព្រះភូមិដែលលោករក្សាព្រះនគរបូរីរដ្ឋ ហើយទឹងទេព្ដារក្សាខ្លោងទ្វារ ទឹងតែង

គ្រឿងសក្ការបូជា មាន់ ទា ស្រា បាយ លាជ ផ្កា ស្លាធម៌ បាយសី ចំណីចំណុកផ្សេងៗ នានា អុចថ្វាយបូជាទេព្រក្ស៍ទាំងពួង បួងសួងថ្វាយ សូមទឹកភ្លៀង ឲ្យមានមកក្នុងរដូវតាមប្រវេណីពីបុរាណរៀងមក ។

គ្រានោះ សេនាមន្ត្រីជាធំស្តាប់ហើយ ក៏ក្រាបបង្គំលាមករៀបចំ ចាត់ចែងតាក់តែងធ្វើពេនពជរតិច្ឆ័ត្រទង់ ចាមរវែមន់ សែនតួនស្រេច ហើយ ក៏ត្រៀមចាំសម្តេចព្រះភូមី ។

គ្រានោះ ព្រះបាទពេជស្ដានរឿងឫទ្ធិបតី លុះព្រឹកព្រាងស្វាង ព្រះសូរ្យហើយ ព្រះអង្គក៏ចូលកាន់ទីស្រង់ព្រះពរស្រេចហើយ ភូមីក៏ ទ្រង់គ្រឿងគ្រប់ប្រដាប់ ប្រដា ព្រមទាំងស្រីស្នំក្រមការឆ្វេងស្តាំ ហើយក៏ ស្ដេចចេញចាកពីប្រាសាទកែវសូរ្យកាន្ត ឯបណ្ដាពួកទាហានហែហម លោមចោមជុំជិតប្រកិតហែទៅ លុះអង្គព្រះចមហៅស្ដេចយាងមកដល់ ហើយព្រះអង្គក៏ទ្រង់យកសុគន្ធវិលេ មកចេមថ្វាសហើយ ព្រះអង្គក៏អុជ ទៀនធូបថ្វាយគ្រឿងសក្ការបូជាលាជភ្ញីផ្កា បូជាទេព្តានឹងទេព្រក្សតូចធំ ទាំងពួង ព្រះអង្គបួងសួងអស់ទេពទេព ។ ហើយស្ដេចមានព្រះឱង្ការ អញ្ជើញទេព្រក្ស អ្នកមានឫទ្ធិអានុភាពសក្តា ដែលលោកនៅរក្សាព្រះពជ ឈាទីនិវេសន៍កងទាំងប៉ុន្មាន សូមទានអញ្ជើញអ្នកចូលមកទទួលយកនូវ គ្រឿងសក្ការបូជា ពិធីពលីការដោយខ្ញុំគារវកក្តី ទាំងពួកអារក្សអ្នកតា ព្រៃភ្នំ ឃ្លាំងមឿងជាធំដែលស្ថិតនៅសព្វគ្រប់ដំបន់បូរុក្ខជាតិ សូមអ្នកខ្ញុំ-

ឃ្មាតអញ្ជើញចូលមកសេពសោយឲ្យសប្បាយ នូវអស់គ្រឿងដង្វាយសក្ការបូជា សូមលោកមានចិត្តមេត្តាករុណាអាណិតយកចិត្តជួយសង្គ្រោះដោះទុក្ខអាណាប្រជាជនមន្ត្រីសេនីសេនាទាហាន ឲ្យបានមានជីវិតរស់តទៅ ក្បិតគ្មានទឹកភ្លៀងសោះឡើយ ហើយខ្ញុំនឹងឧទ្ទិសកុសលផលជូនដល់អ្នកតាំងពួង គ្រានោះ រីអស់ក្រសួងស្រីស្នំក្រមការនោះ លុះអុជទៀនធូបរួចហើយ ក៏បង្កើតស្វាបញ្ជាំវង្វនប្រាណតាំងប៉ុន្មាននាក់នោះ ស្ទុះក្រោកឡើងរាំច្រៀងលេងតាក់ក្បាច់រេកំខទន្ទាំទន្ទ្រីងលេងសប្បាយ ហើយក៏និយាយបួងសួងថា អស់លោកទេព្តា អារក្ស ទេព្រក្ស អ្នកតា ជាសាក្សីពេជ្រញាណ មានបុត្តានុភាព សក្តិសិទ្ធិដែលស្ថិតនៅក្នុងកេងសាលធំឥឡូវនេះ ស្តេចរៀបចំនូវគ្រឿងសក្ការបូជាថ្វាយ ដង្វាយជូនលោកសេពសោយឲ្យសប្បាយ សូមលោកតាំងឡាយអញ្ជើញជួយស្តេចឲ្យសម្រេចបានដូចក្តីប្រាថ្នា កុំឲ្យព្រះចក្រាស្តេចព្រួយព្រះទ័យ ។

កាលនោះ ព្រះបាទពេជស្ថានរិទ្ធិត្រៃក្រ ក្សត្រិយ៍ក៏ខំឧស្សាហ៍ បួងសួងសែនសព្វវេលាគ្រប់ខែ្វង ហើយនឹងមានភ្លៀងស្រក់ចុះមក ១ ដំណក់ឡើយ ហើយស្តេចក៏រីងរៃតែព្រួយព្រះទ័យភ័យបារម្ភពុំមានសេចក្តីសុខសោះឡើយ ។

កាលគ្រានោះ នាយព្រានព្រៃម្នាក់ក៏បានដឹងសេចក្តីថា ព្រះនរបតីបេស្តាតាំងពិធីការបួងសួងទេវតានោះ លុះដល់ ៧ ខែ ៧ ថ្ងៃ រីភ្លៀងនោះ

នៃទឹងមានស្រក់ ១ ដំណក់ក៏ទេសោះឡើយ ហើយនាយព្រានព្រៃនោះបានដឹងហេតុដូច្នោះហើយ ពុំលង់ឡើយក៏ចូលមកថ្វាយបង្គំទូលឲ្យស្តេចទ្រង់ជ្រាបសេចក្តីថា សូមទ្រង់មេត្តាដែលភ្លៀងរាំងនោះ ព្រោះហេតុតែអំណាចឥសីមួយអង្គ មកគង់ចម្រើនឈាន នៅក្នុងព្រៃសាលវននៅជាន់ចន្លោះជើងភ្នំនោះ ឈ្មោះមហាឥសីកាលិយគោត្ត សូមទ្រង់ជ្រាបសេចក្តី ។

កាលនោះ ព្រះបាទពេជស្តានាធិបតី បានស្តាប់នាយព្រានព្រៃទូលដូច្នោះហើយ ទើបអង្គព្រះករុណាត្រើយទ្រង់ពឹងក្នុងចិន្តាថា ការនេះមានតែអង្គអញទំនងគិតបំផ្លាញពិធីមហាឥសីនេះបាន ឥឡូវនេះទឹងមានស្រីណាហើយ ទឹងឲ្យទៅលួងលោមដោយឧបាយកលឧបលក្ខគតិគកែខៃឲ្យខាងតែបានការ ឲ្យមហាឥសីលះខូវគ្គស្នេហាប្រតិព័ទ្ធ មហាក្សត្រទ្រង់គិតពិចារណាដូច្នោះហើយ ព្រះអង្គក៏យាងចូលក្នុងប្រាសាទជ័យ ដល់ហើយក្តីទ័យក៏ឈ្លានឡើងគង់លើព្រះទែនកែវអលង្ការ ហើយត្រាស់ហៅទៅធីតាថា ម្នាលកូនស្ងួនសម្លាញ់បិតាអើយ កូនអើយសូមអ្នកជួយជីវិតបិតា ឲ្យបានរួចក្នុងគ្រានេះម្តង ត្បិតគ្មានភ្លៀងឡើយហោង ធ្លាក់មកក្នុងនគរយើងសោះឡើយ កូនអើយឥឡូវនេះមានមហាឥសីមួយអង្គមកតាំងពិធីការ មេត្តាចម្រើនឈាននៅចុងព្រំខេត្តដែនរបស់យើងនេះ ឥឡូវនេះក៏គ្មានទឹកភ្លៀងសោះឡើយ កូនអើយអស់អាណាប្រជាជនមានសេចក្តី

លំបាកគោកយ៉ាកអត់ឃ្លានទាំងព្រះនគរបូរី នឹងបានសេចក្តីស្លាប់វិនាសអន្តរាយអស់ហើយ កូនអើយចូរអ្នកទៅជួយរំលាងរំលាយពិធីឥសីឲ្យបាន បើបានហើយ ចូរកូននាងនាំយកមកនគរបូរីយើងឲ្យបានណាកូនណា បិតានឹងអភិសេកឲ្យសោយរាជសម្បត្តិជាកំពូលពិនធានិទ្ធបូរីរាជ អាចនឹងបានជាទីពឹងអាណាប្រជាជនទាំងឡាយ ។

កាលនោះ រីនាងអរុណវតីធោមធាយ បានស្តាប់វាទីព្រះបិតាហើយ ក៏ក្រាបវន្ទាទូលតបបិតុរង្គថា ខ្ញុំម្ចាស់ទទួលរ៉ាប់អាសាថ្វាយបិតា កុំព្រួយព្រះទ័យបារម្ភ សូមខ្ញុំនឹងជួយយកជីវិតតបស្នងគុណព្រះបិតាហោង ។

កាលនោះ រីព្រះបាទពេមស្ថានបុទ្ធ័ប្បង ស្តេចបានស្តាប់ព្រះរាជធីតាទូលការតាមព្រះទ័យហើយ ព្រះអង្គក៏ត្រេកអរសោមនស្សណាស់ ទើបស្តេចយាងយាសព្រះបាទា ចេញមកព្រះរាជរោងជ័យ ៗ ហើយក្ដូវន័យក៏មានព្រះឱង្ការប្រាប់ទៅសេនាអាមាត្យ មន្ត្រីឲ្យរៀបរាជរថា នូវអស់យោធារេហ៍ពលពង្សបិតុរង្គសេនីយ ត្បិតកូនស្រីអញនឹងយាងទៅព្រៃហិមវា ។

គ្រានោះ រីសេនាទាំង ៤ បានស្តាប់ព្រះឱង្ការហើយ ក៏ក្រាបថ្វាយបង្គំលារាថយមកចាត់ចែងតែងរេហ៍ពលសកលយោធា ស្រេចហើយក៏រង់ចាំមហាក្សត្រាធិបតី ។

កាលនោះ ទើបនាងអរុណវតីធោមធាយ ក៏ក្រាយចុះស្រង់ព្រះវារី

រួចស្រេច ទើបនាងស្ដេចទ្រង់គ្រឿងរុងរឿងវេក្ខា ប្រដាប់អាត្មាស្រេចព្រះនាង ក៏ស្ដេចចលើមកឡើងរាជរថ ទៀនអស់សេនាអាមាត្យមន្ត្រីយាត្រាទៅតាមមាគ៌ាឋាន រីយោធាទាហានទូវអស់ស្រីស្នំទាំងពួង តាមដោយក្រសួងក្នាក់ផ្ការហែហមហោមជុំអង្គព្រះនាងនាថ យាត្រាកាត់ព្រៃព្រឹក្សាតាមរវោះចន្លោះដងហេមវេស សង្កេតដោយព្រោះជ្រកជ្រលងស្ទឹងបឹងបួរខ្ទួលទីគិរីរុក្ខជាតិ ព្រះនាងនាថ ក៏ទតទស្សនាមើលអស់ដើមព្រឹក្សាដុះដោយដីគ្រៃឈើគ្រឈឹងសាខា ទូវអស់ហ្វូងបក្សាបក្សីឈ្មោលញីចិកស៊ីចំណីដោយក្ដីកាសាសត្វ ហើយនាងនារីរត្នក៏ឲ្យទៀនពលខំស្រូតរូតរះតម្រង់សំដៅចុងដែនព្រំខេត្ត លុះទៀបដិតទីអរញ្ញវេសដែលព្រះមុនីគង់នៅទីនោះហើយ ពុំលង់ឡើយទើបនាយព្រានវនចរក ជាអ្នកនាំមុខរាជរថធីតានោះ លុះដិតមកដល់ជាយព្រៃ ដែលឥសីគង់នោះហើយ ទើបនាយព្រានក៏ក្រាបទូលថា ឲ្យបញ្ឈប់ពលយោធាទ័ព នៅជិតទីអាស្រមក្តុង ហើយក៏ស្ដីប្រាប់ទៅសេនាថា កុំឲ្យនិយាយមាត់កអ្វីអែកោកកាកអឹកធឹកវឹកវរ ចូរសម្ងាត់ឲ្យស្ងាត់ស្ងៀមទាំងអស់គ្នា ស្រេចហើយទើបព្រានវន្នាក្រាបបង្គំទូលទៅសម្ដេចព្រះនាងនាថថា ព្រះមហាឥសីនោះ លោកគង់នៅព្រៃនោះ មានដើមឈើធំចំពោះពិតពិនិត្យមើល ចុះត្រង់ណាឯង ទើបព្រានបង្អុលដៃខ្វែងបង្ហាញប្រាប់ថា នែនាងធីតាមើលទៅចំនុះ ហ៊ាងបួលអាស្រមសាលាមហាឥសី ។

កាលនោះ នាងអរុណវតីបានស្តាប់នាយព្រានប្រាប់ដូច្នោះ នាងក៏ចុះចាកពីកជរថា ក៏យាត្រាដើរត្រង់តម្រង់ទៅបរមសាលា ដល់ហើយឃើញមហាឥសីនោះចំពោះមុខទៅជាសត្វអម្រឹគ្គា តែកាយជាមនុស្សដូច្នោះហើយ ពុំលន់ឡើយនាងអង្គុយស្ងៀម ។

គ្រានោះ រីមហាឥសីកាលិយកោដ្ឋនោះសោត តាំងតែពីកើតមកកាលណា មិនដែលឃើញទេមនុស្សស្រីសោះឡើយ លុះឃើញនាងហើយមកអង្គុយនៅទីនោះ ពិគ្រោះរំពឹងពិចារណាថា សត្វអ្វីអេះក៏អញមិនស្គាល់ សែនមហាពិផលឆ្ងល់សង្ស័យធំខំសម្លឹងប្រឹងមើលទៅឃើញមានស្នែងដុះពីដើមទ្រូងតាំងគូដូចបទុម សត្វនេះពេញចម្លែកពេកក្តី ឬជាសត្វអ្វី ទើបអញមើលមិនស្គាល់សោះឡើយ ហើយទឹងថាជាសត្វតិរច្ឆានក៏ទេដែរ តែមិនដឹងឈ្មោះអ្វី ។ ឥសីរំពឹងគិតហើយក៏មានព្រះពុទ្ធដីកាថាឯងនេះណាជាពួកសត្វអ្វី ហេតុអ្វីទើបមានស្នែងដុះឯដើមទ្រូងនោះ អញឆ្ងល់ណាស់ អញមិនដែលឃើញប្រទះសោះ តាំងតែពីដើមរៀងមកមុខគួរឆ្ងល់ក្រៃ ។

កាលនោះ ទើបនាងអរុណវតីធីតា បានស្តាប់វាចាមហាឥសីហើយ ទើបនាងឆ្លើយតបទូលពុទ្ធដីកាទៅវិញថា លោកតា ស្នែងខ្ញុំម្ចាស់នេះវិសេសចម្លែកប្លែកសល់ មុខគួរឲ្យឆ្ងល់អស្ចារ្យណាស់ ខ្ញុំម្ចាស់មិនដុះស្នែងខាងលើឡើយ ហើយខុសនឹងសត្វតាំងពួងផងឡើយ លោក

គាអើយក៏ត្រឡប់មកផុះឯដើមទ្រូងវិញដូចដួងបទុមត្រពាំងឈូក ហើយលូកដៃពាល់ទៅទន់ដូចជាសំឡី ការនេះសូមព្រះឥសី មេត្តាប្រោសជួយសន្តោសពិគ្រោះមើលឲ្យទាន ទីងបានដឹងជាគ្រោះកាច ឬជាល្អ ឬអាក្រក់ ហ៎ះលោកតា ថាហើយឪតានាងក៏យានក្រកលខិតចូលទៅជិតមហាឥសី ឃ្លាតខ្ទីគក់ប្រញាប់ប្រតិបត្តិបំរើ ហើយធ្វើឲ្យត្រូវទីងដោះនាងដោយកលមាយាស្រី ធ្វើឲ្យមហាឥសីស្រើបស្រាលបណ្តាលដួងចិត្តស្និទ្ធស្នេហា ។

កាលនោះ ព្រះសិទ្ធាតាបសកាលិយគោត្ត នៅគោតមិនដឹងមាយាកលស្ត្រី ក៏ក្តៅសំដៃបិតាបានផ្តាំប្រដៅខ្ញុំនានមកអំពីមុននោះ ក៏លុះបង្កើតសេចក្តីកត: បណ្តាលស្រាលស្រើបព្រឺព្រួចក្បួចទាំងលោមា ដោយនូវក្តីកាមគុណតណ្ហា លោកតាក៏ប្រព៉ឹកទបអង្អែលឪតា ហត្ថាពាល់ត្រូវសុដនត្រុណ ក៏អាគេទកើតប្រតិពន្ធ័តាំងលាត់ស្បង់ទ្រង់រូមសេះមនោរម្យសមសេពអែបជិតទិត្យនៃបនាងនោះ លុះតែស្រេចការកន្ទ្រានោះ ចំពោះឥសីមិនដែលដឹងប្រសព្វសោះឡើយ ហើយនាងក៏ជួយបង្គាប់ប្រាប់ផង ទើបសម្រេចការបាន ។ ស្រេចហើយនាងយៅវិមាននោះ នៅតែអែបនៃបជិតផ្ចិតផ្ដេកកាយមិនឲ្យឆ្ងាយឡើយ ហើយនាងក៏មានសវនីយស្តីថា ខ្ញុំនខ្ញុំនេះជាកជធីតាមហាក្សត្រពេជសាមនាធិបតី ចក្រីស្តេចត្រង់កជធានីបុរីរម្យស្តេចប្រើខ្ញុំនេះឲ្យមកអញ្ជើញយកព្រះអង្គទៅកាន់ទីលំនៅកជឋាន ទីងបានជួយដោះអស់ទុក្ខអាណាប្រជានុកស្ត្រ ឲ្យបានរួចសេះអំពីក្តីមរណា

ប្រៀបគណនាដូចជួយជីវិតហ្វូងជនឲ្យផុតអំពីអត់ឃ្លានបានរស់ផង ។

កាលនោះ ឥសីកាលិយកោដ្ឋសោតបានស្ដាប់នាងថាដូច្នោះ ចំពោះរំលឹកនឹកដល់ពាក្យបណ្ដាំអាពុកដែលបានផ្ដាំទុកថា កុំឲ្យរវើកនឹងសិកាកំលាន់មាត់ថា ឱអញអើយ អញខុសហើយក្នុងគ្រានេះមិនគួរឡើយ មករួមរសមនោរម្យ នឹងស្ត្រីឲ្យខុសនឹងក្រិត្យវិន័យកិច្ចសាងព្រហ្មចរិយៈ ព្រះមុនីសោកណាក៏នឹកស្ដាយណាស់នឹងតបៈកិច្ចពិធី មិនដឹងនឹងគិតធ្វើដូចម្ដេចឡើយ ហើយអញនឹងលះបង់ចោលនាងតាមផ្លូវគិតនឹងទៅសាងពិធីវិញ អញក៏សែនស្ដាយរសជាតិនាងនាថណាស់សល់ ហើយចុះតាមតែផលបុព្វ គិតហើយទើបមានវាចាទេ តបទៅនឹងនាងវិញថា ដែលនាងសិកានឹងនាំបងទៅបុរី ក៏ស្រេចតែសិកាស្រីនាងអាណិតបងផង ត្បិតបងកំព្រា រង៉ាណាស់មានតែម្នាក់ឯង ។

កាលនោះ រីនាងអរុណវតីបានថែងវាចាលោកតាប្ដី តោមស្រីក៏ក្រាបបង្គំវន្ទា សូមអាពធនាអញ្ជើញព្រះអង្គស្ដេចប្រញាប់ឡើងគង់រាជរថ ខ្ញុំរៀបចាំងទេសយោធាមករង់ទទួលចាំនៅជាយព្រៃខាងក្រៅឯណោះ ។

គ្រានោះ ទើបមហាឥសីកាលិយកោដ្ឋ សោតបានស្ដាប់អត្ថាធធីតា ក៏ក្រោកគ្រងគ្រឿងបរិក្ខាតាមរបៀបអ្នកព្រៃ វៃចាប់យកច្រត់នឹងផ្ចិតញាត់ដាក់នឹងយាមធំ ហើយក៏ចេញចោលអាស្រមសាលាទៅជាមួយនឹងនាងទេវីប្រិមប្រិយ រីនាងអរុណវតីនោះ ក៏នាំមហាឥសីប្ដីមកដល់ទី

យោធា នាងក៏វន្ទាអញ្ជើញឥសីឲ្យឡើងគង់លើបល្ល័ង្កពេជ្រពណ៌រាយ នាងដោមដាយអង្គុយនៃបទិត្យជិតផ្ទាប់អង្គ រីពួកអណ្គុស្រីគ្គារ អង្គុយសង់ខាងនាងការុណាវតី ស្រេចហើយឲ្យលើកពលសេនីយយាត្រាវិលទៅសេមាកដ្ឋាន ៗ លុះបានដល់បូរីពេជស្ភានហើយកាលណា ក៏បណ្ដាលមេឃានោះងងឹតអ័ព្ទអស់ទិសា ក៏មានភ្លៀងធ្លាក់មកមហិមាច្រើនក្រៃ រីហ្វូងសត្វព្រៃទូរគ្រីទាំងឡាយ ក៏បានក្ដីសប្បាយមុជហែបហែលលេងដោយគង្គា រីអស់ពួកមនុស្សម្នានាំគ្នាមករកមើលព្រះតាបសឥសីនោះជ្រែកជ្រៀតបៀតគ្នា លុះឃើញកគ្រាមហាតាបសនោះដូចមុខប្រើសដូចសត្វព្រាយ តែរូបកាយជាកេទមនុស្សយើងទាំងអស់ ប៉ុន្តែខុសតែកគ្រា ខ្វះក៏ស្រែកថាពីថ្ងៃនេះតទៅ យើងនឹងចម្រើនសិរីក្ដីសុខាគ្រប់ទាំងធានីរាំងជ័យ ។

កាលនោះ ព្រះបាទពេជស្ភានាធិបតី បានដឹងសេចក្ដីថារាជធីតាទៅបណ្ដាច់ពិធីមុនីឥសីបានដូចក្ដីប្រាថ្នា ក៏សែនត្រេកអរសោមនស្សណាស់ ស្ដេចក៏យាងហោះចុះពីទីប្រាសាទសោភា ទៅទទួលព្រះសិទ្ធាហោង ៗ លុះស្ដេចយាងមកដល់ហើយ ព្រះអង្គក៏ទ្រង់នមស្ការតាបសហើយស្ដេចក៏អញ្ជើញឲ្យមហាឥសីមុនីចុះពីរាជរថ មកឡើងលើប្រាសាទជ័យវេនា ឲ្យមហាឥសីគង់លើបល្ល័ង្ករត្ន ហើយអង្គព្រះចមត្រ័យប្រា-ស្រ័យនឹងព្រះតាបសឥសីសិទ្ធ ដែលទ្រង់ព្រិទ្ធព្រហ្មចរិយបំពេញឈាន

ក្នុងពនាល័យ ព្រះអង្គពូកែក្នុងកិច្ចពិធីវិសេសណាស់ ដោយអំណាចមន្តវិជ្ជាការអាគមព្រះគុណ ទើបគ្មានព្រះករុណាស្រក់មកក្នុងនគររាជធានីវៀងវាំងរាំងបីឆ្នាំគត់ រាស្ត្រប្រជាជនក៏អត់ឃ្លានគ្មានស្រូវអង្ករនឹងស៊ីចុកសោះឡើយ ហើយក៏ស្លាប់អន្តរាយវិនាសច្រើនណាស់ ទើបទ្រង់ប្រើប្រាសឲ្យរាជធីតាទៅនិមន្តព្រះគុណមកក្នុងភព ដើម្បីនឹងជួយដាក់ជីវិតសត្វទាំង-ឡាយ ដែលកើតទុក្ខវេទនាភ័យនោះ នឹងបានរួចពីទុក្ខសោកភេទភ័យ ដោយបុណ្យបារមីព្រះអាចារ្យ ។

កាលនោះ ព្រះមុនីវង្សា បានស្តាប់ព្រះរាជទីហើយក៏ឆ្លើយតបទៅវិញថា ហេតុភេទការទាំងនេះ រូបមិនបានដឹងសោះឡើយ ៗ ហើយអាត្មាវល់តែសូត្រមន្តចម្រើនមេត្តាភាវនា តាំងចិត្តប្រព្រឹត្តការរក្សាកិច្ចពិធីតាមគម្ពីរសៃយវេទ ហេតុដូចម្តេចស្តេចក៏មិនប្រើសេនាអាមាត្យឲ្យទៅប្រាប់ក៏បានដែរ ក៏ស៊ូតែលំបាកលំបិនដល់ ៣ ឆ្នាំ ទាល់តែឃើញនាងអរុណវតីទៅដល់និយាយរាយរឿងប្រាប់អំពីមៀងវៀងវាំងជ័យ កើតភ័យភិតក្នុងបុរីរាជធានីសេមា ទើបរូបអាត្មានេះនិមន្តមកកាន់រាជស្ថាន ៗ

កាលនោះ ព្រះបាទរាជស្ថានបានស្តាប់ហើយសែនត្រេកអរសាទរក្រៃ ទើបត្រូវទ័យក៏ថ្វាយទៀនធូបលាជផ្កាភ្ញីមាសទៅព្រះតាបសឥសី សូមព្រះគុណមេត្តាប្រណីគង់នៅទីនេះនឹងបានតាំងពិធីការ ក្នុងមហាប្រាសាទស្ថានឲ្យបានភ្លៀងមកហោង ៗ ទើបព្រះកាលិយកោដ្ឋផង

បានស្លាប់ហើយ ក៏ត្រេកអរសោមនស្សរួមមនោរម្យនឹងនាងទេវីជាទីសុខសប្បាយកាយា សែនមហាត្រេអាលស្រោលស្រើបស្នេហា ក្បួចក្បាំងតាំងចម្រើនមេត្តាការនាបូជាអគ្គី ហើយតាំងទីអាវាសបរិវេណដែលធ្លាប់ដើរចង្ក្រមឈានហើយ ក៏គ្មានទីករលឹកសិស្សឡើយ ព្រងើយលះបង់ចោលកិច្ចសព្វសារពើតាំងពួងពិត ពីព្រោះតែគុំស្នេហ៍ស្និទ្ធរមសេទឹងកជជីតាជាអចិន្ត្រៃយ៍ទៅហោង ៗ រីនគរវេសាពេជស្ថាននោះ លុះតែបានឥសីកាលិយកោដ្ឋមកកាលណា ក៏មានសព្វកាលរដូវត្រៃតាមសណ្ដាប់ស្រុកពស្ត្រ ប្រជាក៏សុខសម្បូណ៌ក្សេមក្សាន្តគ្រប់ឋាន ទីដំបន់ឥតប័ទ្ទះខាតដូចដើមឡើយ ៗ

កាលនោះ យើងនឹងពោលពណ៌នាពីព្រះបាទទធរដ្ឋាធិបតី ដែលគ្រប់គ្រងបូរីស្រីអយុធ្យានោះ រីអស់បណ្ដាពួកទេវាសុរាប្ញទ្ធិឥសីសិទ្ធិពិធ្យាធរ កិន្នរនាគ នៅគ្រប់ដំបន់ សឹងមកជ្រកពឹងបុណ្យបារមី ព្រះអង្គដូចធីត្រជ័យ បើកបាំងពីលើមោលីជាមួប គ្រប់ប្រទេសក៏បានសេចក្ដីសុខសម្រាន្តគ្រប់ប្រាណប្រុសស្រី រីព្រះបាទទធរដ្ឋាធិបតីនោះ ព្រះអង្គមានមិត្រសំឡាញ់ ១ នឹងស្ដេចសកុណាឈ្មោះថា សដាយុសបក្សា ៗ ហើយស្ដេចគ្មានបុត្រីបុត្រាសោះឡើយ ហើយព្រះអង្គទ្រង់គិតរំពឹងក្នុងចិន្តា ថាបើអាត្មាអង្គអញនេះស្លាប់ទៅ នឹងបានអ្នកណានៅសោយរាជ្យស្នងត្រកូលវង្សត្រពង្សពូជ ទៅមុខនាយនោះក៏គ្មាននឹងគេសោះឡើយ ហើយពួកអសុរអសុរីរក់នឹងចលាចលអំពល់បៀតបៀនត្រៃលោកពុំខាន បើដូច្នោះ

មានតែអញគិតអានប្រជុំជំនុំប្រឹក្សា នឹងមហាឥសីសិទ្ធិ ដែលលោកមានឫទ្ធាក្លាហាន នឹងបានតាំងពិធីការបង្កើតកូន កុំឲ្យសូន្យឡើយ ៗ លុះព្រឹកព្រាងស្វាងព្រះអរុណោទ័យ ព្រះភូវនៃយក៏ទ្រង់ជម្រះព្រះអង្គទ្រង់គ្រឿងប្រដាប់ស្រេច ក៏ស្ដេចយាងចេញកាន់ព្រះរាជរោងរត្ន ទើបព្រះចក្រពត្តិឡើងគង់លើបល្ល័ង្ករត្ន ក្រោមស្វេត្រច័ត្រចេតឆាយ ព្រមទាំងពួកមន្ត្រីតាំងឡាយគាល់ហៀរត្រៀបត្រា ហើយស្ដេចមានព្រះឧង្ការបង្គាប់ប្រាប់ទៅចៅក្រសួងថា ចូរទៅនិមន្តព្រះអាចារ្យមហាឥសីមកឆាប់ ៗ

គ្រានោះ វាក្រសួងភ្នាក់ងារបានស្ដាប់ព្រះរាជតម្រាស់ ក៏ក្រាបសំពះថ្វាយបង្គំលា នាំជិះពាជីទៅម្នា ៗ លុះបានដល់នាទីអាស្រម ក៏នាំគ្នាចូលថ្វាយបង្គំនមស្ការ ទើបទូលថា ព្រះមហាក្សត្រស្ដេចឲ្យនិមន្តចូលឥឡូវនេះឆាប់ ១ ៗ

កាលនោះ ព្រះវរសិម្ពិព្រះស្វាមិត្រ ព្រះវជមិត្រអគ្គី តាំងព្រះមុនីភារៈ-ទ្វាជៈតាំង ៤ នាក់ បានដឹងសេចក្ដីថា ព្រះវង្សទេវាជាកំពូលពិនបុរី ចក្រិឲ្យមកនិមន្តដូច្នោះហើយ ពុំលង់ឡើយទើបនិយាយប្រាប់គ្នាថា ឥឡូវនេះព្រះមហាក្សត្រឲ្យនិមន្តចូលទៅកាន់បុរីរាជស្ថាន ស្រេចហើយគប់ប្រាណក៏ទ្រង់គ្រឿងបរិក្ខារស្រេច ក៏នាំគ្នាត្រេចហោត្រាចាកសាលាអាស្រម ៗ លុះបានដល់បុរីរម្យរាជធានី ទើបនាំគ្នាចរលីលាឡើងគង់លើអាសនៈគង់តាមអណ្ដាប់អណ្ដាយក្រោយមុខគ្នា ៗ

ចប់ខ្សែ ៧ ហើយមានខ្សែ ៨ តទៅទៀត ។

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

(ត)

ចំណងជើង *"សាស្ត្រា ចៅដោះ"*

អ្នកនិពន្ធ *រកពុំទាន់ឃើញ*

កាលបរិច្ឆេទ *គ្មានបញ្ជាក់ក្នុងអត្ថបទ ។*

របៀបនិពន្ធ *កាព្យពាក្យ ៧ (បទល្ហោន) ។*

ប្រភេទរឿង *ខ្សែសន្ធ ?*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត ១ ខ្សែ ។ ឯកសារនេះប្រហែល មិនទាន់ចប់ទេ ព្រោះមានតែ ១៧ សន្លឹក ស្លឹករឹតប៉ុណ្ណោះ ចុះលេខសាស្ត្រា ៦២៣ ។*

អត្ថបទដើម *នេះបទពោល ។ នេះទឹងសម្តែងថ្លែងនិទាន ពីអង្គក្សត្រ ក្សត្តនាថនាមា ព្រះបាទសាមលក្រុងកាព នៅនានគរក្រុងបុរី ។ មហេសីទ្រង់នាមនាងមន្ទារ មានបុត្រសុទ្ធតែពជក្សត្រី ប្រាំពីរព្រះអង្គឆោមប្រិមប្រិយ៍ ទ្រង់នាមទីទៃ ៗ គ្នា ។ ឯនាងប្អូនពៅ បង្អស់នោះ ទ្រង់ព្រះនាមឈ្មោះនាងរចនា ល្អល្អះហាក់ដូចស្រី សួគ៌ា មានសុំស្នេហាជាសុខសាន្ត ។ . , . .*

*. . . . . ។ល។ . . .*

អត្ថបទបញ្ចប់ ដុតភ្លើងក្រឆេះស្តេចប្រឹងផ្លុំ ផេះហើរជាប់រុំមុខស្រមក

តាំងស្តេចតាំងនាងសឹងឈ្លក់ក្អក ផ្សែងភ្លើងបក់មកត្រូវផ្កាភ្លុកៗ

យកដៃឈ្វើភ្លុកបបោសផេះ ភ្លើងឆេះបាយតុះពោរពន់ពេក

នាងទំប្រវាលូកយកវែក ដៃមួយបិទភ្លុកមួយកូរឆ្នាំង ៗ

ស្តេចយល់បាយតុះដាក់មកដាត់ កាន់គ្របឆ្នាំងភ្លាត់ទឹកចេញខ្ទាំង

ទៅទាំងអង្ករពីក្នុងឆ្នាំង រលះរលាំងដាក់ឆ្នាំងផ្តុំ ៗ ដុតទៀត

ហើយកប់ទាំងប្រហុក ឆ្អិនសព្វគ្រប់មុខហើយរៀបចំ ធីស្រេច

លុះយប់ព្រលប់ធំ ហើយចរចូលដំណេកនោះនៃ(១) ៗ

—X—

បំណងជើង «សាស្ត្រា ល្បើកាស្រែវែង»

អ្នកនិពន្ធ រកមិនទាន់ឃើញ ៗ

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ៗ

របៀបនិពន្ធ កាព្យពាក្យ ៧ ៗ

ប្រភពរឿង ស្នេហាពេលជួបគ្នា នៅស្រែវែង ៗ

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មានត្រឹម ៧ សន្លឹកប៉ុណ្ណោះ

ឯកសារនេះ ចុះលេខសាស្ត្រា ៦៣៩ ៗ

---

១ អត្ថបទល្ខោននេះ ប្រហែលជាមិនទាន់ចប់ទេ គ្រាន់តែចប់ឈុត ទី ១ ប្រហែលជានៅមានឈុត ទី ២ ទី ៣ តទៅទៀត ។

អត្ថបទផ្តើម សង្វេគទុក្ខតាំងពល់ទុក្ខ អំពល់អផ្សុកក្នុងចិន្តា ប្រាស

ខ្លួនដេកស្តឹងប្រឹងពិចារណា ថ្លែតថ្លិនអាណិតខ្លួនកំព្រា ៗ ព្រះ

ពាយរំភើយរំផាយផាត់ ស្រងូតស្រងាត់ខ្យល់រងា ស្រពាទប

ឡើយភើយជាគ្នា កំព្រារងាម្នាក់ឯងនៅ ៗ . . .

. . . . . ៗលៗ . . . .

អត្ថបទបញ្ចប់ រឹងប្រុសតន់កុំអន់ចិត្ត ដេកគិតអគ្និយគិតឥតបីបើ នឹក

តែពីស្រីឥតគេស្មើ នឹកណាស់ផ្តាំផ្ញើនឹងខ្យល់ទៅ(១) ៗ

ខ្យល់ . . . . . . .

—X—

បំណាំងជើង "សាស្ត្រា ឥសវង្ស"

អ្នកនិពន្ធ រកពុំទាន់ឃើញ ៗ

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ៗ

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ដូចមហាវេស្សន្តរជាតក ៗ

ប្រភពរឿង គម្ពីរអនាគតវង្ស?

---

១ ឯកសារនេះ មិនទាន់ចប់ទេ ប្រហែលជានៅមានអត្ថបទបន្តទៅទៀត ?

នេះជាអត្ថបទចម្រៀងឆ្លងឆ្លើយ រវាងបុរស និង ស្ត្រីដែលថ្លែងពីសេចក្តីស្នេហាទៅវិញទៅមក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត មានច្រើនគម្ពីរ មានចំនួនខ្សែខុសៗ គ្នា ។ ចំពោះគម្ពីរដែលយកមកពិនិត្យ មាន ១០ ខ្សែ ចុះលេខ សាស្ត្រា ៧០៨ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បាន មកអំពីវត្តជ្រោយនាងងួន ខេត្តសៀមរាប ។

អត្ថបទផ្ដើម នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ សត្ថា សាវត្ថិយំ ឧបនិស្សាយ បុព្វារាមេ វិសាខាយ កាពបិតាយ វសន្តោ អជិតត្ថេរំ អារព្ភ អនាគតេ ។ . . . .

សត្ថា មោះ បរមសត្ថា ព្រះដ៏ជាគ្រូប្រសើរ ព្រះអង្គដែល ប្រដៅឲ្យជាប្រយោជន៍ នៃទេវតាមនុស្សផងទាំងឡាយ ។ វសន្តោ កាលព្រះអង្គគង់នៅ ។ បុព្វារាមេ វិសាខាយ កាពបិតាយ ឰដ៏បុព្វារាម អារាមនាងវិសាខា មហាឧបាសិកា ប្រដាប់សាងថ្វាយព្រះអង្គ ។ ឧបនិស្សាយ ព្រះអង្គអាស្រ័យយកព្រះបិណ្ឌបាត សង្គ្រោះសន្តោសប្រោសសត្វផងទាំងឡាយ ។ សាវត្ថិយំ ឰដ៏ស្រុកសាវត្ថីបុរី ស្រីមហានគរ ។

. . . . . ។ល។ . . . .

អត្ថបទបញ្ចប់ ហៃសារីបុត្តត្ថេរអើយ អស់មនុស្សផងទាំងឡាយ ជាបើពុំទាន់បានលុះមគ្គផលទេតែ ១ ឰដ៏សាសនាព្រះពុទ្ធទាំង ៩

ព្រះអង្គនោះហើយ លុះដល់បាលិលេយ្យកពោធិសត្វ ព្រះអង្គបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមសុមង្គលសម្មាសម្ពុទ្ធ ។ ហៃសារីបុត្តត្ថេរអើយ តថាគតនឹងសម្ដែងថ្លែងសរសើរព្រះបារមីថ្លៃនៃព្រះបាលិលេយ្យ ឲ្យដ៏អាកាសទៅ ព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ចំហុតនូវព្រះនាមករហៅថា សុមង្គលសម្មាសម្ពុទ្ធ ។

ឧទ្ទេសោ ជាសង្ខេប ។ ទសមោ គ្រប់ ១០ ព្រះអង្គ និដ្ឋិតោ ជាស្រេច ។ ឥតិបការេន ដោយនូវប្រការអម្បាលណេះហោង ។

—X—

បំណងរឿង «សាស្ត្រា សុវណ្ណខ្យងសង្ខ(១)»

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង បញ្ញាសជាតក ។

១- តាមផ្ទៃរឿង មិនសមជាសាស្ត្រាទេសន៍ទេ ប៉ុន្តែអ្នកនិពន្ធបុរាណបានរៀបរឿងជាលំនាំទេសនា ។ សាស្ត្រាល្បែង ១ ទៀតហៅថា «ខ្យងសង្ខ» និពន្ធជាកំណាព្យបុរាណ ក្នុងលំដាប់ទី ៣ នៃបញ្ជីប្រជុំឯកសារនេះ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៩ ខ្សែចប់ដុំជាតក់ ។ ឯកសារ
នេះ ចុះលេខសាស្ត្រា ១០១៧ ពុទ្ធសាសនបណ្ឌិត្យ បានមក
ពីវត្តវាល ខេត្តពោធិ៍សាត់ ។

អត្ថបទផ្ដើម នមោ តស្ស ។ ឯវម្មេ សុតំ ឯកស្មឹ សមយេ សត្ថា
ជេតវនេ វិហរន្តោ . . . ។
អារព្ភ កថេសិ ។
ហត្ថា ព្រះមុនីចរិយាញាណ ។ វិហរន្តោ កាលព្រះអង្គគង់
នៅ ។ ជេតវនេ ក្នុងព្រះជេតពន សុគន្ធកុដី ស្រីមហាវិហារ ។
ឯកស្មឹ សមយេ មានកាលសម័យថ្ងៃមួយ ។ . . .
. . . . . ។ល។ . . . .

អត្ថបទបញ្ចប់ ព្រះបាទសាមលរាជ ចេរវិលវិញមកជាព្រះមហាអានន្ទ ។
ឯព្រះបាទសាមលរាជចេរវិលវិញមក បានជាស្តេចធំ ឧត្តមប្រ-
សើរហោង ។ រីឯក្សត្រីចន្ទីទេវី គឺព្រះស្រីមហាមាយាប្រសើរ
ហោង ។ ឯសុវណ្ណធតា ចេរវិលវិញមកជា នាងស្រីសុជាតា ។
អហាមេវ ព្រះសុវណ្ណខ្យងសង្ខ គឺអង្គអញតថាគតប្រាកដហោង ។
បពិត្រអើយ រីទឹងសម្ដែងនិទានព្រះសុវណ្ណខ្យងសង្ខនេះមិញ ។
និដ្ឋិតា ក៏ចប់បរិបូណ៌ស្រេចនូវប្រការអម្បាលណោះឯងហោង ។

បំណងដើង „សាស្ត្រា ស្រីវិជ័យ(១)„

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ លំនាំទេសនា ។

ប្រភេទរឿង ចលនាជាតក៍ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត មាន ១៣ ខ្សែចប់ ដុំជាតក៍ ។ ជាតកនេះ ប្រកបដោយគាថា ៥០១ គាថា ចែកជាកណ្ឌ ។ មាន ១៣ កណ្ឌ ចែកជាខ្សែ មាន ១៣ ខ្សែដែរ ។ ខ្សែទី ១ មាន ២៨ សន្លឹក, ទី ២ មាន ២៨ សន្លឹក, ទី ៣ មាន ២៣ សន្លឹក, ទី ៤ មាន ១៤ សន្លឹក, ទី ៥ មាន ៣៤ សន្លឹក, ទី ៦ មាន ៤៥ សន្លឹក, ទី ៧ មាន ១៩ សន្លឹក, ទី ៨ មាន ២២, ទី ៩ មាន ១៦ សន្លឹក, ទី ១០ មាន ១៧ សន្លឹក, ទី ១១ មាន ១០ សន្លឹក, ទី ១២ មាន ១២ សន្លឹក, ទី ១៣ មាន ១៦

---

១ តាមអត្ថបទផ្ដើមរឿងនៃសាស្ត្រាស្រីវិជ័យនេះ ជាព្រះពោធិសត្វចិត្តចង់កសាងទានបារមី ប៉ុន្តែតាំងពីខ្សែ១ ដល់ខ្សែ ៨ កវី បានបញ្ជាក់អំពីសមត្ថភាពនៃតួអង្គ ឋិតនៅលើការដោះស្រាយបញ្ហាស្មុកស្មាញផ្សេងៗ នៃសង្គមឲ្យបានរួចផុតពីការទាល់ច្រក តាមផ្លូវវិចារណញ្ញាណនិងយុត្តិធម៌ ។ តាំងពីខ្សែ ៨ ដល់ចប់ ទើបតួអង្គចិត្តចង់កសាងទានបារមីយ៉ាងអស្ចារ្យ ដូចការបរិច្ចាគដំរីសដល់ព្រាហ្មណ៍ ៨ នាក់ ការដាក់ទានបុត្រភរិយាដល់ជូជកព្រាហ្មណ៍ ដូចមានក្នុងរឿងព្រះវេស្សន្តរដែរ ។

សទ្ទឹក ។ ចុះលេខសាស្ត្រា ១៣៧២ ។

**អត្ថបទផ្តើម** នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ទេវពជ នមោត្យុត្តិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ
ទានបារមី អារព្ភ កថេសិ ។

សត្ថា មោះ សត្ថវាហោ សត្ថនាយកោ ព្រះបរមសាស្តាស្រពញ្ញ
ជាគ្រូរបស់ទេវតា សុភសុរិន្ទត់ទូព្រហ្មបរមទេពាវិជ្ជាធរ នាគ
យក្ខគន្ធព្វសុបណ្ណមនុស្សសត្វផងទាំងឡាយ ព្រះអង្គជានាយក
តែងនឹងគៀរគរបរប្រមូលបញ្ចូលទៅកាន់អម្ពុតបុរី ស្រីមហា
នគរបវរនិព្វាន ដ៏ជាឋានបរមសុខក្សេមប្រសើរ ។ វិហរន្តោ
មោះ ចតូសុ ឥរិយាបថេសុ វិតិនាមេន្តោ ព្រះអង្គសំរេចសំរាន្ត
មានព្រះឥរិយាបថទាំង ៤ មិនឲ្យច្បូនតម្រិះចិត្តនៃសត្វផងទាំង
ឡាយឡើយ ។ . . . . . .

**អត្ថបទបញ្ចប់** មហាសិរីវិជយជាតកំ និដ្ឋិតំ ។ បពិត្រអើយ រីយើង
នឹងស្រដី សរសើរដំណើរ ដំណាលព្រះតថាគត យោនយក
កំណើតកើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមគរបវរឈ្មោះ
ព្រះស្រីវិជ័យខេះមិញ ។ គេរសកណ្ឌំ រីកណ្ឌជាគំរប់ ១៣
និដ្ឋិតំ មោះ និដ្ឋិតោចយោ ស្រេចនិយាយនូវប្រការអម្បាល
ណោះឯងហាង ។

បំណងជើង "សាស្ត្រា សុវណ្ណជលា(១)"

អ្នកនិពន្ធ ហៅពញាកជាមាត្យ "ទៀង" និងព្រះស្រីអញ្ជិត "ស្រី" ។

កាលបរិច្ឆេទ ថ្ងៃសុក្រ ១៥ កើតខែផល្គុន ម.ស.១៧២៦ គ.ស.១៨០៤

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត កុជន្គលីលា)

ប្រភេទរឿង រឿងព្រេងមួយ (ប៉ុន្តែរឿងព្រេងនេះ វែងជាងរឿងព្រេង នានារបស់ខ្មែរយើង) ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ៧ ខ្សែចប់ ។ ខ្សែទី ១ មាន សន្លឹក ៣០, ខ្សែទី ២ មានសន្លឹក៣៥, ខ្សែទី ៣ មាន សន្លឹក ៣៦, ខ្សែទី ៤ មាន សន្លឹក ២៨, ខ្សែទី ៥ មាន សន្លឹក ៣៣, ខ្សែទី ៦ មាន សន្លឹក ២៦, ខ្សែទី ៧ មានសន្លឹក ១៨ ។ បូករួម ៤០៦ សន្លឹក ។ ឯកសារនេះ ចុះលេខ សាស្ត្រា ១៣៧៤ ។

អត្ថបទផ្តើម អហំវន្ទា សុសិរសា រតុត្តសេដ្ឋំ នមស្សធម្មោ សង្ឃោ-គុណំ សុភាវហំ វរលោកុត្តរ ។ អហំ វន្ទំ សូមថ្វាយបង្គំ

---

១ សាស្ត្រានេះ ពុទ្ធសាសនបណ្ឌិត្យបានខ្ចប់អំពីវត្តហោរ ខេត្តកណ្តាល យកមកចម្លងរក្សាទុកកាលពីឆ្នាំ ១៩៤៣ ។ រឿងនេះ មានចលនាប្រហែល នឹង ចលនា ព្រាហ្មណនិយម ឬ ជាតកទាំងឡាយដែរ តែគ្មានការសរជាតិទេ ។

ដាក់លើសិរសា សរសើរសម្តេច សារពេជ្ញគត ព្រះអង្គ

ជាតិជា ឥស្សរភពត្រៃ ។ . . . .

សកកពជចូលមក ឯកស័ព្ទពោធ ស័កសំរេច ជួបចូលហេមន្ត

ផល្គុនមាសា សុក្រៈពារ ពារពេញបូណ៌មី ។ កាយានាមា-

គតីមាតា ឈ្មោះទៀងជាតិ បានជាចៅពញា ពជាមាត្យខ្មី

មានប្អូនឈ្មោះស្រី សន្ទតនាមា ។ ព្រះស្រីអញ្ជិត រសិរៈ-

គន់គិត ថែងចងកាព្យា និពាន់អំពី សុវណ្ណមាលា រើងប្តូធិចេស្ត

វិមានមានបារមី ។ . . ។ល។ . . .

អត្ថបទបញ្ចប់ ស្តេចស្វាធុងកេ ៈសកសោតសិងកែ វលងជាតិកន្ទង

បានទៅកើតជា ជួបចូលស្នេហ៍ស្នង ហានស្នូតិជាមួង (ចាំង

៤ រូបា) ។ ពោះតាំងស្តេចមនុស្ស ចំណុះតាំងអស់ ពីរយេ

ទ្វេហារ សោយទិវង្គត រលត់ជន្មា សឹងទៅកើតជា សុខស្នូគា-

ល័យ ។ មូលទីងព្រះអង្គ ប្រស័រព្រើសព្រង់ គ្រៀមក្សាន្ត-

ប្រពៃ តាំងពស្តេចស៊េន ច្រើនក្តាត់ទីទៃ សឹងបានបិតព្ង- ដ៏ជា

បរិពារ ។

អាយុវណ្ណំ សុខំពលំ សិទ្ធិពលា សឹងយឺនរៀងរាប ជរាប

ដល់អា- នាគតថ្ងៃថ្ងា បច្ចយោហោន្តុ ។

បំណងជើង "សាស្ត្រា ពាលចក្រី(១)"

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានអត្ថបទបញ្ជាក់ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា (កម្រង់កែវ) ។

ប្រភពរឿង បរាជ័យនៃលទ្ធិព្រាហ្មណ៍សាសនា ជាពិសេសលទ្ធិសិវនិយម ក្នុងប្រទេសកម្ពុជាសម័យអង្គរ ?

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ២៧ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានចម្លងតាមច្បាប់វត្តវេឡុការាម កាលពី គ.ស. ១៩៤៣ ចុះលេខឯកសារ ១៣៨៧ ។

អត្ថបទផ្ដើម នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ គោសាធុពេ ហៃសាធុសប្បុរសផងទាំងឡាយអើយ ចូរស្ដាប់អភិប្រាយនិយាយ អំពីសម្ដេចព្រះស្រីសារពេជ្ញ ព្រះពុទ្ធគម្ដែងយើង តែងទីងប្រោសសត្វនិករ អមរមហន្តមហាសម្ភារ នាកាលព្រះអង្គ គង់ព្រះជន្មានៅឡើយ មានកុម្ភទេវតា មួយ

១ មានឯកសារ ១ ខ្សែទៀត មានចំនួន ២៧ សន្លឹកដែរ ប៉ុន្តែដាក់បំណងជើងថា "សាស្ត្រាព្រះឥស្សរលេងពួន" ។ ឯអត្ថន័យផ្ទៃរឿង ក៏ប្រហែលនឹងសាស្ត្រា "ពាលចក្រី" នេះដែរ។

ឈ្មោះមហេសូរទេវតា មានចុទ្ទិទេស្តានុភាព ដំពបនូវតបៈមានៈ ដ៏ប្រកបនូវឥស្សរ សម្បត្តិយសសក្ការៈដ៏ឧឡារិក អធិកមហិមា ។

. . . . ។ល។ . . .

អត្ថបទបញ្ចប់ ឥតិ ញត្វា នរា លោកេ ។ ហៃសាធុសប្បុរសផង ទាំងឡាយអើយ នរអ្នកឯណា ដឹងទោសអាត្មាជាខុសពុំត្រូវ នឹងគន្លងផ្លូវល្អ ដោយសុចរិត ដោយមកប្រែប្រាសលាកលះ ចិត្តអាក្រក់ចេញ ទទួលយកព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹងទី រលឹក ពាំនាក់សព្វថ្ងៃ អាល័យតែកាននិងសីលពុំខ្ជិល អាត្មា លំឧតកាយារក្សាសីល ៥ ចាំនូវសីលអដ្ឋ សីលឧបោសថ មានអំណត់សប្បុរសខន្តី ។ . . . . .

បពិត្រអើយ អាត្មាភាពចំរើនពរបវរពិពឌ្ឍមង្គល គម្ពល់ពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ចូរជាបច្ច័យនៃអ្នកសប្បុរស គឺឧបាសក ឧបាសិកា ដ៏មានចិត្តមមាញឹកនឹករលឹកគុណព្រះ រតនត្រៃមកនិមន្តអាត្មាភាព សំដែងព្រះសទ្ធម្មទេសនា ។ និដ្ឋិតា គឺចប់ដោយនូវប្រការនេះឯង ។

ចំណងជើង "សាស្ត្រា ចំឡងបុណ្យ[១]"

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

ប្រភពរឿង អានិសង្សនៃសីលទានជាដើម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែមាន ២១ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តព្រែកប៉ូន កាលពី គ.ស. ១៩៤៣ ចុះលេខ ១៣៨.៧ ។

អត្ថបទផ្តើម នមោ តស្ស ។ បុញ្ញតំ ករិត្វា យេ នរា ឥធ បណ្ឌិតា ចរិត្វា តេន បុញ្ញេន ទេវលោកេ ឧប្បជ្ជរេ ។ ភោសាធុវេ ហៃសាធុសប្បុរសជនទាំងឡាយអើយ យេ នរា នរអ្នកឯណាមួយ បណ្ឌិតា ដ៏ជាអ្នកប្រាជ្ញ អាចមក ឆ្លាសឆ្លើយអាថិធម៌ជនទាំងឡាយ ឥធ លោកេ ក្នុងលោកនេះ ដ៏បានធ្វើ បុញ្ញតំ

---

១ សាស្ត្រាចម្លងបុណ្យនេះ ប្រហែលកើតឡើងជាន់ក្រោយទេ គឺក្នុងកាលៈទេសៈខ្លះ ដែលព្រះពុទ្ធសាសនា កំពុងមានសភាពរៀវរោយសៅហ្មងដោយវិបត្តិផ្សេងៗ ទាំងចំពោះការចេះដឹងខាងភាសាបាលីសោតទៀតក៏ទន់ខ្សោយច្រើន ជាហេតុនាំឲ្យអ្នកចេះបាលីខ្លះ រិះរកមធ្យោបាយដោះស្រាយវិបត្តិក្នុងពុទ្ធសាសនា ដោយប្រការផ្សេង ៗ ដើម្បីដឹកនាំប្រជាជនឲ្យខិតខំកសាងកុសលសីលទាន ក្នុងព្រះពុទ្ធសាសនា ជាភិយ្យោភាព ។

នៅបុណ្យបានធ្ងន់ហើយ ។ . . . . .

. . . . . . ។ល។ . . . .

**អត្ថបទបញ្ចប់** បពិត្រអើយ នេះយើងនឹងពណ៌នាសរសេរដំណើរ ផលានិសង្ស នៃអ្នកដ៏បានធ្វើបុណ្យទៀតាន និងប្រដាប់ប្រដា ធ្ងន់បុណ្យមិញ ។ និង្គិតា ចប់ ។ តតិបការេន ដោយនូវ ប្រការអម្បាលនោះឯងហោង ។

—x—

**បំណាងជើង** "សាស្ត្រាញាណមណ្ឌល(១)"

**អ្នកនិពន្ធ** រកពុំបានឃើញ ។

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**របៀបនិពន្ធ** ពាក្យកាយ លំនាំទេសនា ។

**ប្រភេទរឿង** ច្បាប់កដនិតិបុរាណ (ឥទ្ធិពលចម្រុះ គឺពុទ្ធនិយម និង ព្រាហ្មណនិយម ។

---

១ សាស្ត្រាញាណមណ្ឌលនេះ ថ្លែងអំពីក្រិត្យក្រមសំរាប់ព្រះមហាក្សត្រ គួរមានចំណង ជើងថា "សាស្ត្រាព្រះរាជនិតិ ឬ សាស្ត្រាព្រះរាជក្រិត្យ" ទើបសមតាមសាច់រឿង? ឯកសារ នេះ មានអត្ថន័យខ្លះ គេពិបាកនិងយល់ណាស់ ប្រហែលឯកសារនេះដាមរតកត ៗ មកពី សម័យអង្គរ ដូចរាមកេរ្តិ៍ដែរ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៤០ សន្លឹក និង ១

ចំពោះឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានចារចម្លងតាមច្បាប់
សាស្ត្រាវត្តវេឡុការាម កាលពី គ.ស. ១៩៤៣ ចុះលេខ
១៣៨៧ ។

អត្ថបទផ្ដើម នេះនៅស្រដីដំណើរកាលព្រេងឡើយ មានមហាឫសី ១
អង្គ ឈ្មោះជលទនចាទមហាឫសី ។ ទើបព្រះធរណីដណ្ដឹង
ប្រស្នាថា បពិត្រមហាឫសីអើយ នាម្ដេចហៅធរណីវិស័យ
ម្ដេចហៅក្រមវិស័យនោះ ម្ដេចហៅបរិត្តវិស័យនោះ (?)

ទើបមហាឫសីឆ្លើយថា អ្នកនឹងចង់ដឹង ចង់យល់វិស័យទាំង
៣ ចំពូកនោះ សឹងកើតឡើងឯង ។

នោះទើបព្រះធរណីដណ្ដឹងថា បពិត្រមហាឫសីអើយ ត្បិត
អ្វីក៏តែងមកកើតឯងដូច្នេះ?

ទើបមហាឫសីឆ្លើយថា នាងតែងមកកើតឯង នោះក្រមវិស័យ
ឯងតែងបង្កើត ។

ទើបព្រះធរណីដណ្ដឹងសួរថា បពិត្រមហាឫសីអើយ ហេតុអ្វី
ក្រមវិស័យតែងមកបង្កើតនោះ ?

ទើបមហាឫសីឆ្លើយថា ហេតុក្រមចរិតរដូវអាហារផង ក៏ប្រែ
ចរិត ព្រះរាជហឫទ័យសម្ដេចព្រះមហាក្សត្រាធិរាជ ក៏ប្រែចរិត

មន្ត្រីក៏ប្រែចរិត ទេវតាក៏ប្រែចរិត អស់មនុស្សផងទាំងឡាយ

ក៏ប្រែចរិត ព្រះអាទិត្យ ព្រះចន្ទ្រា ព្រះរាហូ ព្រះពាយ ព្រះពិរុណ

ក៏សឹងប្រែចរិត ផលាផលផងខ្លះជូរ ខ្លះផ្អែម ខ្លះចត់ ខ្លះល្វីង

ខ្លះខារ ខ្លះហឹរ ខ្លះពុល តោះដល់អ្នកបរិភោគហើយ សឹង

ស្លាប់ហោង ។ . . . . . .

អត្ថបទបញ្ជាប់ រីឈើបន្ទុំភូមិនោះ ទិសបូពិឲ្យដាំបុស្សនូវក្រសាំងហារ

តែក ទិសអាគ្នេយ៍ ឲ្យដាំសុរភីនូវខ្លឹង ទិសទក្សិណឲ្យដាំថ្កូវ

ស្វាយនូវទម្ពាប់ ទិសនិរតីឲ្យដាំចម្ប៉ានូវស្បូវភ័ព្វស្សនាគ ទិស

បស្ចិមឲ្យដាំកន្ទួតនូវអំពិល ត្រុំសែង ទិសពាយព្យ ឲ្យដាំខ្នុរ

ណាំងនូវគ្រុបសំសារ ទិសឧត្តរ ឲ្យដាំពុទ្រានូវខ្វិត រីទិសឦសាន

ឲ្យដាំនូវស្នោ ហោង ។

រីឯគិរ្តផលស័យមន្ត្រី និយាយថាយស្តេចក្រុងសេពាជ

នូវញាណសារគ្គមន្ត្រី ថាយស្តេចញាណមណ្ឌលមិញ សូរេច

នូវប្រការអម្បាលណោះឯង ហោង ។

បំណងជើង "សាស្ត្រា ជាលីភិសេក(១)"

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

របៀបនិពន្ធ គ្មានបញ្ជាក់កំណត់បទ ។

កាលបរិច្ឆេទ ពាក្យកាយ សំនាំទេសនា (កម្រងកែវ) ។

ប្រភពរឿង មហាវេស្សន្តរជាតក ប៉ុន្តែមានផ្លូវរឿងបន្តពីមហាវេស្សន្តរជាតកទៅទៀត ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ក្សែ មាន ៣៦ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តព្រែកកុយ ខេត្តកំពង់ចាម

---

១ សាស្ត្រាជាលីភិសេកនេះ បានឃើញឯកសារ ២ មានអត្ថបទផ្តើមខុសគ្នាច្រើន តែដល់ទៅខាងចុងរឿង មានន័យស្របគ្នាទៅវិញ គឺឯកសារនេះចាប់ផ្តើមឡើង ថ្លែងពីជីវប្រវត្តិរបស់តាជូជក និងពូជពង្សវង្សត្រកូលតាជូជកដោយពិស្តារ ឯឯកសារមួយទៀត ចុះលេខ ១០២១ មានអត្ថបទផ្តើម ថ្លែងបញ្ជាក់អំពីថ្ងៃ-ខែ ឆ្នាំ និងជីវប្រវត្តិនៃតួអង្គសំខាន់ៗ ក្នុងមហាវេស្សន្តរជាតកដោយសង្ខេប ហើយអត្ថបទបាលី ក៏ខុសគ្នាទៀត "នមោ តស្ស . . . ។ កឹ វេស្សន្តរោ រាជា វិស្សជាតោ វេស្សន្តរោ កុក្កុជិវិស្សេ វិសាខបុណ្ណមី ជីវភាវេ សាយណ្ហកាលេ . . . . ។ល។ . . . ហើយនៅខាងចុងអ្នកនិពន្ធបានភ្ជាប់រឿងចៅជាលី និង នាងក្រស្នាឡើងគ្រងរាជ្យនៅនគរទេវលង្កាទ្វីប ដូចឯកសារនេះដែរ ។ ឯឯកសារទីពីរ ដល់បញ្ចប់អ្នកនិពន្ធសរសេរថា "ជាលីភិសេកជាតកំ និដ្ឋិតំ" ប្រែថា ជាលីភិសេក ចប់ហើយ ។ ដូច្នេះ គួរយល់ថា ឯកសារទាំងពីរ អ្នកនិពន្ធបង់របនារឿងជាតកមួយ ដូចជាតកនានាដែរ ។

គប្បីយល់ថា រឿងនេះមិនមែនជារឿងចាស់បុរាណ ដូចមហាវេស្សន្តរជាតកបាលីទេ គឺអ្នកនិពន្ធ ទើបនិពន្ធឡើងជំនាន់ក្រោយ នៅដែនដីខែត្រឥណ្ឌូចិននេះឯង ។

ចុះលេខ ១០២០ ។

អត្ថបទផ្តើម ផុដកស្ស ពេលរំ ទេវិតពុំ ។ នេះយើងថាថ្ងៃសំដែងអំពី ថ្ងៃ ខែ ឆ្នាំ ផុដកព្រឹទ្ធាចារ្យ ឲ្យអស់មហាជនផងទាំងពួង បាន ដឹងច្បាស់ប្រាកដ កំណត់ឈ្មោះ ម្តាយអាពុកផុដក តាមវារៈ ព្រះបាលីថាដូច្នេះ ផុដកស្ស បិតា គោលគោ នាម ព្រាហ្មណោ ។ រីឯអាពុកផុដកព្រាហ្មណ៍ ឈ្មោះគោលកៈ ព្រាហ្មណ៍ ម្តាយគាត់សោតឈ្មោះ នាងចន្ទ្រីព្រាហ្មណី អាពុកធំខាងម្តាយឈ្មោះ គោវន្ទ្រីព្រាហ្មណ៍ ម្តាយធំគាត់នោះ ឈ្មោះនាងអច្ចរីព្រាហ្មណី ។ . . . .

. . . . . ។ល។ . . .

អត្ថបទបញ្ចប់ ឯចៅពហុលកុមារក្តី នាងឧប្បលវណ្ណាក្តី សឹងបាន ចូលទៅបួសសំណាក់នៃព្រះមហាករុណា ចម្រើននូវវិបស្សនា កម្មដ្ឋាន សឹងបានលុះមគ្គផលដល់ព្រះអរហត្ត សម្រេចនូវព្រះ និព្វានដ៏សុខក្សេមក្សាន្ត ប្រែប្រាសនិរាសចាកទុក្ខ ។ បាន នូវសេចក្តីសុខ ប្រសើរនោះទៀងប្រាកដហោង ។ ផាលីអភិ-សេកំ និដ្ឋិតំ ។ រីនិពណ៌នា អំពីផាលីអភិសេកនេះមិញ ។ និដ្ឋិត ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ។

បំណងជើង «សាស្ត្រា ត្រៃយុទ្ធ[1]»

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង បលនាព្រាហ្មណនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ផ្ទៃ មាន ២១ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តបឹងខ្យាង ខេត្តកណ្ដាល ចុះលេខឯកសារ ១០២៧ ។

អត្ថបទដើម នមោ តស្ស ។ ក្នុំ ។ នេះទីងស្រដ៏អំពីកំណើតផ្ទៃក្រោម ។ មានតែពីរនាក់ប្ដីប្រពន្ធ ឯប្ដីឈ្មោះអាទុក្កពេ ឯប្រពន្ធ

---

១ សាស្ត្រាត្រៃយុទ្ធនេះ ជាចលនាអក្សរសាស្ត្រព្រហ្មនិយមមួយទៀត ដែលជាមតិកសម័យអង្គរ ដែលបានសេសសល់ គង់មកយើងឥឡូវនេះ ។ ចលនាអក្សរសាស្ត្រនេះ នាំឱ្យយើងបានដឹងនូវជីវប្រវត្តិនៃតួអង្គសំខាន់ ៗ ខ្លះ ក្នុងរឿងរាមកេរ្តិ៍ខ្មែរ ឧ. ដូចនាងសីតា ក្រុងរាពណ៍ ហនុមាន ពាលី សុគ្រីព ជាដើម ។

ចុះពាក្យថា «ត្រៃយុទ្ធ» មានន័យដូចម្ដេច? គេអាចបកប្រែថា «ចម្បាំងទាំង ៣» មានន័យថា ចម្បាំងដែលកើតឡើងក្នុងលោកទាំង ៣ (មនុស្សលោក, ទេវលោក, និងបាតាល)។ ប៉ុន្តែក្នុងផ្ទៃឯកសារ គ្មាននិយាយពីចម្បាំងរាំងជលធំដុំ ដូចរឿងរាមកេរ្តិ៍ទេ គ្រាន់តែបញ្ជាក់ពីជីវប្រវត្តិនៃតួអង្គ និងឫទ្ធិអានុភាពផ្សេង ៗ នៃតួអង្គទាំងតូចផ្សេងៗ ប៉ុណ្ណោះ ។

អានុភាព អ្នកទាំងពីរបង្កើតបានកូន ៣ នាក់ ឈ្មោះសង្កែកា ១ ឈ្មោះរេជា ១ ឈ្មោះគមោ ១ ៗ ឯសង្កែកានោះ បង្កើតជាព្រះព្រហ្ម ឯរេជា បង្កើតជាព្រះពៃស្រពណ៍ ឯគមោនោះ បង្កើតជាព្រះឥស្វរ ៗ អ្នកទាំង ៣ នេះត្រូវជាជីដូនមួយ សឹងមានរិទ្ធិអានុភាពដូចគ្នា ៗ . . . . . .

. . . . ៗល ៗ . . . .

អត្ថបទបញ្ចប់ រីឯក្រុងពាលីនូវសុគ្រីពនេះ ព្រះអាទិត្យអ្នកមករណ្តាប់នគរទីមខាស់បុរីឲ្យទៅហើយ ព្រះអាទិត្យរកស្ពានរឯណាមានរិទ្ធិច្រើននោះ ឲ្យជាសេនាយោធាក្រុងពាលីនូវសុគ្រីពនោះសោតសឹងមានរិទ្ធិតេជះអានុភាព អាចកម្រាបទេវតាអសុរយក្ខយក្ខីឃ្នង បីនូវមកប្រឡងផងអ្នកទាំងពីរនោះ ពុំបានឡើយ អ្នកសោយរាជ្យនៅនគរទីមខាស់បុរីនោះហោង ៗ

ហៃសាធុសប្បុរសផងទាំងឡាយអើយ ចូរស្តាប់អតិប្រាយបរិយាយត្រៃយុទ្ធនេះមិញ ៗ ឥតបការេន ស្វរេបជោយនូវប្រការអម្បាលណោះឯងហោង ៗ

បំណងជើង "សាស្ត្រា ត្រៃលោកវិត្ថារ(១)"

អ្នកនិពន្ធ រកមិនបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យរាយ លំនាំទេសនា ។

ប្រភពរឿង អំពីប្រភពនៃលោកទាំង ៣ (ទេវលោក មនុស្សលោក និងអបាយភូមិ) ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ៤ ផ្សែ គឺផ្សែទី ១ មាន ១០ សន្លឹក, ទី ២ មាន ៨ សន្លឹក, ទី ៣ មាន ១៣ សន្លឹក, ទី៤ មាន ១២ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តបន្ទាយក្រោក ខេត្តពោធិសាត់ ចុះលេខ ៩៨២ ។

អត្ថបទដើម នមោ តស្ស ។ បឋមំ សត្តវិញ្ញាណំ បណ្ហំ វិសជ្ជនំ ឥតិ អនុសន្ធិ ។ ព្រះធម៌វិសេសទេសនា ជាសណ្ដាប់របៀបរាប់

---

១ ឯកសារនេះ ដើមឡើយប្រហែលជាចង់បង្ហាញអំពីទស្សនៈខាងព្រហ្មញ្ញសាសនា ចំពោះកំណើតនៃត្រៃលោកនេះ ។ ប៉ុន្តែក្រោយមកប្រហែលជាអ្នកប្រាជ្ញខាងពុទ្ធនិយម ចង់បង្ហាញទស្សនៈនិងគោលការណ៍ខ្លះ តាមលក្ខណៈពុទ្ធនិយម ដូចជាខាងពួកព្រាហ្មណ៍និយមយល់ថា លោកនេះកើតឡើងដោយព្រះព្រហ្មទ្រង់សាងឡើង ។ ឯទស្សនៈពុទ្ធនិយមយល់ថា កើតឡើងដោយសង្ខារលោកជាដើម ។ ដូច្នេះយល់ថា ចលនានៃគោលការណ៍នេះ មានលក្ខណៈជាចម្រុះ ។

គំណត់តាម លំអានឋានដែលអង្គសម្ដេចព្រះជិនវង្សទ្រង់សំដែង ក្នុងគម្ពីរលោកវិត្ថារៈ បានជាមានសេចក្ដីបទព្រះបាលី ក្នុងបទ សតិវិញ្ញាណ សួរប្រស្នាទិងសតិបញ្ញា ជាពាក្យបុច្ឆា វិស្សជ្ជនាៗ សតិវិញ្ញាណសួរថា តើអ្នកសតិបញ្ញា ផែនដីដែលមនុស្សលោក រស់នៅនេះ តើនរណាសាងជាដំបូង ៗ ឆ្លើយថាគ្មាននរណា សាងទេ ៗ បើមិនមាននរណាសាងតើកើតឡើងដោយសារ ហេតុអ្វី? ឆ្លើយកើតឡើងដោយសង្ខារ ៗ សួរថាសង្ខារមាន ប៉ុន្មានយ៉ាង? ឆ្លើយថា សង្ខារមានពីរយ៉ាង ៗ ពីរយ៉ាងគឺអ្វីខ្លះ? ឆ្លើយថា សង្ខារធម៌ ១ សង្ខារលោក ១ ៗ . . . . .

. . . . . ៗលៗ . . .

អត្ថបទបញ្ចប់ ទើបព្រះនាគសេនត្រេមកគិតថា យើងនឹងសិតរូបព្រះបដិមាទុកឲ្យជាទីសក្ការបូជា ៗ ក្នុងគ្រានោះ ព្រះឥន្ទ្រាធិរាជ ទៅនាំយកកែវមរកត អំពីកំពូលភ្នំវិបុលបព៌តមកថ្វាយព្រះនាគសេន ៗ ព្រះវិស្សុកម្មទេវបុត្រ មកនិមិតជាជាងសិតព្រះកែវ-មរកត ទេវតាទាំងឡាយធ្វើសក្ការបូជា ហើយប្រទក្សិណពីឆ្វេងមកស្ដាំ ៣ ជុំគ្រប់ហើយ ក៏ក្រាបទៅកាន់វិមានរបស់ខ្លួនៗ សំដែងមកនេះ ជាសង្ខេបតែប៉ុណ្ណោះហោង ៗ

បំណងជើង "សាស្ត្រា ព្រះសុរូបជាតក(១)"

អ្នកនិពន្ធ គេពុំទាន់ឃើញ

កាលបរិច្ឆេទ គ្មានបញ្ជាក់កន្លែងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ លំនាំទេសនា ។

ប្រភពរឿង បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ១០ ខ្សែ គឺខ្សែទី១ មាន ២៥ សន្លឹក, ខ្សែទី២ មាន ២២ សន្លឹក, ខ្សែទី ៣ មាន ២៣ សន្លឹក ។ ខ្សែទី៤ មាន ១៨ សន្លឹក, ខ្សែទី៥ មាន ១៦ សន្លឹក, ខ្សែទី៦ មាន ១៦ សន្លឹក, ខ្សែទី៧ មាន ១៩ សន្លឹក, ខ្សែទី៨ មាន ២០ សន្លឹក, ខ្សែទី៩ មាន ១១ សន្លឹក, ខ្សែទី ១០ មាន ១៦

---

១ ចលនានៃជាតកនេះ ស្របទៅតាមលក្ខណៈពុទ្ធនិយមដោយច្រើន ព្រោះតួអង្គសំខាន់ ៗ ជាពិសេសតួអង្គព្រះពោធិសត្វ បានរិតរំរែរកមធ្យោបាយ ដោយស្រាយបញ្ហាស្មុគស្មាញ ឬវិបត្តិផ្សេងៗ ក្នុងសង្គមមនុស្ស ដោយសន្តិវិធីជានិច្ច ។ ក្នុងផ្ទៃរឿងជាតកនេះ មាននិទានខ្លីៗជាច្រើន សម្រាប់ធ្វើជាឧទាហរណ៍ដោះស្រាយវិបត្តិ ឬឧបសគ្គតូច-ធំទាំងឡាយ ដែលកើតឡើងក្នុងសង្គមមនុស្ស ។ ជាតកនេះ អ្នកនិពន្ធបានបញ្ជាក់ថា ព្រះពោធិសត្វកសាងបារមី ។ ម្ល៉ោះ ជាតកនេះមានលក្ខណៈប្រហែលនឹងរឿងលោកនយជាតក ឬមហោសថជាតកដែរ ។

ឯកសារនេះ ប្រហែលជាកើតឡើង ២–៣ សតវត្សរ៍មកហើយ ។ បានជារបៀបអក្ខរាវិរុទ្ធ ប្លែកផ្សេងពីសតវត្សរ៍ទី ១៩ ឬ ២០ នេះច្រើន ឧ ក្បក្បើ (ក្អែកអើយ) ន្ទុះ (នោះ ឬ នុះ) ឥសព្រើ ឬ ឥព្រើយ (អស់ត្រី) . . .)

សន្ទឹក ចុះលេខ ៨៥៣ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត ព្រៃពេង ខេត្តកណ្ដាល ។

**អត្ថបទផ្ដើម** នមោ តស្ស ខិជាខសេដ្ឋិមហណ្ឌិ ឥទំ សត្ថា រាជគហញ្ច កោសម្ពិយញ្ច អន្ទកា ឃោសិតារាមេ វិហរន្តោ អត្តនោ បញ្ញាបសំសនំ អារព្ភ កថេសិ ។ នេះទឹងសំដែងថ្លែងនិទាន នៃព្រះសុរូបជាតក តាមអាថិព្រះបាលី ។ សត្ថា រីឯសម្ដេចព្រះបរមគ្រូ នៃទេវតានិងមនុស្សព្រហ្មយមយក្ខ សព្វអនន្តរចក្រវាឡ ។ វិហរន្តោ កាលព្រះអង្គគង់នៅនៃឃោសិតារាម ដ៏ជាចុងខេត្តចំណតដូនគរកោសម្ពី តដែននគររាជគ្រឹះ ទើបព្រះអង្គប្រារព្ធនឹងភិក្ខុសង្ឃទាំងឡាយ សរសើរបញ្ញាបារមីនៃព្រះអង្គ ។ .

. . . . . ។ល។ . . .

**អត្ថបទបញ្ចប់** រីព្រះវិស្ណុកម្មទេវបុត្រ ក្រឡាប់ជាតិចេរវិលវិញមក គឺព្រះនន្ទត្ថេរ ។ រីព្រះវរមាតាបិតាក្រឡាប់ជាតិចេរវិលវិញមក គឺព្រះមហារាជសកល(?) ប្រសើរហោង ។ រីព្រះសុរូបកុមារដ៏ជាព្រះអនុជ ក្រឡាប់ជាតិចេរវិលវិញមក គឺព្រះមហាអានន្ទត្ថេរ។ ឯព្រះសុរូបតាបស ក្រឡាប់ជាតិចេរវិលវិញមក អហមេវ គឺព្រះតថាគតប្រាកដហោង ។ សម្មាសម្ពុទ្ធោ (ជាព្រះសម្មាសម្ពុទ្ធ) ទ្រង់ត្រាស់សំដែងនូវជាតកនេះ ។ ព្រះអង្គសំដែងព្រះធម៌

វិសេសទេសនា ដូចមានពណ៌នាមក ។ ឯរំ ក៏មានដោយប្រការនេះហោង

សុរូបជាតកំ និដ្ឋិតំ ។ បពិត្រអើយ អាត្មាសំដែងព្រះធម៌វិសេសទេសនា គម្ពីរព្រះសុរូបជាតកនេះមិញ ។ និដ្ឋិតំ ស្រេចបរិបូណ៌សម្បូរសមគួរ ដោយនូវវេលានេះហើយហោង ។

—X—

បំណងជើង «សាស្ត្រា ត្រៃភេទ(១)»

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់កន្លងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ។

ប្រភេទរឿង ចលនាព្រាហ្មណនិយម ។

---

១ សាស្ត្រាត្រៃភេទនេះ តាមឈ្មោះគួរមានន័យបញ្ជាក់ អំពីគម្ពីរវេទទាំង ៣ របស់ព្រាហ្មណ៍ ប៉ុន្តែក្នុងផ្ទៃអត្ថបទ បែរជានិយាយបញ្ជាក់អំពីប្រវត្តិ ឬ កំណើតនៃតួអង្គផ្សេងៗ ដែលមានឫទ្ធិខ្លាំងពូកែអស្ចារ្យ ដូចក្រុងរាពណ៍ នាងសីតា ពាលី សុគ្រីព ហនុមាន និង អង្គទជាដើម ។ ដូច្នេះអត្ថបទ នៃត្រៃពេទនេះមានន័យផ្ទុយនឹងសាស្ត្រាត្រៃយុទ្ធ ខាងលើនេះដែរ ។ ប៉ុន្តែឯកសារត្រៃយុទ្ធមានត្រឹម ២១ សន្លឹក ឯឯកសារត្រៃភេទនេះ មានដល់ ៣០ សន្លឹក ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣០ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តអង្គ អង្គតាសោម ខេត្តតាកែវ ចុះលេខ ៨២៣ ។

**អត្ថបទផ្ដើម** ពទ្ធមថាជាតាទត្តិយោ អនុកពេតិយោ បុត្ត ជាយទ្តិ សត្តិកោ រជោ តមោតិ(១) . . . . ។

នេះនៅថ្ងៃកំណើតផ្ទៃក្រោមឲ្យជាប្រាកដ គប្បីអ្នកផងទាំងឡាយដឹង ។ ដើមឡើយមានតែពីរនាក់ប្ដីប្រពន្ធ ។ ឯប្ដីឈ្មោះអនុកពេ បពិត្រឯប្រពន្ធនោះឈ្មោះនាងអនុកព បង្កើតផ្ទៃក្រោមបរិបូណ៌ហើយ ទើបបង្កើតបុត្ត ៣ នាក់ ឈ្មោះសត្តិកោ ១ ឈ្មោះរជោ ១ ឈ្មោះតមោ ១ ឯសត្តិកោ បង្កើតព្រះព្រហ្ម រីឯរជោ បង្កើតព្រះពៃស្រពណ៌ ឯតមោ បង្កើតព្រះឥសូរ ។ . .

. . . . ។ល។ . . , .

**អត្ថបទបញ្ចប់** រីឯនាងបូរចន្ទនោះមិញ ហេតុតែម្ដាយខឹងផង ផ្ដាសាសាដានថាឥឡូវ ដូចេះទាក់ក្អែកទាំងពីរហោង ។ ថាបើព្រះពាយបក់មកនាំកស្ទុ៊ីៗ ដល់មាត់នាងៗ ឆ្ចូលទៅហោង ។ រីឯនាងបូរចន្ទនោះ ព្រះពាយបក់នាំកំលេសព្រះឥសូរមកចូល

---

១ អត្ថបទខាងលើនេះ មិនសូវមានលក្ខណៈត្រឹមត្រូវតាមវេយ្យាករណ៍បាលី សព្វថ្ងៃនេះទេ។ សូមធំរាបថា ឯកសារនេះប្រហែលកើតឡើងក្នុងសម័យអង្គរដែរ តែមិនចប់សព្វគ្រប់ទេ។

មាត់នាង ។ នាងទ្រង់គភ៌ប្រសូត្រជាហនុមានហោង ។ រីឯក្រុងពាលី នូវសុគ្រីពនោះ ព្រះអាទិត្យមករណ្តាប់នគរខាស់ខិនបុរីឲ្យនៅហើយ ព្រះអង្គឲ្យពានរឯណាមានឫទ្ធិច្រើនឲ្យជាសេនាយោធា ក្រុងពាលីនិងក្រុងសុគ្រីពហោង ។ ឯពាលីនូវសុគ្រីពនោះសោត សឹងមានឫទ្ធិអានុភាពអាចបង្ក្រាបនូវអស់ទេព្តា នូវអស់អសុរយក្ខយង់ឃ្មឹងផងទាំងឡាយ ឯណាឥតបីស្មើបានឡើយ សឹងមកប្រឡងគេផងអ្នកទាំងពីរពុំបានឡើយ ហើយអ្នកឲ្យនៅនគរខាស់ខិនបុរី សោយរាជ្យនៅនាឋាននោះ ឥឡូវនេះហោង ។

—X—

បំណងជើង “សាស្រ្តា ចន្ទបរិត្ត សុរិយបរិត្ត(១)„

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ៍ ពាក្យកាយ លំនាំទេសនា ។

---

១ ឯកសារនេះ បានពោលបញ្ជាក់ អំពីបុព្វកម្មនៃព្រះចន្ទ និង ព្រះអាទិត្យ និងអសុរិន្ទរាហូ ដែលអ្នកនិពន្ធទុកជាក់ជាទេវៈ អំពីដំណើរចរយាត្រាព័ទ្ធជុំវិញភ្នំព្រះសុមេរុ អំពីទ្វីបទាំង៤ អំពីទំហំខ្លួននិងអវយវៈនៃរាហូ អំពីចន្ទ្រគ្រាះសូរ្យគ្រាះ នៅទីបំផុត អ្នកនិពន្ធបញ្ជាក់ថា ព្រះអាទិត្យព្រះចន្ទឋិតនៅជានិច្ច ដល់ភ្លើងឆេះកប្ប ទើបឡើងទៅឋិតនៅក្នុងឋានព្រហ្មលោក ។

ឯកសារនេះ ប្រហែលអ្នកមានគំនិតចង់ដោះស្រាយវិបត្តិដែលកើតឡើងដល់ផ្លូវចន្ទ និងផ្លូវអាទិត្យ ក្នុងគ្រាបានចន្ទគ្រាះ—សូរ្យគ្រាះទេដឹង? ។

ប្រភពរឿង គម្ពីរគាណវារៈបាលី (សូត្រមន្ត) ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១២ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត តាកកាក (កណ្តាល) ចុះលេខ ៩៩៥ ។

អត្ថបទផ្តើម នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឯវម្មេ សុតំ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ ឯវំ សុតំ វិសូត្រនេះ មេ គឺ អញ្ញខ្ញុំ អានន្ទត្ថេរ ឈ្មោះអានន្ទត្ថេរ សុតំ ក៏បានស្តាប់ អំពីកាលសម្តេចព្រះសាស្តាចារ្យ សារពេជ្ញតាញាណ ព្រះអង្គ បានត្រាស់ព្រះធម៌វិសេសទេសនាប្រោសទេវតា នូវមនុស្សសត្វ ផងទាំងឡាយ ។ ឯកំ សមយំ នាកាលសម័យ ។ . . .

. . . . . ។ល។ . . . .

អត្ថបទបញ្ចប់ លុះតែប្រថពីនេះ កើតភ្លើងឆេះកល្បអស់ទាំងសែនកោដិ ចក្រវាឡនោះ ទើបព្រះចន្ទព្រះអាទិត្យក៏នឹងឃ្លាតចេញចាកវង់ ហើយនឹងឡើងទៅនៅមហាព្រហ្មវេហប្ផលា ទិងអាកស្សព ឲ្យ រម្ងងអណ្តាតភ្លើងឆេះកល្បនោះហោង ។

ទេសនាបរិយោសានេ លុះចប់ព្រះធម៌វិសេសទេសនាព្រះដ៏មាន បុណ្យហើយ ព្រះបាទបសេនទិកោសលរាជ នូវអស់បរិពារ

ផងទាំងឡាយ នូវអស់អរហន្តា វីណាស្រពផងទាំងឡាយ ក៏បានលុះមគ្គផល បានដល់ព្រះនិព្វាននោះទៀតប្រាកដហោង ។ ចន្ទបវត្ត សុរិយបវត្តិ និទ្ទំ ។ បពិត្រអើយ នេះនឹងស្រដីនិទាន អំពីព្រះច័ន្ទព្រះអាទិត្យនេះមិញ ក៏ស្រេចនូវប្រការអម្បាលណោះហោង ។

—X—

បំណងជើង «សាស្ត្រា អានិសង្សខ្សាច់(១)»

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ លំនាំទេសនា ។

ប្រភពរឿង ប្រពៃណីនិយមខ្មែរ និងចលនាពុទ្ធនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ២៧ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តកោកកាក (កណ្ដាល) ចុះលេខ ១.៩៥ ។

---

១ អានិសង្សខ្សាច់នេះ ប្រហែលអ្នកនិពន្ធ ទើបតែរៀបរៀងឡើងក្នុងសម័យក្រោយ ជាពិសេសក្នុងសម័យ ឬក្នុងសតវត្សរ៍ ដែលគេបាននិពន្ធគម្ពីរបញ្ញាសជាតក ។ ឯកសារនេះប្រហែលបានចាប់កំណើតឡើងក្នុងដែនដីឥណ្ឌូចិននេះឯង ។

**អត្ថបទផ្តើម** នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ឯកស្មឹ កិរ សមយេ សត្ថា ជេតវនេ វិហរន្តោ ភិក្ខូហិ បរិវុតោ។ កោសាធុកេ បពិត្រសប្បុរសផងទាំងឡាយអើយ ។ កិរ ដូចយើងបានឮមកនោះឯង ។ ឯកស្មឹ សមយេ លុះមានកាលសម័យថ្ងៃមួយ ។ សត្ថា រីសម្តេចព្រះសារពេជ្ញតាញាណ ដ៏ជាគ្រូនៃទេវតាអសុរមនុស្សផងទាំងឡាយ ។ វិហរន្តោ ទោះ ចតូសុ ឥរិយាបថេសុ វត្តមានោ កំស្តេចគង់សម្រេចសម្រាន្តខាននូវឥរិយាបថ . . . ។ល។ . . .

**អត្ថបទបញ្ចប់** ទេសនាបរិយោសានេ សាត្ថិកា ធម្មទេសនា សោតាបត្តិផលាទីនិ បាបុណឹសុ ពហូ ជនាតិ ។ បពិត្រអើយ កាលណាស្រេចព្រះធម៌វិសេសទេសនា ព្រះដ៏មានបុណ្យហើយ រីអស់មហាសប្បុរសទាំងឡាយ ក៏សឹងបានលុះសោតាបត្តិផលជាដើមក្នុងកាលណោះឯងហោង ។

ពាលុកាចេតិយានិសំសវណ្ណនា និដ្ឋិតា ។ បពិត្រអើយ នេះនឹងសរសើរផលានិសង្ស នៃអ្នកបានសាងភ្នំខ្សាច់នេះមិញ និដ្ឋិតំ ឥតិបការេន ក៏ចប់ជាស្រេច នូវប្រការអម្បាលណោះឯងហោង ។

ចំណងជើង  "សាស្ត្រា ក្រមពលទេព[១]"

អ្នកនិពន្ធ  រកពុំបានឃើញ ។

កាលបរិច្ឆេទ  ម.ស. ១៦១៥ ស័ករកានក្សត្រ ៣ កើត ខែកត្តិក ថ្ងៃ ចន្ទ (រជ្ជកាលព្រះជ័យជេស្ឋា គ.ស. ១៦៩៣ ។

របៀបនិពន្ធ  ពាក្យកាយ ច្បាប់ក្រិតក្រមផ្សេង ។

ប្រភពរឿង  គម្ពីរព្រះធម្មសាស្ត្រ អំពីបុរាណ ។

លក្ខណៈឯកសារ  សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៩ សន្លឹក ។ ឯកសារនេះ បានជាអក្សរជ្រៀង ១ ទំព័រ មាន ៥ បន្ទាត់ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តកណ្ដាលជុំ ខេត្តកំពង់ស្ពឺ ចុះលេខ ៩៨៣ ។

អត្ថបទផ្ដើម  សុភមស្តុ . . . ពហុលទេស្ឋាជយាតិរេក ១៦១៥ ស័ករកានក្សត្រ ៣ កើត កត្តិកមាស ចន្ទវារ សុភមហោតិ មហាឡាភានុកូល សម្បូរវិបុលផលអំពីព្រះរាជហឫទ័យនៃសម្ដេចព្រះបាទព្រះរាជឱង្ការ ព្រះជ័យជេស្ឋា ព្រះមាត់ស្វរបរមបវរទ្ធកម្មទ្ធក-

១ ក្រមពលទេពនេះ ស្ដីអំពីបទចោរកម្ម មានការលួចស្រូវអង្ករ ឬប្រដាប់ធ្វើស្រែជាដើម ដែលត្រូវមុខងារ ពហុលទេពជំនុំជំរះកាត់ទោសតាមក្រមនេះ ។

ច្បាប់នេះ អ្នកចម្លងបានបញ្ជាក់ថា បានចប់នៅថ្ងៃ ១២ កើត ខែមិគសិរ ឆ្នាំកុរបញ្ចស័ក ។

នាថ បរមខត្តិយជាតិសុរិយោវង្ស . . . ទើបព្រះបាទព្រះបរម
នាថបរមបពិត្រ បើកព្រះឧស្សទិព្វថៃ្ង បន្ទូលព្រះរាជឱង្ការបរម
សារពេះនេះ ។

វនឹងស្រដី ឯច្បាប់ក្រមពលទេពនោះ ឲ្យទុកញាតិពហុលទេព
ឆ្វេងស្ដាំ នូវស្រីសុរិយាវង្ស នូវទុកញាតិត្រគ្រាធិបតី ជាទៅហ្វាយ
ពលទេពឆ្វេង ស្ដាំ . . . ។ល។ .

អត្ថបទបញ្ចប់ មាត្រា ១ ទោះទៅក្រមជង ឯងធ្វើក្ដីអស់ទៅនោះ ច្បាប់
ឲ្យយកហត្ថសុញមករាស់ខាតឃាង នូវខាតនោះ នូវខាតឈើ
អណ្ដាត នូវខាតបើនោល នូវខាតប្រុស នូវខាតប្រុងនោះ
កុំឲ្យយកខាតព្រះសពលាក់ឡើយ កុំឲ្យយកខាតមន្ត្រីឡើយ
កុំឲ្យយកខាតតូចឡើយ កុំឲ្យយកខាតស្រីឡើយ ។ បើទៅ
ក្រមឯណា កុំធ្វើដូចព្រះរាជក្រិត្យ សោយស្រាស្ត្រនេះឡើយ
ឲ្យបន្ទតទៅក្រមនោះចេញ អំពីការ ហើយឲ្យពិន័យអន្ដព្រះពហុ
សត្តិនោះហោង ។

—X—

បំណាំងជើង សាស្ត្រា ច្បាប់ព្រះរាជក្រឹត្យ ក្រមឥរិយា(១)

១ ឯកសារនេះ មានបញ្ជាក់នាមអ្នកចារចម្លងថា ខ ញ៉ាតិកក្សេនិយ ចារចប់ព្រះរាជក្រិត្យ នៅថ្ងៃ ៣ កើត ខែអស្សុជ ឆ្នាំមមីចត្វាស័ក ព្រះពុទ្ធសាសនាកន្លងទៅហើយបាន ២៤២៨ ព្រះវស្សា ខែកន្លងទៅហើយបាន ៥ ខែ ថ្ងៃកន្លងទៅបាន ២១ ថ្ងៃ ។

**អ្នកនិពន្ធ** គេពុំមានឃើញ ។

**កាលបរិច្ឆេទ** ម.ស. ១៦១៥ ឆ្នាំរកានក្សត្រ ១០ រោច ខែកត្តិក ថ្ងៃចន្ទ (ក្នុងកាលព្រះជ័យជេដ្ឋា គ.ស. ១៦៩៣) ។

**របៀបនិពន្ធ** ពាក្យកាយ ក្រឹត្យក្រមជើង ១ ។

**ប្រភេទរឿង** គម្ពីរធម្មសាស្ត្រ ពីបុរាណ ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត ១ ផ្លូវ មាន ១០ សន្លឹក ចារជាអក្សរជ្រៀង ដូចឯកសារមុននេះដែរ ។ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តកណ្ដាលជុំ ខេត្តកំពង់ស្ពឺ ចុះលេខ ៩៨៣ ។

**អត្ថបទផ្ដើម** សុភមស្តុ សួស្តីស្រីសុភមង្គល ពហុលជេស្ឋាជយាតិរេក ១៦១៥ ស័ក រកានក្សត្រទាំងនោះ បរយោ(?) កត្តិកមាសា ពារបន្ទ្រ សុភមហាតិមហោជយាទុក្ខល ផុលអំពីព្រះរាជហឫទ័យ នៃព្រះបាទសម្ដេចរាជឱង្ការ ព្រះជ័យជេស្ឋាពមាឥស្វរ បរមសាខ្ទុក្ខទ្ធ បរមចិត្តយសុរិយោវង្ស ពង្សក្សត្រជាធិបតី ។ មាត្រា ១ នោះបើអ្នកឯណាយកស្រីនោះជាប្រពន្ធ ហើយយកទាំងបងទាំងប្អូនបង្កើតក្ដី ក្មួយបង្កើត ម្ដាយមីងបង្កើតក្ដី យកក្មួយដោយពង្ស ម្ដាយមីងដោយពង្សក្ដី សូមកូនជាកូនធំឡើង យកជាប្រពន្ធក្ដី បើកូនដើមយកគ្នាជាប្ដី ជាប្រពន្ធក្ដី អស់ទោស

រាំទាំងនោះឲ្យភ្ញាក់ការលក់សុបិនបង់ ហើយរឹបទ្រព្យរបស់ផង ។

**អត្ថបទបញ្ចប់** មាត្រា ១ សោត ទោះអ្នកផងឯណា បើកស្រីទាំងបង ទាំងប្អូនបង្កើតទាំង ២ នោះក្តី បើយកមានកូនហើយលែងក្តី ទោះស្លាប់ក្តី ហើយយកឯប្អូនទៀតក្តី ទោះយកប្អូនមានកូន ទោះលែង ទោះស្លាប់ក្តី ហើយទៅយកឯបងវិញក្តី ទោះម្តាយមីងហើយទៅក្មួយផងក្តី ទោះយកឯណាមានកូនហើយស្លាប់ក្តី លែងក្តី ទោះយកជីដូនហើយយកចៅផងក្តី ទោះសុំកូនគេជាកូន ធំឡើងវិលមកជាប្រពន្ធក្តី ទោសរាំទាំងនេះ ហៅជ្រះពជ ឲ្យភ្ញាក់ការលក់សុបិនទិមួយខ្លួន ហើយរឹបយកទ្រព្យរបស់ផង ជាដង្វាយព្រះបាទអ្នកជាអម្ចាស់ហោង ។

—X—

**បំណងជើង** „សាស្ត្រា រតនមាលា(១)„

**អ្នកនិពន្ធ** រកពុំទាន់ឃើញ ។

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**របៀបនិពន្ធ** ពាក្យរាយ លំនាំទេសនា ។

---

១ ផ្នែកទី ១ អ្នកនិពន្ធបានធ្វើសេចក្តីពន្យល់ ឬ បកស្រាយនូវអត្ថបទពុទ្ធគុណ ធម្មគុណ និង សង្ឃគុណ ប៉ុន្តែលើកយកព្យញ្ជនៈ ១ តួ ១ នៃអត្ថបទមកពន្យល់ ។

ឯផ្នែកទី ២ ជាពាក្យចោទឆ្លើយ បំភ្លឺពីគោលលទ្ធិពុទ្ធនិយមខ្លះ ។

ប្រភពរឿង ឥទ្ធិពល ពុទ្ធនិយម ។

លក្ខណៈ ឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១៨ សន្លឹកកន្ទុះ ជាផ្នែក១ ឯផ្នែក ១ទៀតជាខាងចុងមាន ១១ សន្លឹក ។ ឯកសារនេះពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តចុងកោះជ្រុក ខេត្តកំពង់ចាម ចុះលេខ ៩៨៩ ។

អត្ថបទផ្ដើមទី១ ឥត្តោ សព្វញ្ញុតញ្ញាណោ ឥច្ចន្តោ អាសវក្ខយំ ឥត្ថ ធម្មំ អនុប្បត្តោ ឥទ្ធិមន្តំ នមាមិហំ ។ . . . .

ឥ គឺព្រះអង្គប្រាជ្ញថ្លាប្រាជ្ញាសព្វញ្ញុតញ្ញាណ គ្មានធុញថប់ត្រឡប់ថយក្រោយ ពុំមានខ្លោយទាល់តែបានក្ស័យអាសវៈ ត គឺព្រះអង្គធ្ងន់ទូរលោកទាំង ៣ ទូរអន្ទង់ទាំង ៣ . . . .

. . . . . ។ល។ . . . .

អត្ថបទបញ្ចប់ទី១ ប្រែព្រះសង្ឃគុណ ១៤ បទជាសង្ខេបតែប៉ុណ្ណោះ ។ លោកដែលពណ៌នាសរសើរគុណកែវទាំង ៣ រៀងកបចងចាប់ខ្ជាប់ជាប្រក្រតី :លោកនុះប្រសើរក្រៃលែង សត្វទាំងដទៃនានាហេតុត្បិតនឹងបានអប្បនាសមាធិឈាន ដាក់ពួលឈានទាំងពួង ។ បើបានដល់អប្បនាសមាធិ ដូចសត្វស្វាបលាស្វាបរេកប្រុងហើរឡើងទៅទិសនេះទិសនោះ ។ បើពុំដូច្នោះទេ ដូច

កន្ទុំដឹងក្លិនផ្កានៅទិសណា ៗ ហើយហើរសំដៅទៅទិសនោះ ៗ ដល់ហើយ ក៏ហើរក្រឡឹងវិលវល់ ប្រុងតែនឹងចូលចាប់ជញ្ជប់កេសរផ្កា ឯឧបចារជ្ឈាន ក៏ដូច្នោះដែរ ៗ ពីរបៀបដែលប្រែមកដូច្នេះ ឈ្មោះគេនមាលា ។

**អត្ថបទផ្ដើមផ្នែកទី២** នមគ្គ គេនគ្គយស្ស ៗ គ្រានេះនឹងបានអធិប្បាយដោះស្រាយក្នុងសទ្ទមបញ្ហា តាមដោយពាក្យដែលសួរថា អើដែលជាធម៌ ៗ ទុះអ្វីជាធម៌ ដែលល្អ ក៏ថាល្អ ដែលអាក្រក់ ក៏ថាធម៌ ដែលមិនល្អ មិនអាក្រក់ ក៏ថាធម៌ដែរ ៗ . . .

. . . . . ។ល។ . . .

**អត្ថបទបញ្ចប់ផ្នែកទី២** មគ្គ ដែលសម្លាប់សំយោជនៈ នូវកិលេសដូចឈើកាត់តែដើម ៗ ផលដែលកាត់ ដូចដែលកាត់ហើយរំលើងឫសគល់ចេញ សេចក្ដីនេះក៏ដូចគ្នា ៗ បណ្ឌិតជាតិដែលប្រកបដោយប្រាជ្ញា គប្បីចូលចិត្តតាមន័យដែលសំដែងមកនេះ ៗ ផល ៤ និយមដោយប្រយោគបស្សទ្ធិ ត្បិតជាអ្នករម្ងាប់ ៗ មួយវិញទៀត មគ្គជាហេតុ គឺជាលោកុត្តរកុសល ឯផលជាលោកុត្តរវិបាក ត្បិតមគ្គជាហេតុ ឲ្យទុំនៃផល ៗ

បំណងជើង „សាស្ត្រា ព្រះសន្ធបត្ត(១)„

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង គម្ពីរ បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៥ ខ្សែចប់ ដុំជាតក់ ។ ខ្សែទី១ មាន ១១ សន្លឹក, ខ្សែទី២ មាន ៨ សន្លឹក, ខ្សែទី៣ មាន ៨ សន្លឹក, ខ្សែទី៤ មាន ១១ សន្លឹក, ខ្សែទី៥ មាន ៩ សន្លឹក ។ ឯកសារចាស់គ្រាំគ្រាណាស់ ចុងសន្លឹកពុកផុយរលួយច្រើនសន្លឹក គួរឲ្យចារចម្លងជាថ្មី ដើម្បីរក្សាទុកឲ្យបានវែងឆ្ងាយ ។ ពុទ្ធសាសនបណ្ឌិត្យបានមកពីវត្តកែវឧត្តម ខេត្តពោធិ៍សាត់ ចុះលេខ ៩៨៨ ។

អត្ថបទផ្ដើម នមោ តស្ស ។ សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា បុព្វេ សន្ធបត្តជាតកំ កថេសិ មហាកិលនប្បត្តោ អហោសិ ។

---

១ ក្នុងបញ្ជីឯកសារនេះ មានរឿងសង្ខបត្តពីរ គឺ ១ និពន្ធជាពាក្យកាព្យ ។ ឯទី ២ នេះ និពន្ធជាពាក្យកាយ លំនាំទេសនា ។ ឯកសារទាំងពីរនេះ មានន័យដូចគ្នា គឺអ្នកនិពន្ធចង់បញ្ជាក់ អំពីឥទ្ធិពលនៃលទ្ធិកម្មផល តែងផ្ដល់ផលល្អ—អាក្រក់ ដល់អ្នកប្រព្រឹត្តជានិច្ច បីដូចស្រមោល អន្ទោលតាមប្រាណ ។

សត្ថា ព្រះសាស្តាចារ្យ អាហរិត្វា ទ្រង់នាំមកហើយ ឥមំ ធម្មទេសនំ នូវព្រះធម៌ទេសនានេះ កថេសិ សំដែងហើយ សន្ធិបត្តជាតកំ នូវសន្ធិបត្តជាតកនេះឲ្យពិស្តារ ពិស្តាបន្តិចទៅ ។

. . . . . ។ល។ . . . .

**អត្ថបទបញ្ចប់** ឯសីហានោះ លុះព្រះបានត្រាស់កាលណាក្រឡាប់ជាតិមកបានជាព្រះសារីបុត្តប្រាកដហោង ។ ឯកុញ្ជរនោះ លុះក្រឡាប់ជាតិមក បានជាមហាមោគ្គល្លានប្រាកដហោង ។ ឯព្រាហ្មណ៍ឈ្មោះ ចៅជុជ្ជះ ខ្លាក់នោះ ក្រឡាប់ជាតិមក បានជាទេវទត្តប្រាកដហោង ។ ព្រះសន្ធិបត្តកុមារនោះមិញ មិនគឺអ្នកដទៃឯណាឡើយ គប់ឯង គឺអញតថាគតឯង បានត្រាស់ប្រាជ្ញាសារពេជ្ញតាញាណ ជាព្រះពុទ្ធប្រាកដហោង ។

សន្ធិបត្តជាតកំ និដ្ឋិតំ ។ នេះនិងសំដែង ព្រះសន្ធិបត្តជាតកនេះមិញ ជាសូរេចនូវប្រការអម្បាលណោះហោង ។

—X—

**បំណងជើង** "សាស្ត្រា និព្វានបរិយាយ(១)"

១ អត្ថបទនៃឯកសារនេះ ករីមិនបានពន្យល់ អធិប្បាយព្រះនិព្វានដោយចំពោះទេ គឺគ្រាន់តែនិយាយទូន្មានឲ្យខិតទំធ្វើបុណ្យទាន និងរក្សាសីលដែលជាមធ្យោបាយផ្លូវដំណើរអ្នកប្រតិបត្តិទៅរកព្រះនិព្វាន ដែលជាឋានបរមសុខប៉ុណ្ណោះ - នៅផ្នែកខាងចុងអត្ថបទ ករីបានសំដែងអំពីទុក្ខទោសផ្សេងៗ ក្នុងឋាននរក ដែលជាផលវិបាក នៃសេចក្តីលោភ កំណាញ់ស្អិតស្អាញ ចិត្តបាបអកុសល ផ្តល់ឲ្យខ្វះនវងទុក្ខវេទនាផ្សេង ៗ ន ឋានបរលោក ។

អ្នកនិពន្ធ  រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ  គ្មានអត្ថបទបញ្ជាក់ ។

របៀបនិពន្ធ  ពាក្យកាព្យ បទព្រហ្មគីត ។

ប្រភពរឿង  ឥទ្ធិពល ពុទ្ធនិយម ។

លក្ខណៈឯកសារ  សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១១ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តបុងកោះប្រាក ខេត្តកំពង់ចាម ចុះលេខ ៦៦៩ ។

អត្ថបទផ្ដើម  បទព្រហ្មគីតនាំទី- ទានអំពីនៃមហាជន ឲ្យដឹងទោសស្រាលធ្ងន់ ក្នុងបរលោកនិងលោកិយ ។ ហៃមហាជនទាំង-ឡាយ ស្ដាប់បរិយាយគ្រប់ប្រុសស្រី តម្រង់ប្រុងស្មារតី ចាំកុំភ្លេចឡើយហោង ។ ត្បិតយើងនិងសំដែង ចរចាចែងតាមទំនង ដំណើរពីដើមនង ប្រាប់ទំនងពីអតីតា ។ . . .

. . . . . ល។ . . . .

អត្ថបទបញ្ចប់ ព្រះយមផ្ដាំស្មៀនៈស្មារ ស្ម្រាបញ្ជីនូវស្មៀនត្រា

គយល្បាតសព្វទី  ប្រុងប្រយ័ត្នកុំភ្លោយ ។

បពិត្រជនទាំងឡាយ  ស្ដាប់បរិយាយហើយចាំឲ្យ

រៀនបានធម៌ទុកដោយ  ខ្ញុំទីទៃទើបប្រសើរ ។

ជនអើយស្ដាប់បរិយាយ    យើងថែងតាយតាមដំណើរ
និព្វានមានប្រសើរ    ជាតំណាក់ព្រះយោគា
មិនមានតែប៉ុណ្ណោះ    និងឈប់ស្មុះពុំនាំពារ
ទៅទៀតច្រើនណាស់ណា    ស្រេចអ្នកនិព្វានហោង ។

—X—

**បំណងជើង** "សាស្ត្រា បណ្ឌិតស្មើរភ្លើង(១)"

**អ្នកនិពន្ធ** រកពុំទាន់ឃើញ ។

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

**របៀបនិពន្ធ** ពាក្យកាព្យ បទកាកគតិ ។

**ប្រភពរឿង** សេចក្តីរំលឹកដាស់តឿន ឲ្យខិតខំសិក្សារៀនសូត្រតាមប្រពៃណី ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៩ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តចុងកោះប្រាក់ ខេត្តកំពង់ចាម ចុះលេខ ៦៦០ ។

---

១ សាស្ត្រាបណ្ឌិតស្មើរភ្លើង ជាច្បាប់ទូន្មានប្រៀនប្រដៅតាមប្រពៃណីពីបុរាណ ។ ពាក្យនេះ ក៏ប្រហែលចង់បញ្ជាក់ន័យ នៃពាក្យចំនៀម ១ ដែលគេតែងពោលថា "បើចង់បានផ្លែផ្កា ឲ្យយកភ្លើងដុតគល់" គឺថា ម្ដាយឪពុកក្ដី គ្រូអាចារ្យក្ដី បើចង់ឲ្យកូន ឬ សិស្សចេះដឹងនូវវិជ្ជាអ្វីៗ មានអក្សរជាដើម ត្រូវស្ដីជេរ វាយដំ អប់រំ ទើបកូន ឬ សិស្សខំរៀនសូត្រ ព្រោះតែចេញផ្លែផ្កា គឺចំណេះវិជ្ជាសមដូចបំណង ។

អត្ថបទផ្ដើម នេះគឺដីកា គន់គិតតែងចារ តែងចងជារឿង ឲ្យឃើញ

គំនិត ក្នុងចិត្តនុះយើង បណ្ឌិតស្មើរក្មេង ក្មេងពាលកំឡោះ ។

ចិត្តចើកកយមាយ រវើរវាយ មិនមានសន្ត្រស្មោះ ត្រង់រៀន

ត្រង់សូត្រ ប្រួតដៃសោះ រកកលដើរតោះ ពោលកិច្ចរបៀន ។

. . . . . ។ល។ . . . .

អត្ថបទបញ្ចប់ ពីមនុស្សលោកិយ ចិត្តបាបអប្រិយ ពុំស្គាល់យល់ទុក្ខ

ព្រោះតែចេះតិច មិនយល់ទៅមុខ ទោះទៅនរក រងទុក្ខ

វេទនា ។ ទាំងចាស់ទាំងក្មេង ស្រើបស្រាលពុំដឹង វង្វេងដូច

គ្នា ច្រើនតែសរសើរ អំពើពាលា នោះឯងថាជា យល់ខុស

ជាត្រូវ ។ (ជាសូរបេហោង) ។

—X—

បំណងរឿង "សាស្ត្រា ក្អែកតាដប់(១)"

អ្នកនិពន្ធ គឺឈ្មោះ អេង-លី កំណើតនៅស្រុកព្រែកទ្រមាក់ ចេញ

ទៅនៅរកស៊ីឯភូមិពាមឯក ខេត្តបាត់ដំបង ទើបចាប់ផ្ដើមនិពន្ធ

រឿងនេះឡើង ។

---

១ សាស្ត្រាក្អែក ១០ នេះ មានអត្ថន័យពិរោះស្ដាប់ គួរឲ្យចាប់អារម្មណ៍ច្រើន គឺមានចោទ អំពីបញ្ហាក្នុងសង្គមគ្រួសារ រហូតដល់សង្គមជាតិ ។ មាណពដែលជាតួអង្គសំខាន់ ក្នុងរឿងព្រេងនេះ បានរិះរកមធ្យោបាយដោះស្រាយវិបត្តិដែលអាចកើតឡើងដល់ខ្លួនបាន ដោយសន្តិវិធី ថែមទាំងជួយផ្ដល់លទ្ធផលល្អដល់ខ្លួនផង ។

ដើមកាព្យនៃឯកសារនេះ មិនសូវមានតក់ឆ្គងច្រើនទេ ។

កាលបរិច្ឆេទ ព.ស. ៦៤១ ស្រា? (ប្រហែលប្រឡងដើន?) ។

របៀបនិពន្ធ ពាក្យកាព្យ បទព្រហ្មគីត ។

ប្រភពរឿង រឿងព្រេងខ្មែរ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១៥ សន្លឹក ។ ឯក-
នេះ ពុទ្ធសាសនបណ្ឌិត្យ មាន ២ ខ្សែ បានមកអំពីវត្តបុនកោះ
ប្រាក់ ខេត្តកំពង់ចាម ចុះលេខ ៦៦៩ ។

អត្ថបទផ្ដើម សូមថែងថ្លែងដោយបទ ព្រហ្មគីតគត់ដោយពេហារ
លើកល្បងប្រាជ្ញ រឿងក្អែកដប់សព្វសេចក្ដី ។ អញខ្ញុំនូន
សិរសា ថ្វាយនមស្ការព្រះជិនស្រី ព្រះពុទ្ធព្រះធម៌ខ្ពី ព្រះ
សង្ឃសូមសីលបរិសុទ្ធ ។ នូវគុណព្រះបិតា ប្រសើរថ្កើរក្រៃ-
បុត្ត មាតាថ្លៃវិសុទ្ធ អ្នកបំបៅអង្គអញខ្ញុំ ។ . . .

. . . . ។ល។ . . . . .

អត្ថបទបញ្ចប់ កុំផ្ចុកឃ្លាចុងល្បះ ឡប់ឡើងច្រះខូចខុសស្ដែង ចម្លង
តាមនេះឯង កុំចាំកែប្រែទៀតណា សេចក្ដីចប់ម៉្លេះហើយ ព្រះ
គុណអើយសូមមេត្តា អញខ្ញុំព្រះករុណា លើកប្រគេនមកព្រះ
គុណ ។ សូមតែមគ្គផលទុក តទៅមុខទុកជាទុន ជាផ្លូវទៅមុខ
មុន រៀនដកបដល់និព្វាន ។ រឿងពាក្យក្អែកដប់នៃ ចប់សេចក្ដី
ពិតពុំមាន តាមដោយរឿងនិទាន មានថែងចប់តែម៉្លេះណា ។

**បំណងជើង** "សាស្ត្រា គម្ពីរបឋមកាល្ប[១]"

**អ្នកនិពន្ធ** រកពុំទាន់ឃើញ ។

**របៀបនិពន្ធ** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**កាលបរិច្ឆេទ** ពាក្យពាយ លំនាំទេសនា (កម្រងកែវ) ។

**ប្រភពរឿង** ឥទ្ធិពល ពុទ្ធនិយម ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត មាន ៣ ខ្សែ ។ ខ្សែទី ១ មាន ៣៣ សន្លឹក, ខ្សែទី២ មាន ២៩ សន្លឹក, ខ្សែទី៣ មាន ២៧ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តព្រែកពោធិ ខេត្តកំពង់ចាម ចុះលេខ ៩៩១ ។

**អត្ថបទផ្ដើម** នមោ តស្ស ភោ សាធុពៅ ហៃសាធុសប្បុរសផងទាំងឡាយអើយ រីឯនឹងសំដែងអំពីព្រះបារមីសម្ដេចបរមសាស្ដាសម្មាសម្ពុទ្ធអម្ចាស់វិសេសនៃយើងនេះ ព្រះអង្គបានសាងសន្សំបន្ទុំព្រះពោធិសម្ភារបារមីទាំងរៀងមកជា ២០ អសង្ខេយ្យ អធិកនឹងទៅនូវមហាសែនកប្ប រៀងកល់មកដល់ភទ្ទកប្បយើងនេះ

---

១ ឯកសារនេះចែងអំពីប្រវត្តិនៃព្រះពុទ្ធទាំងឡាយក្នុងកប្បផ្សេងៗ នាអតីតកាល ។ ផ្នែកខាងចុងមានចែងអំពីព្រះនាមព្រះពុទ្ធ ១០ ព្រះអង្គដែលនឹងចុះមកត្រាស់ក្នុងអនាគតកាល ។ ក្រៅអំពីនេះ អ្នកនិពន្ធបានថ្លែងអំពីការសាងបារមី នៃព្រះពុទ្ធគោតមបរមគ្រូនៃយើងតាំងពីពេលចាប់ផ្ដើមតាំងចិត្តអធិដ្ឋានបារមីកសាងពុទ្ធភូមិ ។

ទើបព្រះអង្គបានត្រាស់ ច្បាស់ព្រះប្រាជ្ញាសារពេជ្ញតាញាណជា

ព្រះពុទ្ធ . . . . ។ល។ . . .

**អត្ថបទបញ្ចប់** នរអ្នកឯណា នឹងចង់ប្រាថ្នាជាព្រះពុទ្ធ គំប្បីឲ្យស្តាប់

គម្ពីរព្រះសោទត្តីមហានិទាននិបាត ឲ្យមានចិត្តពិព្យាយាម ធ្វើ

តាមគន្ធព្រះសទ្ធម្មនេះ ។ អ្នកនោះនឹងបានត្រាស់ជាព្រះពុទ្ធ

ចំហុត នាំសត្វផងទាំងឡាយនោះទៀនប្រាកដហោង ។

ទេសនាបរិយោសានេ នាកាលបើសុះចព្រះធម៌វិសេសទេ-

សនាព្រះដ៏មានបុណ្យនូវប្រការអម្បាលនោះហើយ ។ រីអស់

ទេវតា មនុស្ស សត្វផងទាំងឡាយ ១ អសង្ខេយ្យ សឹងបាន

លុះធម្មាភិសម័យ ក្នុងកាលណោះ ។ ឥតិ សោទត្តី មហា-

និទានំ . . . និដ្ឋិតំ ។ រីនឹងស្រដីពណ៌នាសរសើរដំណើរ

និយាយ គម្ពីរសោទត្តី មហានិទាននេះមិញស្រេចនូវប្រការ

អម្បាលណោះហោង ។

បំណងជើង «សាស្ត្រា មហាជម្ពូបតី(១)»

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យរាយ លំនាំទេសនា ។

ប្រភេទរឿង ឥទ្ធិពល ពុទ្ធនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ៥ ខ្សែ ។ ខ្សែទី១ មាន ២៧ សន្លឹក, ខ្សែទី២ មាន ២៣ សន្លឹក, ខ្សែទី៣ មាន ២២ សន្លឹក, ខ្សែទី៤ មាន ២០ សន្លឹក, ខ្សែទី៥ មាន ៣១ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តល្វា ខេត្តសៀមរាប លេខ ៨៥៧ ។

អត្ថបទផ្តើម នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ឯវម្មេ សុតំ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ ។

---

១ អត្ថបទខាងដើម ពណ៌នាសេចក្តីហូរហែក្នុងសម័យពុទ្ធកាលបើងនេះ ដល់ទៅខាងចុងបញ្ចប់មានបញ្ជាក់ពីការសជាតិ ដូចជាតកទៅវិញ ។ អត្ថបទមានលក្ខណៈដូច្នេះ ប្រហែលគេទើបនិពន្ធឡើងជាន់ក្រោយ ជាពិសេសក្នុងដែនដីសុវណ្ណភូមិនេះឯង ហើយឋិតនៅក្នុងរយៈសម័យបញ្ញាសជាតកដែរ ។

អត្ថបទមហាជម្ពូធិបតីនេះ មានន័យជាអច្ឆរិយៈស្ទើរតែទាំងអស់ ដូចការសំដែងឫទ្ធិជាអច្ឆរិយៈផ្សេងៗ ដើម្បីផ្ចាញ់ផ្ចាលសភាវៈអាក្រក់ ដូចរឿងរាមកេរ្តិ៍ដែរ ប៉ុន្តែគ្មានធ្វើឲ្យអន្តរាយដល់អាយុជីវិត ដល់អ្នកណាមួយឡើយ ដែលជាលក្ខណៈនិងវិធានការពុទ្ធនិយម ។

ក ធម្មាធិបតី នាមពជា ។ល។ ឯកំ សមយំ ។ មានកាល

សម័យថ្ងៃមួយ ។ គគវា រីអង្គសម្តេចព្រះសារពេជ្ញាញាណ ។

វិហរតិ ព្រះអង្គគង់នៅ ។ វេឡុវនេ ឮដ៏អាកមនាមហៅ

វេឡុវ័ន ។ . . . ។ល។ .

អត្ថបទបញ្ចប់ ទេសនាបរិយោសានេ ពហូ ជនា បាបុណិសុ ។

រីសម្តេចព្រះសាស្តាចារ្យជាព្រះបរមគ្រូ ស្តេចសំដែងព្រះធម៌

វិសេសទេសនាជាស្រេចហើយ ព្រះអង្គទេសនាផ្តុំជាតកថា

កិត្តុវ ម្នាលភិក្ខុទាំងឡាយអើយ ភិក្ខុអើយ វិបុរសពាណិជ្ជ

ម្នាក់គិតដ៏បេរវិលវិឧមកក្នុងសាសនាអញតថាគតឥឡូវនេះ ធម្ម

ធិបតី បានជាមហាធម្មធិបតិគ្រេតឥឡូវនេះហោង ។ រីឯកិរិយា

នោះសោត គិតដ៏បេរវិលវិឧមក បានជានាងកញ្ញានទេវីថេរីភិក្ខុនី

ឥឡូវនេះហោង ។ រីយើងទីងស្រដីពណ៌នាចោទចាត់ថែង

សំដែងសរសើរដំណើរមហាធម្មកជជ្ឈិបតីកជនេះមិញ ។ និដ្ឋិត

ចប់បរិបូណ៌ ឥតិបការេន ជាស្រេចនូវប្រការអម្បាលណោះឯង

ហោង ។

បំណងជើង «សាស្ត្រា ធម្មធាតុ[១]»

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យពយ ល់នាំទេសនា ។

ប្រភេទរឿង ចលនាព្រាហ្មណនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣០ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តត្បែង ខេត្តសៀមរាប ចុះលេខ ១០១៩ ។

អត្ថបទផ្ដើម ធម្មធាតុ ។ សេចក្ដីធម្មធាតុទាំង ៧ ប្រការ ដែលជានាមធម៌ អាស្រ័យនិងរូបនៃសត្វនិងមនុស្សទាំងឡាយ ឲ្យគិតឲ្យនឹកអារម្មណ៍ផ្សេងៗ ហើយនឹងដឹង គឺ កវេ្ត ប្រែថាកើត មួយៗនមួយមនោ ប្រែថាបង្អោនទៅកាន់អារម្មណ៍ផ្សេង ៗ មានរូបជាដើម ១ ចិត្តំ ប្រែថា នឹកគិតអារម្មណ៍ ១ វិញ្ញាណំ ប្រែថា ដឹងច្បាស់នូវអារម្មណ៍១ សង្ខារ ប្រែថា ដឹងច្បាស់នូវអារម្មណ៍១

១ អត្ថបទធម្មធាតុ ប្រហែលអ្នកនិពន្ធបានដកស្រង់ចេញមកអំពីគម្ពីរព្រះអភិធម្មត្រង់និយាយអំពីខន្ធ ៥ ញែកបំបែកដោយល្អិតល្អ ដើម្បីឲ្យចេះពិចារណាតាមលក្ខណៈទាំង ៣ គឺ អនិច្ចំ ទុក្ខំ អនត្តា ។

សង្ខារ ប្រែថា បំរុងតែងនឹងសេចក្តីឈ្លាសមិនឈ្លាស ១ ។

. . . . ។ល។ . . , .

អត្ថបទបញ្ចប់ គឺនាមរូបនេះឯង នាមវាបង្កើតឡើងហើយ ជីវិតរក្សាវាទុក បានជារស់នៅ តែជីវិតដាច់ហើយ នាមក៏រលត់ រូបក៏រលួយទ្រុឌទ្រោមសូន្យទៅ វាជារបស់មិនទៀងជាទុក្ខ មិនមែនរបស់យើង មិនមែនខ្លួនយើង តាមតែវា បណ្ដាយវាចុះ កុំប្រកាន់វាទុក ព្រោះព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ប្រដៅទុកថា ការឯណាដែលមិនមែនជារបស់ខ្លួន ការនោះ ចូរលះបង់ចុះ កុំប្រកាន់វាទុក ។ បើលះបង់បានហើយ ដឹងប្រយោជន៍នៃខ្លួនអស់កាលដូច្នេះ នេះជាព្រះពុទ្ធភាសិតប្រាកដ ។ ហេតុនេះ យើងទាំងឡាយបានកើតជាមនុស្សបានភពប្រសប់ នឹងព្រះពុទ្ធសាសនា ជាលាភធំរបស់យើងហើយ ចូរកុំប្រមាទឡើយ ខំស្វាហាប់ចំរើនសមថៈ នឹងវិបស្សនា ឲ្យស្អាតដោយល្អចុះ នឹងបានជាទីពឹងរបស់យើង ។ មួយទៀត នឹងបានជានិស្ស័យមគ្គ-ផលទៅអនាគតឯមុខ មិនបង់កំណើតដែលបានកើតទាន់ភពប្រសប់ព្រះពុទ្ធសាសនានេះហោង ។

(នៅមានត)

# លទ្ធផលនៃការប្រឡងប្រជែងទំនៀម
# ទម្លាប់ខ្មែរ នៅឆមាសទី ២ ឆ្នាំ ១៩៦៥
## ស្ដីអំពីសត្វផ្សេងៗ

នៅក្នុងឆមាសទី ២ ឆ្នាំ ១៩៦៥ គឺពីខែកក្កដា ដល់តំណាច់ខែធ្នូ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបើកការប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ ១ មុខគឺ "អំពីសត្វផ្សេងៗ" ដើម្បីប្រមូលឯកសារផ្នែកនេះ យកមករក្សាទុកជាគោលចារឹកនៃប្រពៃណីរបស់ប្រទេសតទៅអនាគត ។

ក្នុងរយៈកាល ៦ ខែ ក្រោយដែលបានប្រកាសផ្សាយរួចហើយ ក្រុមជំនុំទំនៀមទម្លាប់ បានទទួលអត្ថបទស្ដីអំពីសត្វផ្សេងៗ នោះជាបន្តបន្ទាប់គ្នា អំពីសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំខ្លះ អំពីបេក្ខជនក្រៅពីសមាជិកខ្លះ ទាំងបព្វជិតទាំងគ្រហស្ថជាច្រើនច្បាប់ ។

ក្រោយដែលក្រុមជំនុំបានប្រជុំគ្នាពិនិត្យវិញ្ញាសាទាំងនេះយ៉ាងហ្មត់ចត់ទៅ ឃើញថាអត្ថបទទាំងនេះនៅខ្វះន័យមានតម្លៃជាច្រើន ម្ល៉ោះហើយក្រុមជំនុំក៏សម្រេចជូនត្រឹមតែរង្វាន់លេខ ៣ ប៉ុណ្ណោះ ចំពោះឯកសារដែលគ្រាន់បើជាងគេ ហើយទិងមានរង្វាន់លើកទឹកចិត្តបន្ទាប់បន្សំជាច្រើនទៀតផង ។ ឯអ្នកដែលបានជាប់លេខក្នុងការចាត់ថ្នាក់ មានដូចតទៅ ៖

-លោក ចាប-រិត គ្រូបង្រៀននៅសាលាបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០៖០០ ៛

-លោក ណុប-កាង នៅឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៖០០ ៛

-លោក សាន ឌុយ ហៅ កែវ សានឌី នៅសៀមរាប អង្គរ (ក្រុង) បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៖០០ ៛

-លោក ឌួង-អ៊ួច អតីតមេឃុំ ។ អង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៖០០ ៛

-ភិក្ខុ លាវ-គាន ហៅ ប្រធុល គង់នៅវត្តបាណន់ក្រោម ឃុំឈើទាល ស្រុកសង្កែ ខេត្តបាត់ដំបង បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៖០០ ៛

-ភិក្ខុ ឡុង-ស៊ុស៊ុយ៉ាត់ អនុលេខាធិការគណ ស្រុកកំចាយមារ គង់នៅវត្តស្មោង ឃុំស្មោង ស្រុកកំចាយមារ ខេត្តព្រៃវែង បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៖០០ ៛

ក្នុងឱកាសជាមួយគ្នានេះ ក្រៅពីការប្រឡង ក្រុមជំនុំបានទទួលឯក-សារស្ដីអំពីទំនៀមផ្សេង ៗ ជាច្រើនទៀត អំពីសមាជិកឆ្លើយឆ្លងខ្លះ អំពីអស់លោកដែលមិនមែនសមាជិកខ្លះ ដែលមានឧត្តមគតិល្អ យល់ច្បាស់

នូវប្រយោជន៍ជាតិពិតប្រាកដ បានសរសេរឲ្យការណ៍ទៅក្រុមជំនុំយើង ។

ចំណែករង្វាន់ដែលត្រូវបានដល់បេក្ខជនប្រឡងជាប់ ដល់សមាជិក និង ក្រៅសមាជិកដែលផ្ញើអត្ថបទទៅក្រុមជំនុំនោះ ក្រុមជំនុំបានចាត់ប្រគេន-ជូនហើយខ្លះ និងចាត់ប្រគេន ជូនក្នុងពេលឆាប់ ៗ ខាងមុខខ្លះទៀត ។

ក្រុមជំនុំទំនៀមទម្លាប់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះតេជព្រះគុណ និង អស់លោក-អ្នកដែលបានយកព្រះទ័យទុកដាក់ យកចិត្តឈឺឆ្អាលជួយរក្សាកេរ្តិ៍តំណែលរបស់ជាតិ ដ៏ថ្លៃថ្លាទាំងអស់នេះជាកិយ្យោភាព ។

# ពិធីប្រគល់មុខងារបាងហ្វាងសាសនាអ៊ីស្លាម

នៅថ្ងៃសៅរ៍ទី ២០ វិច្ឆិកា ១៩៦៥ ពេលម៉ោង ១៩-៣០ នៅវិហារមុខដាច់នៃសាសនាអ៊ីស្លាម ជ្រោយចង្វា សង្កាត់លេខ ៧ ក្រុងភ្នំពេញ មានធ្វើពិធីប្រគល់មុខងារ បាងហ្វាងសាសនាអ៊ីស្លាម ចំពោះហាកិម រេះ ឡេះ ដែលបានជាប់ឆ្នោតកាលពីថ្ងៃទី ១៧ តុលា ១៩៦៥ ។ ពិធីនេះបានប្រព្រឹត្តទៅ ក្រោមអធិបតីភាពនៃសហជីវិន ទ្រិញ-វ៉ាញ អនុរដ្ឋលេខាធិការក្រសួងធម្មការ ជាតំណាងឯកឧត្តមរដ្ឋមន្ត្រី ។ ក្នុងឱកាសនោះ សហជីវិន អនុរដ្ឋលេខាធិការ បានថ្លែងសុន្ទរកថា ដូចតទៅ :

## សុន្ទរកថា

ដែលសហជីវិន ទ្រិញ-វ៉ាញ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងក្នុងឱកាសពិធីប្រគល់មុខងារ បាងហ្វាងសាសនាអ៊ីស្លាមដល់ ហាកិម រេះ-ឡេះ ថ្ងៃទី ២០ វិច្ឆិកា ១៩៦៥ ។

- សូមគោរពហាកិមទាំងឡាយ
- សូមជំរាប សាសនិកជនអ៊ីស្លាម និងសហជីវិន-សហជីវិនី ទាំងអស់

ក្នុងឱកាសនៃពិធីដ៏រុងរឿងនេះ ខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ដោយបានទទួលកិត្តិយស មកប្រគល់ជូនក្នុងព្រះបរមនាមនៃព្រះ

រាជបល្ល័ង្ក ក្នុងនាមនៃរាជរដ្ឋាភិបាល និងជាតំណាងឯកឧត្តម រដ្ឋមន្ត្រីក្រសួងធម្មការ នូវមុខងារនៃចាងហ្វាងសាសនាអ៊ីស្លាម ចំពោះហាកិមរេះ-ឡោះ ដែលបានជាប់ឆ្នោតកាលពីថ្ងៃទី ១៧ តុលា ២៩៦៥ គឺជាការបោះឆ្នោតដំបូងបំផុត ក្នុងប្រវត្តិនៃសាសនាអ៊ីស្លាម នៅប្រទេសកម្ពុជា ។

សូមជ្រាបថា ការបោះឆ្នោតជ្រើសតាំងចាងហ្វាងសាសនាអ៊ីស្លាមនេះ គឺជាការប្រោសព្រះរាជទាន នៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ ក្នុងវត្តបំណងលើកតម្កើងសាសនាអ៊ីស្លាម ឲ្យស្របទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ដែលសង្គមរាស្ត្រនិយមបានដឹកនាំមក ។ នៅប្រទេសកម្ពុជា, អ្នកកាន់អំណាចត្រួតត្រាព្រះសង្ឃផ្ទាល់ជាអាទិ៍គឺ មេគណ និង អនុគណ សុទ្ធតែត្រូវជ្រើសតាំងដោយការបោះឆ្នោត ។ សិទ្ធិដ៏ខ្ពង់ខ្ពស់ ដែលព្រះរាជបល្ល័ង្កបានទ្រង់ប្រោសព្រះរាជទានជាកិត្តិយសចំពោះពុទ្ធសាសនា ដែលជាសាសនាសម្រាប់រដ្ឋនេះ ព្រះអង្គបានទ្រង់ប្រោសព្រះរាជទានចំពោះសាសនាអ៊ីស្លាមមុនគេបំផុត ក្នុងចំណោមពាហិរសាសនាទាំងឡាយ នៃប្រទេសកម្ពុជា ។ ដូច្នេះ គឺសាសនាអ៊ីស្លាមនេះហើយ ដែលជារៀមច្បងបានទទួលកិត្តិយស និងអត្ថប្រយោជន៍លើសគេ ជាងពាហិរសាសនាទាំងអស់ ជាអាទិ៍គឺការធ្វើប្រជាធិបតេយ្យបនិយកម្ម ដល់អ្នកការពារផលប្រ-

យោជន៍ និងត្រួតត្រាសាសនាផ្ទាល់ គឺហាកិម និងចាងហ្វាងសាសនាអ៊ីស្លាមជាដើម , ដែលសុទ្ធតែសម្រេចដោយការបោះឆ្នោតជ្រើសតាំងៗ

ដូចបងប្អូនខ្មែរអ៊ីស្លាមទាំងឡាយ បានជ្រាបស្រាប់ហើយ សាសនាអ៊ីស្លាមដែលចូលមកប្រតិស្ឋាននៅប្រទេសកម្ពុជា បានទទួលការឧបត្ថម្ភយ៉ាងខ្ពង់ខ្ពស់បំផុតពីព្រះរាជបល្ល័ង្ក និងពីព្រះរាជរដ្ឋាភិបាល នៅក្នុងសម័យរាជធានីភ្នំពេញ ក៏ដូចជានៅក្នុងសម័យលង្វែក និងសម័យឧដុង្គដែរ ៗ ការិយកម្មនៃសាសនាអ៊ីស្លាមនេះ បានទទួលសិទ្ធិនិងសេរីភាពជាពិសេស ដូចជាសាសនារបស់រដ្ឋ ជាអាទិ៍មានការកាប់ឈើរួចពន្ធសម្រាប់ស្ថាបនាព្រះវិហារ និងសិទ្ធិក្នុងការផ្សាយសាសនាជាដើម ៗ

ក្នុងសម័យឧដុង្គ ព្រះបាទហរិរកមាព្រះអង្គឌួង ដែលរដ្ឋធម្មនុញ្ញព្រះរាជអាណាចក្របានតម្កល់ទុកថា ជាព្រះមហាក្សត្រទី ១ នៃប្រទេសកម្ពុជាបច្ចុប្បន្ននោះ ព្រះអង្គពុំមែនគ្រាន់តែរៀបចំឡើងវិញជាថ្មី នូវការសិក្សា និងការប្រតិបត្តិព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ព្រះអង្គទ្រង់ឲ្យស្វះស្វែងរកអ្នកប្រាជ្ញខាងសាសនាអ៊ីស្លាម ឲ្យរួបរួមគ្នាតែងធម៌វិន័យរបស់អ៊ីស្លាម ហើយទ្រង់ឲ្យហាត់សូត្រធម៌បទ និងទ្រង់ឲ្យបង្ហាត់បង្រៀនធម៌វិន័យរបស់អ៊ីស្លាម នៅគ្រប់ព្រះវិហាររបស់អ៊ីស្លាម ៗ ក្នុងពេលនោះព្រះបាទអង្គឌួង បានទ្រង់បញ្ញត្តិឲ្យសូត្រធម៌បទរបស់ចាម មានឈ្មោះហៅថា បទមហាសម័យ និងបទគិរីមានន្ទ ដូចជាបទរបស់ខ្មែរដែរ

ហើយឲ្យចារិកធម៌វិន័យរបស់សាសនាអ៊ីស្លាម ជាអក្សរខ្មែរ ដោយនៅក្នុងសម័យបុរាណ ប្រទេសចម្ប៉ាបានប្រើអក្សរខមដូចគ្នានឹងអក្សរនៃប្រទេសកម្ពុជាដែរ ។ ព្រះតេជ្ជៈនៃព្រះបាទអង្គឌួងនេះ បានត្រូវគេរក្សាខ្ជាប់ខ្ជួនទៅវិហារអ៊ីស្លាមទាំងឡាយនាក្រុងឧដុង្គ ហើយពួកអ៊ីស្លាមដែលកាន់តាមប្រពៃណី ដែលព្រះបាទអង្គឌួងទ្រង់រៀបចំមកនេះ បានត្រូវអ្នកសិក្សាខ្មែរតាមក្បួនពីម៉ាឡេស៊ីយ៉ា ឬពីឥណ្ឌូណេស៊ី - អេហ្ស៊ីប - អារ៉ាប់ ចាត់ទុកថាជាពួកបុរាណ ។

គួរកត់សំគាល់ថា ការផ្តួចផ្តើមព្រះតំរិះនៃព្រះបាទអង្គឌួង ដែលទ្រង់សព្វព្រះរាជហឫទ័យឲ្យខ្មែរអ៊ីស្លាម សិក្សាធម៌វិន័យរបស់អ៊ីស្លាមជាភាសាខ្មែរ ឬចាម ដែលសរសេរជាអក្សរខ្មែរនេះ គឺជាព្រះតំរិះត្រូវបំផុត ព្រោះគេពុំចាំបាច់រៀនអក្សរភាសាឥណ្ឌូណេស៊ី ឬម៉ាឡេស៊ីយ៉ា, ក៏អាចសិក្សា អាចមើលធម៌អាថ៌នៃសាសនាអ៊ីស្លាម ជាអក្សរខ្មែរបានដែរ ។ ក្នុងពេលនេះ ខ្មែរអ៊ីស្លាមទាំងឡាយបានផាកទៅចូលរៀននៅសាលាបឋមសិក្សារាជការដោយច្រើន ហើយពុំងាយនឹងមានពេលទៅរៀនអក្សរអារ៉ាប់ ដើម្បីមើលធម៌វិន័យនោះទេ ។ ដូច្នេះ ព្រះតំរិះនៃព្រះបាទអង្គឌួង ដែលទ្រង់សព្វព្រះរាជហឫទ័យ ឲ្យរួបរួមអ្នកប្រាជ្ញសាសនាអ៊ីស្លាម ធ្វើក្បួនច្បាប់សាសនាអ៊ីស្លាមជាភាសាខ្មែរនោះ គឺជាការត្រូវមែន ហើយត្រូវប្រាកដដែលពុំអាចនឹងបដិសេធបាន ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ។

តាមគោលការណ៍, ដែលប្រទេសនីមួយៗ ត្រូវប្រកបដោយអង្គ ៥ យ៉ាងគឺ :

១- មានផែនដី - ដែលមានព្រំប្រទល់ត្រឹមត្រូវ

២- មានពលរដ្ឋរបរមគ្នា

៣- មានអធិបតេយ្យ

៤- មានអង្គការគ្រប់គ្រងទាំងអំណាចនីតិបញ្ញត្តិ-នីតិប្រតិបត្តិ និងតុលាការ

៥- មានវប្បធម៌ ។

ខ្ញុំពុំអធិប្បាយអំពីគោលការណ៍ទាំង ៥ នេះទេ ប៉ុន្តែខ្ញុំសូមដកយកអំពីពាក្យថា « វប្បធម៌ » ដែលបុកណាហៅថា ធម្មការ ជូនជាទីសណ្តាប់បន្តិច ។

ពាក្យថា វប្បធម៌ គឺ«culture» នេះចែកជា ៥ យ៉ាង គឺ :

១- ភាសា គឺ សំដីនិយាយ និង អក្សរ

២- ប្រពៃណី

៣- សាសនា

៤- ច្បាប់

៥- រចនា

តាមរបៀបនៃប្រទេសទាំងអស់ ពាក្យថា វប្បធម៌គឺ« culture »

ដែលគេយកមកប្រើធ្វើជាក្រសួងរដ្ឋមន្ត្រីនោះ ត្រូវមាននាទីត្រួតត្រា ការពារនិងធ្វើឲ្យចំរើនលូតលាស់នូវវប្បធម៌ទាំង ៤ យ៉ាង របស់ជាតិនេះ ដែលប្រទេសចំរើនខ្លះគេបានបែងចែកក្រសួងវប្បធម៌នេះ ទៅជា៤ ក្រុម ។

ប្រទេសកម្ពុជា មានវប្បធម៌ទាំង ៤ យ៉ាងនេះយ៉ាងបរិបូណ៌ តាំងពីសម័យអង្គរ ដូចមានក្បួនច្បាប់ សិលាចារឹក និងរូបចម្លាក់នៅប្រាសាទបាយ័ន និងនៅអង្គរវត្តជាសំអាងស្រាប់ ។ ក្នុងសម័យឧដុង្គ គឺព្រះបាទអង្គឌួងនេះហើយ ដែលបានទ្រង់រៀបចំ និងបានទ្រង់ស្ថាបនាឡើងវិញជាថ្មី នូវវប្បធម៌របស់ជាតិទាំង ៤ យ៉ាង ហើយព្រះកេរ្តិ៍នេះមានតម្លៃកប់ពុំបានក្នុងវប្បធម៌ជាតិ ដែលគេបានរក្សាទុកដោយផ្ចិតផ្ចង់ដរាបដល់សព្វថ្ងៃ ហើយព្រះមហាក្សត្រគ្រប់ព្រះអង្គ ក៏បានទ្រង់បន្តការស្ថាបនាជាតិជាថ្មី តាមគ្រោងការណ៍នៃការរៀបចំវប្បធម៌ជាតិទាំង ៤ យ៉ាង ដែលព្រះបាទអង្គឌួង បានត្រួសត្រាយមកនេះ ។

តាមរដ្ឋបញ្ញត្តិជាទូទៅ ដែលហៅថា ជនជាតិនៃប្រទេសទីមួយ ៗ នោះ ពុំមែនដោយគ្រាន់តែការចូលជាតិ ឬដោយការដាក់ឈ្មោះខ្លួនប៉ុណ្ណោះទេ ជាពិសេស គឺត្រូវអ្នកនោះនិយម វប្បធម៌ទាំង ៤ យ៉ាងនៃប្រទេសនោះផង ទើបហៅថា ជាជនជាតិនៃប្រទេសនោះកើត ។

គួរកត់សំគាល់ថា បន្ទាប់ពីប្រទេសចម្ប៉ាត្រូវបរាជ័យទៅ ព្រះមហាក្សត្រនៃប្រទេសចម្ប៉ា ព្រះរាជវង្សានុវង្ស និងព្រះរាជបរិពារជាច្រើន

បានមកសុំស្នាក់អាស្រ័យនៅក្នុងប្រទេសកម្ពុជា ក្នុងរាជ្យព្រះជ័យជេដ្ឋាទី ១ សម័យបន្ទាយលង្វែក ហើយអាណាកជនចាម ជាបងប្អូនទាំងនោះ បានត្រូវព្រះមហាក្សត្រខ្មែរទំនុកបំរុងឲ្យធ្វើជាជនជាតិខ្មែរ ដែលមានសិទ្ធិសេរីភាព ដូចជាជនជាតិខ្មែរទាំងឡាយដទៃដែរ ។

ព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ មានសម្តេចព្រះ នរោត្តម សីហនុ ក្នុងសម័យសង្គមរាស្ត្រនិយម ជាពិសេស បានទំនុកបំរុងអាណាកជនទៃប្រទេសចម្ប៉ាទាំងនោះ ពុំមែនគ្រាន់តែឲ្យទៅជាខ្មែរ និងប្រកបអាជីវកម្ម ដែលមានកាន់មុខតំណែងសាធារណៈធំ - ធំ ប៉ុណ្ណោះទេ គឺបានទាំងទំនុកបំរុងខាងកិច្ចប្រតិបត្តិសាសនាផង ។ គឺដោយសារការឧបត្ថម្ភនៃព្រះរាជបល្ល័ង្ក និងការជួយទំនុកបំរុងយ៉ាងអនុគ្រោះនៃរាជរដ្ឋាភិបាលនេះហើយ ដែលសាសនាអ៊ិស្លាមបានត្រូវផ្សាយពាសពេញព្រះរាជអាណាចក្រ ដោយមានវិហារអ៊ិស្លាមសម្រាប់ផ្សាយ និងសម្រាប់ប្រតិបត្តិសាសនាចំនួន ១១៥ ។

ចំពោះការទាក់ទងជាអន្តរជាតិវិញ រាជរដ្ឋាភិបាលបានចាត់ឲ្យគណៈប្រតិភូសាសនាអ៊ិស្លាមនៃប្រទេសកម្ពុជា ២ រូប ឲ្យទៅរួមប្រជុំក្នុងសន្និសីទអ៊ិស្លាម អាហ្វ្រិក-អាស៊ី នាក្រុងបានឌុងនៃប្រទេសឥណ្ឌូណេស៊ី ពីថ្ងៃទី ៦ ដល់ថ្ងៃទី ១៤ មីនា ១៩៦៥ ។

— បានចាត់ប្រតិភូខ្មែរអ៊ិស្លាម ៤ រូបឲ្យទៅប្រជុំប្រឡងគម្ពីរ កូរអាន

នៅក្រុងកូឡាំបូ " ម៉ាឡេស៊ីយ៉ា " ពីថ្ងៃទី ១៧ ដល់ទី ២៣ មករា ១៩៦៤ ហើយដល់ឆ្នាំ ១៩៦៦ នឹងមានបាត់ឲ្យខ្មែរអ៊ីស្លាម ទៅរួមប្រជុំក្នុងការប្រឡងគម្ពីរនេះទៀត ។

បានបញ្ជូននិស្សិតខ្មែរអ៊ីស្លាម ១០ នាក់ឲ្យទៅបន្តវិជ្ជាអ៊ីស្លាមនៅប្រទេសអារ៉ាប់រួម ក្នុងឆ្នាំ ១៩៦៣ , ហើយក្នុងឆ្នាំនេះ កំពុងបាត់ឲ្យនិស្សិត ៥ រូបទៀត ទៅបន្តវិជ្ជានៅក្រុងគែរ ។

ក្រៅពីនេះ រាជរដ្ឋាភិបាល បានជួយឧបត្ថម្ភអ្នកកាន់សាសនាអ៊ីស្លាម នៃប្រទេសកម្ពុជា ទៅនមស្ការនៅក្រុងឡាម៉ិក " ម៉ាក់កាស់ " នៃប្រទេសអារ៉ាប៊ី សេអ៊ូឌីត រៀងរាល់ឆ្នាំ ហើយនៅឆ្នាំ ១៩៦៦ ក៏មានអនុញ្ញាតឲ្យចំនួន ២០ នាក់ អញ្ជើញទៅជាថ្វីការទៀតដែរ ទោះបីប្រទេសត្រូវការត្បិតត្បៀតប៉ុណ្ណោះយ៉ាងណាក៏ដោយ ។

សូមជំរាបថា ក្រសួងធម្មការ បានបាត់ការគ្រប់កិច្ចការទាំងអស់សម្រាប់សាសនាអ៊ីស្លាម ឲ្យស្របទៅតាមបទបញ្ញត្តិទាំងឡាយនៃគម្ពីររបស់សាសនានេះ ជាអាទិ៍ គឺជួយឲ្យសាសនានេះ អាចបំពេញនូវមុខវត្តប្រតិបត្តិទាំង ៤ យ៉ាងរបស់ខ្លួនបានដោយសេរី គឺ :

១– ការជំរះលាងកាយ និងសូត្រមន្ត

២– ការរក្សាសីល ៣០ ថ្ងៃ ក្នុងខែរ៉ាម៉ាដន គឺខែទី ៩ របស់អ៊ីស្លាម ដែលត្រូវកាន់តំណម ដោយវៀរចាកបរិភោគអាហារ-ទឹក ជក់

ទឹក លាបគ្រឿងក្រអូប ឬការប្រព្រឹត្តទៅដើម្បីកត់ៈ ចាប់តាំងពីព្រះអាទិត្យរះ រហូតដល់អស្ដង្គត ។

-៣ ការបំពេញទាន

-៤ ការទៅនមស្ការនៅ ម៉ាក់កាស់ ។

ក្រៅពីនេះ មានជួយទំនុកបំរុងខាងការសិក្សា មានឲ្យជាវគម្ពីរពីបរទេសជាដើម ។

ខ្ញុំយល់ថា ក្នុងពេលបច្ចុប្បន្នដែលរាជរដ្ឋាភិបាល បានតម្រូវឲ្យកំចាត់ការមិនចេះអក្សរនេះ ការបង្កើតឲ្យមានក្បួនខ្នាត និងសាលាបង្រៀនសាសនាអ៊ីស្លាម ជាភាសាខ្មែរ គឺជាការចាំបាច់មួយដែលត្រូវបង្កើតឲ្យមាន ព្រោះក្បួនខ្នាតនិងសាលារៀន អាចធ្វើឲ្យអ្នកកាន់សាសនាអ៊ីស្លាម យល់ត្រូវគ្នា ដែលជាហេតុនាំឲ្យមានសាមគ្គីនៅក្នុងផ្ទៃនសាសនានេះកើត ។

ខ្ញុំសូមថ្លែងសេចក្ដីសរសើរយ៉ាងស្មោះ ហើយយ៉ាងកក់ក្ដៅជូនហាកិម ឞៈឡោះ បានជាប់ឆ្នោត ដោយមានសម្លេង ៧៩ ទល់នឹង ២៨ ដែលបញ្ជាក់ឲ្យឃើញថា លោកមានប្រិយភាព និងជាទីទុកចិត្តនៃហាកិមទាំងឡាយនៃប្រទេសកម្ពុជា ។

ក្រសួងធម្មការ បានទទួលស្គាល់សមត្ថភាព និងសេចក្ដីសុចរិតស្មោះត្រង់នៃហាកិមនេះ ដោយលោកធ្លាប់បានធ្វើជាអតីតក្រូឈ្នួយ

ចាប់ពីថ្ងៃទី ១ នៃសេចក្ដីទុកញាក់ជាធិបតី ហាដស់អ៊ីន ។

គឺដោយស្គាល់ច្បាស់នូវសេចក្ដីស្វាមីភក្ដិ ស្មោះត្រង់នៃឃាតិមនេះ ចំពោះព្រះកដបល្ល័ង្កនោះហើយ ទើបព្រះកដបល្ល័ង្ក មេត្តាប្រោសតែងតាំងលោក ជាចាងហ្វាងសាសនាអ៊ីស្លាមដោយមានសក្តិ ៩ ហូពាន់ និងគោរម្យងារជា ទុកញាក់ជាធិបតី ។

ក្នុងករណីនេះ ខ្ញុំសុំឲ្យអ្នកទុកញាំ រៀបចំឲ្យមានរបៀបរៀបរយ និងមានសាមគ្គីធម៌ជាថ្មីឡើងវិញ នៅក្នុងផ្ទៃនៃសាសនាអ៊ីស្លាម ដើម្បីឲ្យស្របតាមមាគ៌ានយោបាយនៃសម្ដេចព្រះប្រមុខរដ្ឋ ។

នៅដំបន់ណាដែលមានអធិករណ៍ពុំទាន់ជ្រះស្រឡះ សូមអ្នកទុកញាំមេត្តាអញ្ជើញទៅឲ្យដល់ដំបន់នោះ ដើម្បីសម្រុះសម្រួលឲ្យបានស្រុះស្រួលជាស្ថាពរផង ។

ម្យ៉ាងទៀត ខ្ញុំសុំផ្ដាំផ្ញើឲ្យអ្នកទុកញាំពប់រកសាសនិកជនអ៊ីស្លាមទូទៅទាំងពួកចាស់ពួកថ្មី កុំប្រកាន់បក្សពួកឲ្យសោះ ជាពិសេសសូមឲ្យពប់រកអស់លោកខាងបក្សជនធ្លាក់ឆ្នោតនោះ ឲ្យវិសេសលើសគេទាំងអស់ព្រមទាំងឲ្យពប់រកពួកអ៊ីស្លាម ដែលកាន់តាមប្រពៃណី ដែលបានរៀបចំឡើងសម័យទុង្គនោះផង ។

ចំណែកបក្សអ្នកដែលធ្លាក់ឆ្នោតសូមទទួលស្គាល់លទ្ធិប្រជាធិបតេយ្យ

គឺត្រូវគោរពតាមភាគច្រើន ហើយពុំត្រូវមានគំនិតបំបែកបំបាក់សាមគ្គីឡើយ ។

នៅទីបំផុតនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះសហជីវិន និងសហជីវិនីទាំងអស់ ដែលបានជូនកិត្តិយស ដោយព្រាំស្តាប់សុន្ទរកថាយ៉ាងវែងរបស់ខ្ញុំ ហើយខ្ញុំសូមប្រសិទ្ធិពរ ដោយអានុភាពនៃព្រះអាល់ឡោះ ដើម្បីសុភមង្គល និងសេចក្តីចំរើនក្នុងមុខងារថ្មី នៃអ្នក-កញ្ញាចាន់ហ្វាង និងសុំឲ្យសហជីវិន-សហជីវិនីទាំងអស់ បានជួបប្រទះនូវជោគជ័យ សិរីមង្គល និងសេចក្តីចំរុងចំរើនគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

# សេចក្ដីកត់ហេតុនៃការប្រជុំការងារទី ៧

## នៅពុទ្ធសាសនបណ្ឌិត្យ ថ្ងៃ១១-១០-៦៥

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ ថ្ងៃទីដប់ប្រាំមួយខែតុលា វេលាម៉ោងប្រាំបីព្រឹក នៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ មានបើកការប្រជុំមួយ ក្រោមអធិបតីភាពនៃសហជីវិន លាង ហ៍ប អាន ដោយមានសមាជិកចូលរួមជាច្រើនរូបគឺ :

១. សហជីវិន ញូង-សឿង អគ្គលេខាធិការរង

២. — ឱក-គាម នាយការិយាល័យបោះពុម្ពផ្សាយ

៣. — អៀង-ស្បោង នាយឃ្លាំងសៀវភៅ

៤. — ទុន-សោម អ្នកកាន់បញ្ជីសារពើភណ្ឌ

៥. — សឹង-ផន បណ្ណារក្ស

៦. សហជីវិនី ពេជ្រ-សល់ នាយការិយាល័យទំនៀមទម្លាប់

៧. សហជីវិន សូ-បូ លេខាធិការនៃទីប្រជុំ

ក្រោយពីថ្លែងអំណរគុណចំពោះអង្គប្រជុំមក សហជីវិននាយកបានថ្លែងបើកសម័យប្រជុំ ដោយយកបញ្ហាសមាគមសាស្ត្រាចារ្យសុំសៀវភៅវិជ្ជាស្ថាន របស់ពុទ្ធសាសនបណ្ឌិត្យ សម្រាប់ដាក់បណ្ណាល័យសមាគម តាមលិខិតលេខ ១ ស-ស-ខ- ១០ ចុះថ្ងៃទី ៧ កញ្ញា ១៩៦៤ មកដោះ

ស្រាយដូចតទៅ :

ទីប្រជុំក្រោយដែលបានពិភាក្សា ឬរយោបល់គ្នាអំពីពាក្យសុំនេះ ហើយដោយបានពិនិត្យទៅតាមគោលបំណងរបស់វិជ្ជាស្ថាន ដែលជាកន្លែងឃោសនាផ្សាយវប្បធម៌អក្សរសាស្ត្រជាតិ ហើយដោយយល់ថា សមាគមសាស្ត្រាចារ្យនេះមានសមាជិកដល់ទៅ ១.៣០០ នាក់ ហើយជាអ្នកកាន់ការផ្ទាល់ក្នុងការផ្សាយវប្បធម៌អក្សរសាស្ត្រ មានគោលបំណងដូចវិជ្ជាស្ថានរបស់យើងដែរ ហើយដោយហេតុពីមុនៗ មក ពុទ្ធសាសនបណ្ឌិត្យក៏ធ្លាប់បានទាក់ទង ធ្វើអំណោយសៀវភៅចំពោះអង្គការវប្បធម៌ដទៃទៀត ដែលមានគោលបំណងដូចគ្នានេះដែរ ។ ដូច្នេះ ទីប្រជុំបានមូលមតិជាឯកច្ឆ័នថា :

ទី ១ ត្រូវធ្វើអំណោយ នូវសៀវភៅដែលបានបោះពុម្ពផ្សាយរួចហើយ មួយមុខមួយក្បាល ។ លើកលែងតែសៀវភៅដែលជាភាសាបាលីសុទ្ធ ។

ទី ២– ត្រូវអញ្ជើញប្រធាន និងតំណាងសមាគមមកទទួលអំណោយនេះ នៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងថ្ងៃសៅរ៍ ៣០ តុលា ១៩៦៤ ពេលម៉ោង ៩ ព្រឹក ។

របៀបវារៈនៃការប្រជុំ ក៏បានចប់សព្វគ្រប់នៅវេលាម៉ោង ៩ ព្រឹក នៅថ្ងៃ ខែ ឆ្នាំ ដដែល ។

# សេចក្តីកត់ហេតុនៃការប្រជុំការងារទី ៨
# នៅពុទ្ធសាសនបណ្ឌិត្យ ថ្ងៃទី២១-១០-៦៥

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ ថ្ងៃទីម្ភៃមួយ ខែតុលា វេលាម៉ោងប្រាំបីព្រឹក នៅការិយាល័យលោកនាយកនៃពុទ្ធសាសនបណ្ឌិត្យ មានបើកការប្រជុំការងារមួយ ក្រោមអធិបតីភាពនៃសហជីវិន លាង-ហ័បអាន ជានាយក ដោយមានបុគ្គលិកច្រើនរូបចូលរួមប្រជុំផងគឺ :

១- សហជីវិន ញឹង-សៀង អគ្គលេខាធិការរង
២- — ឈឹម-ណាក នាយការិយាល័យគណនេយ្យ
៣- — ឌឹក-គាម នាយការិយាល័យបោះពុម្ពផ្សាយ
៤- — គុយ-សូត្រ បេឡាធិការ
៥- — សូ-ប៊ូ លេខាធិការនៃទីប្រជុំ

បន្ទាប់ពីអរគុណចំពោះទីប្រជុំរួចហើយ ហើយដើម្បីកុំឲ្យខាតពេលវេលា សហជីវិននាយកក៏បានប្រកាសបើកសម័យប្រជុំ ដោយយកបញ្ហាដែលត្រូវពិភាក្សាមួយម្តង ៗ មកជូនអង្គប្រជុំដោះស្រាយដូចតទៅ :

**បញ្ហាទី ១ :- គណនេយ្យរបស់ក្រសួង** - លោកនាយកបានមានប្រសាសន៍ថា ការលើកយកគណនេយ្យមកជំនុំពិភាក្សាពេលនេះ

គឺក្នុងគោលបំណងចង់ធ្វើតុល្យការ ប្រៀបធៀបចំណូលនិងចំណាយ ព្រមទាំងកំណត់នូវសេចក្តីរាយការណ៍ ចាប់ពីថ្ងៃដែលលោកមកទទួលការ ។

ទី១- ថវិកាឆ្នាំ ១៩៦៥ :- សហជីវិន ឈឹម - ណាក នាយការិយាល័យគណនេយ្យបានយកបញ្ជីថវិកាដំរាបបញ្ជាក់ ទំប្រជុំដូចតទៅ :

ក– ថវិកាបុគ្គលិកមាន : . . . ២.០៩៨.៤០០៛០០

ខ– ថវិកាសម្ភារៈដែលបោះពុម្ពផ្សាយមាន . . ១.៤៥៨·០០០៛០០

គ– ថវិកាសម្ភារៈទូទៅមាន : . . . . -២០៥.៥០០៛០០

ទី២- ចំណាយមកដល់ខែតុលា :-

ក– ចំណាយខាងបុគ្គលិក មកដល់ថ្ងៃ ៣០ ខែកញ្ញាអស់ ១.២៦២ ៣១៩៛០០ ។

នៅសល់សម្រាប់ដំណាច់ឆ្នាំ ១៩៦៥ មាន ៨៣៦.០៨០៛៦៩ ។

ខ– ចំណាយសម្ភារៈ ផ្នែកបោះពុម្ពផ្សាយមកដល់ថ្ងៃទី ៣០ ខែ ៩ - ៦៥ នៅសល់ ៣.៨០០៛ ។

គ– ចំណាយសម្ភារៈទូទៅមកដល់ថ្ងៃ ៣០ - ៩ - ៦៥ អស់ ១២១ · ៥៣៥៛១៥ ។

នៅសល់ ៨៣.៩២៤៛៨៥ ។

សេចក្តីវិនិច្ឆ័យ :- ចំពោះខទី ១ និងខទី ២ នៃថវិកាចំណូលនិង

ចំណាយ : ទីប្រជុំបានឃើញថា ថវិកាដែលគ្រោងសម្រាប់ឆ្នាំ ១៩៦៥ មានចំនួនគ្រប់គ្រាន់ហើយ ពុំមានខ្វះខាតទេ ។

ទី៣- ចំណូល :- បានមកពីការលក់សៀវភៅនានា ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៦៥ ព្រមទាំងការលក់សៀវភៅនៅសល់ក្នុងឆ្នាំពីឆ្នាំមុន ៗ មកទល់ថ្ងៃទី ២០-១០-៦៥ នេះ មានចំនួនប្រាក់ :

២-១១០-៦១៣៛៩២

សេចក្តីវិនិច្ឆ័យ :- ចំពោះចំណូលនិងចំណាយមកដល់ថ្ងៃ ២០-១០-៦៥

ទី១- ប្រៀបធៀបទៅនឹងចំណូលឆ្នាំ ១៩៦៤ :

– ឆ្នាំ ១៩៦៤ ចំណូលមាន : ១-៩១៥-៦៤៧៛៤៤

ឆ្នាំ១៩៦៥មកដល់ថ្ងៃ២០-១០-៦៥ចំណូលមាន :២-១១០-៦១៣៛៩២

គិតទៅលើសឆ្នាំ ១៩៦៤ ដល់ទៅ ១៩៤-៨៦៦៛០៨ ។

ទី២- ប្រៀបធៀបចំណូលត្រឹមថ្ងៃទទួលការរបស់នាយក:

– អគ្គលេខាធិការចាស់ « ដើមឆ្នាំ ១៩៦៥ មកទល់ថ្ងៃទី ១២ ៨-៦៥ » ចំណូលមាន ១-៤៦៧-៦១៦៛២៥ ។

– នាយកថ្មី ពីថ្ងៃ ១២-៨-៦៥ មកទល់ថ្ងៃ ២០-១០-៦៥ ចំណូលមាន :៦៤២-៩៩៧៛២៧

សរុបចំណូលទាំងអស់ : . . . . . ២-១១០-៦១៣៛៩២

ទី៣- ប្រៀបធៀបទៅនឹងថវិកាសម្រាប់បោះពុម្ពផ្សាយ :

- ថវិកាឆ្នាំ ១៩៦៥ : . . . . ១.៤៥៨-០០០៛០០

- ចំណូលមកដល់ថ្ងៃ ២០-១០-៦៥ មាន ២-១១០-៦១៣៛៥២

- ឃើញថាមានចំណេញ . . . . . ៦៥២.៦១៣៛៥២

ចំពោះរឿងចំណូលនេះ ទីប្រជុំបានសម្រេចថា នឹងរិតរំផ្សាយលក់សៀវភៅតាមគ្រប់មធ្យោបាយទៅទៀត ដើម្បីធ្វើយ៉ាងណា ឲ្យបានចំណេញកើនឡើង សម្រាប់ជួយដល់ថវិកាជាតិ ។

- បញ្ហាទី ២ :- រឿងលក់សៀវភៅ - ទីប្រជុំបានសម្រេចថា :

ក - អ្នកលក់ជារៀងរាល់ថ្ងៃ មុននឹងយកប្រាក់ទៅប្រគល់ជូនបេឡាធិការ ត្រូវយកបញ្ជីចំនួនទឹកប្រាក់ដែលលក់បាន មកសុំសេចក្តីបញ្ជាក់ពីនាយក ។ ប្រសិនបើនាយកមានធុរៈ ត្រូវជូនអគ្គលេខាធិការ ឬ នាយការិយាល័យគណនេយ្យបញ្ជាក់ ។

ខ បេឡាធិការ ក្នុងពេលបញ្ជប់បញ្ជីហិបប្រាក់កន្លះខែម្តង ត្រូវយកមកជូននាយកបញ្ជាក់ហត្ថលេខាផ្ទៀងផ្ទាត់សម្រេច ។

គ - បេឡាធិការ កាលបើបានទទួលបង្កាន់ដៃឃ្លាំងជាស្ថាពរហើយ ត្រូវយកមកបិទភ្ជាប់នឹងបញ្ជីហិបប្រាក់ជូននាយកពិនិត្យម្តងទៀត ។

## បញ្ហាទី ៣ :- រឿងប្រាក់បណ្តាក់ជាវសៀវភៅសម្រាប់បណ្ណាល័យវត្ត :

ទីប្រជុំបានសម្រេចប្រគល់ការៈជូនសហជីវិន ញូន សឿន អគ្គលេខាធិការរង និងសហជីវិន ឈឹម-ណាក នាយការិយាល័យគណនេយ្យ កាន់កាប់ទទួលខុសត្រូវ ។

ចំពោះប្រាក់បណ្ដាក់នេះ កាលណាសាមីខ្លួនអ្នកជាវយកមកបង់គ្រប់ចំនួនហើយ ត្រូវយកប្រាក់នោះទៅប្រគល់ឲ្យបេឡាធិការ ដើម្បីចេញបង្កាន់ដៃជាស្ថាពរ ។

ទីប្រជុំសុំឲ្យពិនិត្យបញ្ជីចាស់ដែលមានស្រាប់ឲ្យទៀងទាត់ ហើយទៅមុខត្រូវយកមកជូនទាយកចុះទិដ្ឋាការម្ដងក្នុងមួយខែ ។

## បញ្ហាទី ៤ :- អំពីការតាំងនាយការិយាល័យបណ្ណាល័យជំនួសលោក ស៊ឹង-ផន :

ទីប្រជុំបានសម្រេចបន្ថែមមុខងារ ជានាយការិយាល័យបណ្ណាល័យជំនួសសពសហជីវិន ស៊ឹង-ផន ចំពោះសហជីវិន ឌុក-គាម ដែលសព្វថ្ងៃជានាយការិយាល័យបោះពុម្ពផ្សាយទំព័របន្ទាស់ថ្មីជំនួសបាន ។

## បញ្ហាទី ៥ :- អំពីអត្ថបទឯកសាររបស់លោក ញ៉ុក-ថែម:

ដោយមហាវិទ្យាល័យគរុកោសល្យ ត្រូវការទារយកឯកសារនេះ ទៅវិញជាប្រញាប់ ហើយដោយខ្វះខាតបុគ្គលិកសម្រាប់ចម្លងឯកសារនេះ សម្រាប់ចុះកម្ពុជសុរិយា ទីប្រជុំសម្រេចជួលអ្នកចម្លង គិតតម្លៃ ១ ចប់យ៉ានក្រាសចំនួន ៤២០ ទំព័រ ជាប្រាក់ ៥០០៛០០ ដោយយកប្រាក់មូលនិធិអាស៊ីចំណាយ ។

ទីប្រជុំក៏ត្រូវប្រកាសបិទពេលប្រជុំចប់សព្វគ្រប់នៅម៉ោង ១០ និង ៣០ នាទី នាថ្ងៃ ខែ ឆ្នាំដដែល ។

ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ
និងសាសនៈសិក្សាធិការ

# ព្រះរាជអាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ១៧ ធ្នូ ១៩៦៥

ចុតហ្មាយអ្នកទកញ៉ាពិកក្តិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនៈសិក្សាធិការ ។

មកសហជីវិននាយកពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

កម្មវត្ថុ : សេចក្តីសរសើរជាផ្លូវការ ចំពោះសហជីវិន ញូង.សឿង

យោង : លិខិតសហជីវិនលេខ-១៨១១ ពប-ស ចុះថ្ងៃទី១៨ តុលា ១៩៦៥

តាមសេចក្តីស្នើសុំរបស់សហជីវិននាយកដូចយោងខាងលើ ខ្ញុំមានសេចក្តីពេញចិត្តជាខ្លាំង ហើយសុំសរសើរជាផ្លូវការចំពោះសហជីវិន ញូង.សឿង លេខាធិការ ការិយាល័យនិងខេត្តថ្នាក់លេខ ២ ការនាទីជាអគ្គលេខាធិការរងនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលបានខិតខំធ្វើការបម្រើក្រសួង ដោយយកចិត្តទុកដាក់បំពេញកិច្ចការ បានប្រកបនូវលទ្ធ-ផលយ៉ាងសំខាន់ក្នុងកំឡុងពេលចូលមកតំណែងរបស់ខ្លួន តាំងពីលេខា-ធិការធម្មការហូតដល់ទីអគ្គលេខាធិការ-រង ។ លក្ខណៈពិសេសទៀតគាត់ឧស្សាហ៍ ខិតខំបំពេញមុខងារ ជាខ្ញុំរាជការយ៉ាងប្រណីតរបស់ សហជីវិន ញូង.សឿង នេះ ទុកជាបុគ្គលិកគំរូមួយរូប ។

សេចក្តីសរសើរ ជាលាយលក្ខណ៍អក្សរនេះ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងផ្ទាល់របស់សាម៉ីរូប ទុកជាសក្ខីភាពនិងជាគុណប្រយោជន៍ខាងការងាររាជការតទៅ ។

ហត្ថលេខា អ៊ិន តាំ

ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ
និងសាសនៈសិក្សាធិការ

ព្រះរាជអាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ១៧ ធ្នូ ១៩៦៥

ចុតហ្មាយអ្នកឧកញ៉ាពិតក្តិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនៈសិក្សាធិការ ។

មកសហជីវិននាយកពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

កម្មវត្ថុ ៖ សេចក្តីសរសើរជាផ្លូវការចំពោះសហជីវិន អៀង-ស្បាង

យោង ៖ លិខិតសហជីវិន លេខ-១៤១១ បព-ស ចុះថ្ងៃទី ១៨ តុលា ១៩៦៥ ។

តាមសេចក្តីស្នើសុំរបស់សហជីវិននាយក ដូចយោងខាងលើ ខ្ញុំមានសេចក្តីពេញចិត្តជាខ្លាំង ហើយសុំសរសើរជាផ្លូវការ ចំពោះសហជីវិន អៀង-ស្បាង អ្នកនិពន្ធតែងសេចក្តីថ្នាក់លេខ ៤ ទទួលភារៈជានាយរក្សាឃ្លាំង និងទទួលខុសត្រូវចំពោះសៀវភៅចេញ-ចូល របស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលបានខិតខំធ្វើការបម្រើក្រសួងហួសពេលម៉ោងរៀងរាល់ថ្ងៃ ដោយយកចិត្តទុកដាក់បំពេញកិច្ចការបានប្រកបទៅលទ្ធផលយ៉ាងសំខាន់ ក្នុងកំឡុងពេលជាយូរឆ្នាំមកហើយ ។ លក្ខណៈពិសេសទៀតគាត់ឧស្សាហ៍ ខិតខំបំពេញមុខងារ ជាខ្ញុំរាជការយ៉ាងល្អរបស់សហជីវិន អៀង-ស្បាង នេះ ទុកជាបុគ្គលិកគំរូមួយរូប ។

សេចក្តីសរសើរ ជាលាយលក្ខណ៍អក្សរនេះ ត្រូវដាក់បញ្ចូលក្នុង សំណុំរឿងផ្ទាល់របស់សាម៉ីរូប ទុកជាសក្ខីភាពនិងជាគុណប្រយោជន៍ ខាងការងាររាជការតទៅ ។

ហត្ថលេខា អ៊ុន ពាំ

ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ
និងសាសនៈសិក្សាធិការ

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ១៧ ធ្នូ ១៩៦៥

ចុតហ្មាយអ្នកឧកញ៉ាពិតក្តិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនៈសិក្សាធិការ

មកសហជីវិននាយកពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

កម្មវត្ថុ : សេចក្តីសរសើរជាផ្លូវការចំពោះសហជីវិន មាស-សែត ។

យោង : លិខិតសហជីវិនលេខ-១៤១១ ពប.ស ចុះថ្ងៃទី១៨ តុលា ១៩៦៥

តាមសេចក្តីស្នើសុំរបស់សហជីវិននាយក ដូចយោងខាងលើ ខ្ញុំមានសេចក្តីពេញចិត្តជាខ្លាំង ហើយសុំសរសើរជាផ្លូវការចំពោះសហជីវិន មាស-សែត អ្នកនិពន្ធតែងសេចក្តីថ្នាក់លេខ ៤ ទទួលមុខងារជាអ្នកជាវសៀវភៅរបស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលបានខិតខំធ្វើការបម្រើក្រសួងហួសពេលម៉ោងរៀងរាល់ថ្ងៃ ដោយយកចិត្តទុកដាក់បំពេញកិច្ចការបានប្រកបទៅលទ្ធផលយ៉ាងសំខាន់ ក្នុងកំឡុងពេលជាយូរឆ្នាំមកហើយ ។ លក្ខណៈពិសេសទៀតគាត់ឧស្សាហ៍ ខិតខំបំពេញមុខងារ ជាខ្ញុំរាជការយ៉ាងល្អ របស់សហជីវិន មាស-សែត នេះ ទុកជាបុគ្គលិកគំរូមួយរូប ។

សេចក្តីសរសើរ ជាលាយលក្ខណ៍អក្សរនេះ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងផ្ទាល់របស់សាម៉ីរូប ទុកជាសក្ខីភាពនិងជាគុណប្រយោជន៍ខាងការងាររាជការតទៅ ។

ហត្ថលេខា អ៊ុន គាំ

# មរណភាពនៃសមាជិកឆ្លើយឆ្លងខាងទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ មានសេចក្ដីរន្ធត់ពន់ប្រមាណ នៅពេលដែលបានទទួលដំណឹងថា លោកឌួង-អ៊ុច ជាសមាជិកឆ្លងឆ្លើយបានទទួលមរណភាពទៅហើយ ។ ព្រោះថា តាំងពីច្រើនឆ្នាំមកហើយ សមាជិករូបនេះ បានជួយយកចិត្តទុកដាក់ក្នុងការរបស់ក្រុមជំនុំ ឥតដែលប្រហែសធ្វេសម្ដងណាឡើយ ។ នៅគ្រាបាត់បង់រូបលោក ឌួង-អ៊ុចទៅ ក្រុមជំនុំក៏ហាក់ដូចបាត់កម្លាំងមួយភាគយ៉ាងធំដែរ ។ អាស្រ័យហេតុនេះហើយ ទោះបីយល់ថា សង្ខារមនុស្សមិនទៀងពិតមែនក្ដី ក្រុមជំនុំនៅតែមានសេចក្ដីសោកស្ដាយពុំចេះអស់ហើយឡើយ ។

ហេតុនេះ ក្រុមជំនុំសូមថ្លែងរំលែកមរណទុក្ខ អំពីក្រុមគ្រួសារនៃសពយ៉ាងក្រៀមក្រំជាទីបំផុត ។ ហើយសូមសន្យាថានឹងរក្សាទុកនូវកិត្តិនាមកិត្តិស័ព្ទលោក ឌួង-អ៊ុច ជាដរាប ចំពោះស្នាដៃជាច្រើនដែលលោកបានតម្កល់ទុកជាសម្បត្តិជាតិក្នុងក្រុមជំនុំយើង ។